ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-Jan-2013, 14:08
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ១៨នាទី**

**សវនាការលើកទី១៥២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ គុលវុឌ្ឍី
លោក ដាវ អានសាន *(Mr.Dav ANSAN)*

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*
លោក ស៊ីម៉ុន មេសិនប៊ឺជ
*(Mr. Simon MEISENBERG)*
លោក ហ្វីលីព រ៉ូជឺ *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង
លោក លោក ឌេល លីសាក់ *(Mr.Dale Lysak)*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន
លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក ឡោ ជុនធី

លោក ហុង គីមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ល សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក អាល់ វ៉ុកូហ្វ (TCW-565) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖  លោក អាល់ រ៉ូកូហ្វ** (TCW-565)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ..........ទំព័រ ៥
សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ..........ទំព័រ ៨
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្ដើមពី ..........ទំព័រ ៥៩
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ..........ទំព័រ ៦៧

# កិច្ចដំណើរការនីតិវិធី

[០៩:១៨:៥៣]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនរួចហើយកាលពីអំឡុងថ្ងៃទី២៤ និងថ្ងៃ២៥ ខែមករា កន្លងទៅនេះ ថាអង្គជំនុំជម្រះនឹងរៀបចំធ្វើសវនាការស្តាប់សក្ខីកម្មមួយរូប គឺលោក អាល់ រ៉ុកូហ្វ (AL RockOff)។ ហើយថ្ងៃនេះគឺដោយមានព័ត៌មានសមស្រប ដែលអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មរូបនេះ តាមកាលវិភាគដែលបានកំណត់។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:២០:២៦]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តី មានវត្តមាន។ លើកលែងតែលោកមេធាវី ពេជ អង្គ មេធាវីនាំមុខជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីអវត្តមាន ដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។ ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយមូលហេតុសុខភាព។ រីឯជនជាប់ចោទ នួន ជា អវត្តមានដោយមូលហេតុសុខភាព និងកំពុងសម្រាកព្យាបាលនៅមន្ទីរមិត្តភាពខ្មែរ-សូវៀត។ ប៉ុន្តែជនជាប់ចោទបានដាក់នូវលិខិតលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការនៃការស្តាប់សក្ខីកម្មសាក្សី TCW-565 ដែលនឹងមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ។ ឯកសារលេខ E57/1។ ហើយសាក្សីរូបនេះមានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូបគឺលោក នួន ជា, អៀង សារី និង ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។ សូមអរគុណ។

[០៩:២១:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

មុននឹងកោះអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់លោក នួន ជា។ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានទទួលនូវលិខិតលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការដោយផ្ទាល់ សវនាការក្នុងការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-565 ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ដែលធ្វើឡើងនៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត តាមរយៈលោកមេធាវីការពារក្តីរបស់គាត់ និងរបាយការណ៍របស់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត លេខ ៩០មមខស ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ បានបញ្ជាក់ថា ស្ថានភាពសុខភាពលោក នួន ជា បច្ចុប្បន្នមានការកាន់តែល្អប្រសើរ និងមានលទ្ធភាពអាចចាកចេញពីមន្ទីរពេទ្យនៅសប្តាហ៍ក្រោយ។

[០៩:២២:៤៥]

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោក នួន ជា មានបញ្ហាសុខភាព និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ តែគាត់បានសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការនេះ និងស្ថានភាពសុខភាពបញ្ញាស្មារតីរបស់គាត់សមស្រប។ ហេតុដូច្នេះដើម្បីជៀសវាងនូវការពន្យារពេលសវនាការ និងដើម្បីជាប្រយោជន៍យុត្តិធម៌ ដោយផ្អែកលើពាក្យសុំសិទ្ធិក្នុងការមិនចូលរួមសវនាការ និងស្តាប់របាយការណ៍របស់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត អង្គជំនុំជម្រះសម្រេចធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-565 ដោយមិនមានវត្តមានជនជាប់ចោទ នួន ជា។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទាប់សវនាការ!

មន្ត្រីរដ្ឋបាលតុលាការកុំអាលទាន់អញ្ជើញគាត់មក! ឲ្យគាត់នៅទុំងសិនហើយ!

សូមអញ្ជើញលោក ម៉ៃខល កាណាវាស!

ឲ្យៗគាត់នៅចាំក្រៅសិនទៅ!

[០៩:២៤:០០]

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោក លោកស្រីចៅក្រម អស់លោក លោកស្រីនៅក្នុងនេះ។ មូលហេតុដែលខ្ញុំ

ក្រោកឈរ គឺពាក់ព័ន្ធទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាកាលពីថ្ងៃសុក្រ សូមពេលវេលាបន្ថែម។ យើងបានអ៊ីម៉ែល ប្រហែលជានៅម៉ោងបីសូន្យប្រាំមួយ ថ្ងៃសុក្រពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ។ នៅក្នុងកថាខណ្ឌ៣ នៃសំណើរបស់សហព្រះរាជអាជ្ញា ក្នុងពេលដែលលោករៀបចំការសួរដេញដោលលោករ៉ុកូហ្វ។ យើងដឹងថា ប្រហែលជាលោកសាក្សីរូបនេះអាចមានព័ត៌មានច្រើនបន្ថែមទៀត ដើម្បីមកផ្ដល់សក្ខីកម្មនៅក្នុងតុលាការនេះ។ ដូច្នេះសហព្រះរាជអាជ្ញាស្នើសុំពេលវេលាបន្ថែម។

ជាទូទៅយើងមិនប្រកាន់រឹងដូច្នេះនោះទេ នៅពេលដែលស្នើសុំពេលវេលាបន្ថែម។ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា យើងបានទទួលសំណើ ដឹងបញ្ហានេះកាលពីម៉ោងបី កាលពីថ្ងៃសុក្រសប្ដាហ៍មុន ហើយដោយសារយើងដឹងហើយថាសាក្សីនេះនឹងមកផ្ដល់សក្ខីកម្ម។ ហើយទី២ តាមរយៈផ្ដល់សក្ខីកម្មរបស់សាក្សី សាក្សីរូបនេះគឺថាមានព័ត៌មានច្រើនដែលនឹងផ្ដល់ជូន ហើយយើងដឹងច្បាស់ណាស់ថា តើ សាក្សីនេះជានរណា ហើយនឹងមកផ្ដល់អ្វីខ្លះ។ ដូច្នេះសំណើសុំកាលពីថ្ងៃសុក្រ ម៉ោងបីនោះ គឺថាវា ហាក់ដូចជាលឿនពេក ហើយយើងដឹងហើយថា សាក្សីរូបនេះគឺមាននៅក្នុងខ្សែវីដេអូ យើងបានដឹង ទាំងអស់ គ្នាហើយ។ វាជាការភ្ញាក់ផ្អើលណាស់ដែលសហព្រះរាជអាជ្ញានោះធ្វើសំណើនៅម៉ោងបី ថ្ងៃសុក្រ។ ហើយគាត់ថា អ៎! លោក រ៉ុកូហ្វ នេះប្រហែលជាមានព័ត៌មានច្រើនណាស់។ ដូច្នេះហើយ យើងខ្ញុំស្នើសុំព័ត៌មានបន្ថែម។

[០៩:២៥:៥៦]

ជាគោលការណ៍ យើងខ្ញុំគិតថា អង្គជំនុំជម្រះសាលាដំបូងគួរតែគោរពទៅតាមកាលវិភាគកំណត់ពេលវេលារបស់ខ្លួនទៅ។ ប្រសិនបើថ្ងៃអនាគត សហព្រះរាជអាជ្ញាស្នើសុំពេលវេលាបន្ថែមនោះគួរតែធ្វើសំណើនេះឲ្យបានទាន់ពេលវេលា ឲ្យមានពេលសមស្រប មិនអាចធ្វើសំណើសុំលឿនដូច្នេះនៅម៉ោងបី ថ្ងៃសុក្រដូច្នេះនោះទេ។

ហើយយើងដឹងហើយថា សាក្សីរូបនេះ គឺយើងដឹងហើយថា យើង -- គាត់នឹងមកផ្ដល់សក្ខីកម្មយើងស្គាល់គាត់ច្បាស់ គាត់ល្បី ហើយយើងដឹងថាប្រធានបទអ្វីខ្លះ ដែលសាក្សីនេះមកផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ហើយគាត់មិនមែនមកផ្ដល់សក្ខីកម្មលើសំណុំរឿង០០២ទាំងមូលនោះទេ។ យើងដឹងច្បាស់ទាំងអស់គ្នា។ សូមអរគុណ។

[០៩:២៦:៤៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ អស់លោក លោកស្រី មេធាវីភាគីទាំងអស់។ ខ្ញុំភ្ញាក់ផ្អើលដែរ ដែលខាងមេធាវីការពារក្តីនេះជំទាស់ ដែលគាត់រៀបរាប់អំពីករណីនេះមិនធ្លាប់មានពីមុន។ យើងដឹងហើយថា យើងញឹកញាប់ណាស់ដែលថា ភាគីមួយចំនួននោះបានស្នើសុំពេលវេលាបន្ថែមនៅថ្ងៃ ដែលសាក្សីមកផ្តល់សក្ខីកម្ម ហើយយើងខ្ញុំបានព្យាយាមជូនដំណឹងទៅដល់ភាគីឱ្យបានមុនរួចជាស្រេច។ បន្ថែមពីនេះ ខ្ញុំដឹងហើយថា នៅម៉ោងមួយល្ងាចតែប៉ុណ្ណោះដែលក្រុមមេធាវីការពារក្តី នួន ជា បានរៀបរាប់លើកឡើងថា ពួកគាត់បោះបង់សិទ្ធិមិនចូលរួមវត្តមាននៅក្នុងការស្តាប់សក្ខីកម្មរូបនេះ -- សាក្សីរូបនេះ។

[០៩:២៧:៥០]

ដូច្នេះហើយ យើងទើបតែបានដឹងនៅម៉ោងមួយកាលពីថ្ងៃសុក្រថា គាត់បោះបង់មិនមានវត្តមានចំពោះសាក្សីរូបនេះ។ ដូច្នេះហើយ វាមិនពាក់ព័ន្ធទៅនឹងសំណើនេះធ្វើកាលពីថ្ងៃសុក្រ ឬក៏យ៉ាងណានោះទេ នៅពេលដែលយើងសុំពេលវេលាបន្ថែមពាក់ព័ន្ធនឹងសាក្សីរូបនេះ។ យើងខ្ញុំបានព្យាយាមរួចជាស្រេចរួចមកហើយ ហើយយើងខ្ញុំគិតថាយើងនឹងអាចបញ្ចប់តាមកាលវិភាគ។

សំណើសុំដែលខ្ញុំធ្វើឡើងនេះ គឺដោយសារតែយើងដឹងហើយថា ពេលវេលាតុលាការនៅថ្ងៃស្អែកនោះ ប្រហែលជាអាចសម្រាប់ឱ្យយើងប្រើប្រាស់បន្ថែមបាន។ ស្ថិតនៅក្នុងកាលៈទេសៈទាំងអស់នេះហើយ ដូច្នេះយើងខ្ញុំគិតថា វាសមហេតុផលប្រសិនបើភាគីស្នើសុំពេលវេលាបន្ថែមចំពោះសាក្សីរូបនេះ។ យើងដឹងហើយថា សាក្សីរូបនេះអាចផ្តល់ព័ត៌មានបន្ថែមចាប់ពីថ្ងៃរហូត ថ្ងៃមុនឆ្នាំ៧៥ រហូតមកដល់ឆ្នាំ៧៥។

ដូច្នេះហើយ យើងដឹងថាពេលវេលាសម្រាប់សាក្សីរូបនេះ រួមទាំងថ្ងៃស្អែកនោះប្រហែលជាអាចធ្វើទៅបាន។ ហើយខ្ញុំនឹងបញ្ជាក់អង្គជំនុំជម្រះបន្ថែមទៀតនៅព្រឹកនេះ ថាតើពេលវេលាបន្ថែមប៉ុន្មានទៀតដែលថា យើងខ្ញុំសុំបន្តិចបន្តួចបន្ថែមនោះ ហើយយើងខ្ញុំនឹងឱ្យអង្គជំនុំជម្រះនោះជ្រាបទៅលើបញ្ហានេះ។ យើងខ្ញុំនឹងបញ្ចប់ការសួរដេញដោលសាក្សីនេះក្នុងពេលមួយសមស្របទៅតាមកាលវិភាគរបស់

អង្គជំនុំជម្រះ។ សូមអរគុណ។

[០៩:២៩:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣០:០៤]

**ប្រធានអង្គជំនុំ៖**

បាទ ចំពោះបញ្ហានេះអង្គជំនុំជម្រះ បន្ទាប់ពីបានស្តាប់នូវមតិយោបល់របស់ភាគីទាំងសងខាង អង្គជំនុំជម្រះនឹងពិចារណាសម្រេចតាមស្ថានភាពជាក់ស្តែងចាំបាច់នាពេលខាងមុខនេះ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

[០៩:៣០:២៧]

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:៣១:៣០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីលោកសាក្សី តើលោកឈ្មោះអី លោកអាចប្រាប់នាមត្រកូល និងនាមខ្លួនលោកជូនដល់អង្គជំនុំជម្រះបានដែរឬទេ?

**លោក អាល់ រ៉ុក្វហ្វ៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ អាល់ រ៉ុក្វហ្វ។

**ស៖** បាទ អរគុណលោក រ៉ុក្វហ្វ តើលោកអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ខ្ញុំមានអាយុ៦៤ឆ្នាំ។

**ស៖** អរគុណ។ តើលោកមានទីលំនៅសព្វថ្ងៃនេះនៅទីកន្លែងណា?

**ឆ៖** ខ្ញុំរស់នៅ ប៉ូឡូឌីដេវ ផ្លរីដា យូ.អេស.អេ សហរដ្ឋអាមេរិក។

**ស៖** បាទ អរគុណ។ ហើយតើលោកប្រកបមុខរបរធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំជាអ្នកថតរូប។

**ស៖** បាទ សូមរំឭកលោក រ៉ុក្វហ្វ ថា សូមលោករង់ចាំបង្អង់បន្តិចដើម្បីឱ្យក្បាលមីក្រូហ្វូនហ្នឹងប្រតិបត្តិការដោយឱ្យភ្លើងសញ្ញា ភ្លើងក្រហម មានន័យថាក្បាលមីក្រូហ្វូននឹងចាប់ផ្តើមប្រតិបត្តិការ

លោកអាចមានប្រសាសន៍បាន។ បើមិនដូច្នោះទេ សំឡេងរបស់លោកមិនចូលនៃប្រព័ន្ធនៃការស្តាប់សំឡេងនៅទីនេះ ក៏ដូចជាដល់អ្នកបកប្រែភាសាបានទេ។ បាទ សូមធ្វើដូច្នេះបាទ។

លោកអាចប្រាប់ដល់អង្គសវនាការអំពីថា តើឪពុករបស់លោក និងម្តាយរបស់លោកហ្នឹងគាត់ឈ្មោះអ្វីដែរ?

[០៩:៣៣:៥២]

**ឆ៖** ឪពុករបស់ខ្ញុំឈ្មោះ ល្វីស រ៉ុក្វូហ្វ។ ម្តាយខ្ញុំឈ្មោះ ម៉ារី រ៉ុក្វូហ្វ។

**ស៖** តើលោកមានប្រពន្ធដែរឬទេ ហើយបើមានតើប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធរបស់ខ្ញុំឈ្មោះ វ៉ិចតូរៀ ប៊ែនណឹស ហើយខ្ញុំគ្មានកូនទេ។

**ស៖** បាទ អរគុណ ហើយលោកមានសញ្ជាតិអ្វីដែរ?

**ឆ៖** ខ្ញុំជាជនជាតិអាមេរិក។

**ស៖** លោក អាល់ រ៉ុក្វូហ្វ ក្នុងនាមលោកជាសាក្សី ដែលត្រូវផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ អង្គជំនុំជម្រះតម្រូវឲ្យលោកធ្វើសម្បថទៅតាមជំនឿសាសនារបស់លោកជាមុនសិន តើលោកយល់ព្រមដែរឬទេ?

[០៩:៣៥:០០]

**ឆ៖** បាទ ខ្ញុំយល់ព្រម។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីសវនាការលោកស្រី ហ្វៃហ្សា សូមណែនាំដល់លោក អាល់ រ៉ុក្វូហ្វ ឲ្យធ្វើសម្បថតាមជំនឿសាសនារបស់គាត់។

**ក្រឡាបញ្ជី៖**

អារុណសួស្តី លោក រ៉ុក្វូហ្វ សូមឲ្យលោកយកដៃខាងឆ្វេងដាក់លើព្រះគម្ពីរ ហើយលើកដៃខាងស្តាំឡើងដើម្បីអានតាមខ្ញុំ។ "ខ្ញុំសូមប្រកាសដោយឱឡារឹកថា ខ្ញុំនិយាយតែការពិតៗ គ្មានអ្វីក្រៅតែពីការពិត"។

**លោក អាល់ រ៉ុក្វូហ្វ៖**

ខ្ញុំសូមប្រកាសជាឱឡារឹកថា ខ្ញុំនិយាយតែការពិតៗគ្មានអ្វីក្រៅតែពីការពិត។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទអរគុណលោក អាល់ រ៉ុក្កូហ្វ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹងលោកមិនមានជាប់ចំណងញាតិលោហិតញាតិពន្ធជាមួយនឹង បុគ្គលដែលត្រូវទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ នេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីនាក់ដែរគឺលោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន តើពិតមែនដែរឬទេ?

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** ពិតជាដូច្នោះមែន។

**ស៖** បាទ អរគុណ។ អង្គជំនុំជម្រះសូមជម្រាបជូនអំពីសិទ្ធិ និងករណីកិច្ចរបស់លោក លោក អាល់ រ៉ុក្កូហ្វ ក្នុងនាមលោកជាសាក្សីក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏សុំឲ្យលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលដាក់បន្ទុកលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ចក្នុងនាមលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬអង្គជំនុំជម្រះសួរចំពោះលោក។ ហើយលោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានធ្វើ ឬបានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តហេតុ នូវហេតុការណ៍ទាំងឡាយដែលលោកពាក់ព័ន្ធទៅនឹងសំណួរ អ៊ំ! ហេតុការណ៍ទាំងឡាយដែលមានភាពពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមសួរលោក។

លោក អាល់ រ៉ុក្កូហ្វ តើលោកធ្លាប់ដែលផ្តល់នូវកិច្ចសម្ភាសន៍ជាមួយនឹងមន្ត្រីអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលឬទេកន្លងមកនេះ?

**ឆ៖** មកទល់ពេលបច្ចុប្បន្នខ្ញុំមិនដែលធ្លាប់ទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមជម្រាបជូនតំណាងសហព្រះរាជអាជ្ញាថា នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិការជូនទៅ

តំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយពេលវេលាដូចអង្គជំនុំជម្រះបានជម្រាបជូនរួចហើយ។ សូមអញ្ជើញសហព្រះរាជអាជ្ញា!

[០៩:៣៨:៤១]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ អរុណសួស្តីលោកប្រធាន វ៉ុក្ខហ្វ។ ខ្ញុំឈ្មោះឌេល លីសាក់។ ខ្ញុំជាសហព្រះរាជអាជ្ញាមួយរូបនៅក្នុងតុលាការនេះ។ ហើយខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកនៅព្រឹកនេះ។ ខ្ញុំសូមរំឭកលោកថា យើងទាំងពីរនិយាយជាភាសាអង់គ្លេស មានអ្នកបកប្រែដែលបកទន្ទឹមពេលដែលយើងនិយាយ។ គឺបកសំណួរនិងចម្លើយដែលលោកឆ្លើយ។ ដូច្នេះ សុំឲ្យលោកបង្អង់បន្តិចបន្ទាប់ពីខ្ញុំសួរសំណួរដើម្បីឲ្យអ្នកបកប្រែនោះអាចបកឲ្យបានគ្រប់ជ្រុងជ្រោយ ហើយសូមឲ្យលោកមើលមីក្រូហ្វូនលោកផងនៅពេលដែលវាចេញភ្លើងក្រហមទើបលោកអាចនិយាយបាន។ ខ្ញុំសូមបញ្ជាក់សួរលោក។ លោកបញ្ជាក់ថាលោកជាអ្នកថតរូប តើលោកអាចរៀបរាប់ទិដ្ឋភាពទូទៅក្នុងមុខនាទីជំនាញរបស់លោកជាអ្នកថតរូបដែរឬទេ? តើលោកចាប់ផ្តើមធ្វើអាជីពជាអ្នកថតរូបហ្នឹងតាំងពីពេលណាមកដែរ?

[០៩:៤០:៤៧]

**លោក អាល់ វ៉ុក្ខហ្វ៖**

**ឆ៖** ខ្ញុំចាប់ផ្តើមការងារជាអ្នកថតរូបនៅពេលដែលខ្ញុំធ្វើការងារនៅក្នុងជួរកងទ័ពរបស់សហរដ្ឋអាមេរិក។ ដំបូងនៅក្នុងប្រទេសអាល្លឺម៉ង់ បន្ទាប់មកខ្ញុំទៅប្រទេសវៀតណាមក្នុងពេលដែលបម្រើទាហាននៅក្នុងជួរកងទ័ពវៀតណាមនោះ គឺនៅក្នុងប្រទេសវៀតណាមនោះ គឺថាខ្ញុំធ្វើការងារ ត្រូវបានផ្លាស់ប្តូរជាអ្នកកាសែតថតរូប។ នៅពេលដែលខ្ញុំចេញពីជួរកងទ័ពក្នុងនាមជាអ្នកថតរូបនៅក្នុងឆ្នាំ១៩៧៣ ខ្ញុំបានមកឥណ្ឌូចិននៅក្នុងឆ្នាំ៧៣រហូតដល់ខែឧសភា ឆ្នាំ១៩៧៥ ធ្វើអាជីពជាអ្នកថតរូបសម្រាប់អ្នកកាសែត។

**ស៖** សូមអរគុណដែលលោកបានឆ្លើយ។ និយាយអំពីរយៈកាលដែលលោកត្រឡប់មកប្រទេសកម្ពុជាវិញ ហើយធ្វើជាអ្នកថតរូបសម្រាប់កាសែតនៅក្នុងខែមេសា ឆ្នាំ៧៣ ដល់ ឧសភា ឆ្នាំ៧៥។ តើលោកអាចជម្រាបបានដែរឬទេ នៅពេលដែលលោកត្រឡប់មកប្រទេសកម្ពុជាវិញនៅក្នុងពេលនោះ តើ

បេសកកម្មទម្លាក់គ្រាប់បែកសហរដ្ឋអាមេរិកនៅតែបន្តទម្លាក់ទៀតដែរឬទេ នៅក្នុងអំឡុងពេលនោះ?

**ឆ៖** គឺនៅតែបន្ត។ បេសកកម្មទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនេះ បន្តរហូតដល់ខែសីហា ឆ្នាំ១៩៧៣។

**ស៖** លោកបានបញ្ជាក់ថាបេសកកម្មនេះបន្តរហូតដល់ថ្ងៃ១៥ ខែសីហា ឆ្នាំ៧៣។ តើលោកធ្វើម៉េចដឹងកាលបរិច្ឆេទនេះច្បាស់លាស់ទៅ?

[០៩:៤១:៤៧]

**ឆ៖** ខ្ញុំចាំថា ខ្ញុំចាំកាលបរិច្ឆេទនេះច្បាស់លាស់ណាស់ ដោយសារខ្ញុំនៅផ្លូវជាតិលេខ៣ នៅពេញមួយព្រឹក។ ហើយខ្ញុំចាំថាប្រហែលជាម៉ោងដប់ពីរថ្ងៃត្រង់ ពេលដែលថ្ងៃបញ្ចប់នៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ហើយគឺនៅពេលនោះគឺមានការទម្លាក់គ្រាប់បែកខ្លះនៅពេលនោះ។ ដូច្នេះហើយខ្ញុំចាំច្បាស់ណាស់ ថ្ងៃ១៥ ខែសីហា ឆ្នាំ៧៣ នៅពេលនោះ។

**ស៖** សូមអរគុណលោក រ៉ុកូហ្វ។ នៅពេលនេះខ្ញុំសូមសួរលោកសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងតំបន់មួយចំនួនដែលលោកបានទៅពិនិត្យមើល ក្នុងអំឡុងពេលសង្គ្រាមក្នុងប្រទេសកម្ពុជាចន្លោះពីឆ្នាំ៧៣ រហូតដល់ខែមេសា ឆ្នាំ៧៥។ តើលោកអាចជម្រាបបញ្ជាក់បានដែរឬទេ ប្រសិនបើលោកអាចផ្ដល់ជាទិដ្ឋភាពរួម ទិដ្ឋភាពទូទៅអំពីទីតាំងដែលលោកបានទៅថតរូបក្នុងនាមជាអ្នកថតរូបនោះ តើលោកបានទៅដល់ទីតាំងណាខ្លះដែរក្នុងអំឡុងពេលនោះ?

**ឆ៖** ក្នុងអំឡុងពេលដែលខ្ញុំធ្វើការងារនៅក្រៅទីក្រុងភ្នំពេញ គឺមានកន្លែងមួយចំនួនតិចណាស់ដែលខ្ញុំអាចទៅ ប្រហែលជា២០ ទៅ៣០គីឡូម៉ែត្រតែប៉ុណ្ណោះពីទីក្រុងភ្នំពេញ។ ទីកន្លែងមួយចំនួនក្រៅពីទីក្រុងភ្នំពេញ ផ្លូវជាតិមួយចំនួនត្រូវបានគេបិទទ្វារ បិទច្រក ហើយខ្ញុំនៅទៅតាមផ្លូវជាតិលេខ៤ ទៅកំពង់សោមពីរបីថ្ងៃ។ ខ្ញុំ -- នៅពេលដែលយើងចង់ទៅតាមជនបទឆ្ងាយណានោះ គឺថាយើងត្រូវតែទៅជាមួយនឹងយោធា ឬតាមឧទ្ធម្ភាគចក្រ។ ខ្ញុំបានទៅកន្លែងបន្តិចបន្តួចតែប៉ុណ្ណោះ។ ក៏ប៉ុន្តែជាទូទៅខ្ញុំទៅតាមផ្លូវជាតិ។ ឧទាហរណ៍ថាផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ៥ និងផ្លូវជាតិលេខ១។ ផ្លូវជាតិចំនួនបីដែលមាន ដែលសង្គ្រាមវាយប្រយុទ្ធជាសមរភូមិក្ដៅបានកើតឡើង។

[០៩:៤៣:៥៨]

**ស៖** តើមានអំឡុងពេលណាមួយ ក្នុងពេលសង្គ្រាមនោះ ចន្លោះឆ្នាំ៧៣ រហូតដល់៧៥ តើមានពេលណាមួយដែលលោកអាចមានលទ្ធភាពទៅដល់ម៉ុខដុង្គដែរឬទេ?

**ឆ៖** ខ្ញុំបានទៅដល់ឧដុង្គនៅក្នុងឆ្នាំ១៩៧០ នៅក្នុងពេលដែលខ្ញុំបម្រើក្នុងជួរកងទ័ពសហរដ្ឋអាមេរិក។ ការចូលលុកលុយរបស់អាមេរិកនៅក្នុងប្រទេសកម្ពុជាប្រហែលជា២ខែ។ ហេតុការណ៍កើតឡើងក្នុងឧដុង្គ ក្នុងអំឡុងពេល២ឆ្នាំ គឺប-៥២ ការទម្លាក់គ្រាប់បែកបេ-៥២ នេះបានធ្វើឡើងនៅក្នុងម៉ុឧដុង្គ -- ទីប្រជុំជនឧដុង្គនោះ។

**ស៖** ប្រសិនបើលោកនៅចាំ តើលោកចាំពេលណាមួយនោះដែលឧដុង្គ ទីប្រជុំជនឧដុង្គ ក្រុងឧដុង្គត្រូវបានខ្មែរក្រហមកាន់កាប់ ក៏ប៉ុន្តែក្រោយមកគឺរដ្ឋាភិបាល លន់ នល់ នេះបានកាន់កាប់វ៉ៃដណ្តើមយកមកវិញ។ តើលោកចាំហេតុការណ៍ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំចាំ ខ្ញុំមិននៅទីនោះទេ។ ខ្ញុំចាំហេតុការណ៍នោះ ក៏ប៉ុន្តែខ្ញុំអត់នៅទីនោះ ហើយខ្ញុំក៏មិនចាំកាលបរិច្ឆេទ ឬក៏ខ្ញុំនៅម៉ុណាជាក់លាក់ដែរនៅពេលនោះ។

[០៩:៤៥:៣៥]

**ស៖** ក្រោយកងកម្លាំងរដ្ឋាភិបាល លន់ នល់ វ៉ៃដណ្តើមក្រុងឧដុង្គមកវិញ តើលោកអាចធ្វើដំណើរទៅក្រុងឧដុង្គនោះវិញដែរទេ ដើម្បីពិនិត្យមើលស្ថានភាពទីប្រជុំជននៅទីនោះ?

**ឆ៖** អត់មានលទ្ធភាពទៅបានទេ។

**ស៖** តើលោកមានវត្តមានទេ នៅពេលដែលសមរភូមិវាយប្រយុទ្ធគ្នាកើតឡើងនៅក្រោយមកក្នុងឆ្នាំ១៩៧៤ ក្នុងខេត្តកំពង់ឆ្នាំង?

**ឆ៖** កំពង់ឆ្នាំង ខ្ញុំនៅទីនោះ គឺខ្ញុំនៅចាប់ផ្តើមពីខែតុលា ឆ្នាំ៧៤។ យើងមានឃើញមានសមរភូមិវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លារវាងខាងជនបះបោរចាមនិងខ្មែរ។ ហើយខ្ញុំបានទៅកំពង់ឆ្នាំងជួយធ្វើការដោះស្រាយទៅលើបញ្ហាសព ហើយខ្ញុំក៏ទៅទីនោះជាមួយនឹងសារព័ត៌មាន អា.អេហ្វ.ប៉េ ផងដែរ។ យើងឃើញមានខ្មែរ ទាហានខ្មែរដែលធ្វើការជីករក ឬក៏រកសាកសពមួយចំនួននៅទីនោះ។ ខ្ញុំនៅទីនោះ១យប់ ហើយស្អែកឡើងខ្ញុំក៏បានទៅធ្វើការកាយឃើញសាកសព លឹម សម្បត្តិ នៅទីនោះផងដែរ។ លឹម សាវ៉ាត។ ហើយគឺប្រហែលជាខ្ញុំនៅក្នុងខេត្តកំពង់ឆ្នាំនោះ ប្រហែល៣ថ្ងៃ។

[០៩:៤៧:២៤]

**ស៖** តើលោកមានរបួសដែរឬទេ នៅពេលដែលទៅដល់កំពង់ឆ្នាំង?

**ឆ៖** គឺមានប្រហែលជាអំបែង ហើយនិងគ្រាប់កាំភ្លើងខ្លះដែលវាមកត្រូវខ្ញុំ។ ខ្ញុំត្រូវរបួសធ្ងន់នឹងអំបែងគ្រាប់បែក ហើយអំបែងគ្រាប់បែកនេះត្រូវត្រង់កដៃរបស់ខ្ញុំ និងខ្លួនប្រាណរបស់ខ្ញុំផងដែរ គឺ

បេ-៥២។ ហើយអ្នកកាសែតមួយរូបទៀតដែលមានឈ្មោះ -- ដែលជាអ្នកកាសែតកូរ៉េ ឈ្មោះ លី ក៏ត្រូវរបួសដែរ។ យើងត្រូវបានយកទៅកន្លែងព្យាបាលនៅវាលទេ កន្លែងនុ៎ង ហើយគេវះកាត់ ហើយបានធ្វើការព្យាបាលខ្ញុំ។ ខ្ញុំត្រូវបានក្រុមវះកាត់កាកបាទក្រហម គឺវេជ្ជបណ្ឌិត អ៊ែរ៉ូណាន់ឌ័រ ជាអ្នកវះកាត់យកគ្រាប់ចេញ។ គាត់ធ្វើឲ្យស្ថានភាពរបស់ខ្ញុំ ធ្វើឲ្យស្ថានភាពគ្រោះថ្នាក់ -- របួសរបស់ខ្ញុំនោះគឺមានស្ថិរភាព ហើយនៅម៉ោងប្រហែលជាមួយទៅម៉ោងពីរគឺថា ខ្ញុំចាប់ផ្ដើមមានដឹងខ្លួនបន្តិច ហើយគេយកខ្ញុំទៅសៃហ្គន មន្ទីរពេទ្យយោធា ហើយធ្វើឲ្យស្ថានភាពគ្រោះថ្នាក់របួសរបស់ខ្ញុំនេះអាចឋិតថេរឡើងវិញ និងល្អឡើងវិញ ជាសះស្បើយ។

[០៩:៤៨:៥៩]

**ស៖** តើចំណាយរយៈពេលប៉ុន្មានដែរ ដែលធ្វើឲ្យលោកជាសះស្បើយពីជំងឺនេះ ហើយអាចវិលត្រឡប់មកប្រទេសកម្ពុជាវិញដើម្បីអាចធ្វើជាអ្នកកាសែតថតរូប?

**ឆ៖** ប្រហែលជាប៉ុន្មានខែដែរ ហើយខ្ញុំក៏បានវិលត្រឡប់មកប្រទេសនេះវិញ ប្រហែលជា៥អាទិត្យក្រោយមកគឺខ្ញុំវិលត្រឡប់មកវិញ។

**ស៖** នៅពេលនេះខ្ញុំសូមសួរលោកសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងអំឡុងពេលក្នុងខែ ឈានទៅដល់រហូតខែមេសា ឆ្នាំ៧៥។ សំណួរ ប្រធានបទដំបូងដែលខ្ញុំសូមសួរលោក ថាតើនៅក្នុងអំឡុងពេលនុ៎ង គឺខែមីនា, មេសា ឆ្នាំ១៩៧៥។ តើលោកធ្លាប់ឮការផ្សាយចេញពីវិទ្យុ ឬក៏សេចក្ដីថ្លែងការណ៍របស់ខ្មែរក្រហមពាក់ព័ន្ធទៅនឹងមហាក្បត់ទាំងប្រាំពីរដែរឬទេ?

**ឆ៖** ខ្ញុំឮរបាយការណ៍ផ្សាយតាមវិទ្យុ ខ្ញុំដឹងថាអ្នកពីរបីដែលទៅលើបញ្ហានេះ។ អ្នកកាសែតមួយចំនួនបានសរសេរ ខ្ញុំមិនច្បាស់ចំនួនសរុបប្រាំពីរ ឬក៏យ៉ាងណានោះទេ គឺមានជនមហាក្បត់មែន។ គេផ្សាយ របាយការណ៍គេផ្សាយនោះ គឺមិនមែននិយាយអំពីតែជនក្បត់នោះទេ គេក៏បានផ្សាយថា នៅពេលដែលសង្គ្រាមបញ្ចប់រួចរាល់នោះ គឺប្រជាជនគ្រប់រូបអាចត្រឡប់ទៅកន្លែងដែលពួកគេមកពីណាគឺអាចទៅកន្លែងនោះវិញ។ មានប្រជាជនមួយចំនួនគឺជឿទៅលើបញ្ហានេះ ក៏ប៉ុន្តែប្រជាជនភាគច្រើនដែលរស់នៅទីក្រុងភ្នំពេញនោះ ប្រហែលជា២លាននាក់នោះ គឺជាជនភៀសខ្លួនមកពីតាមតំបន់ផ្សេងៗ។

[០៩:៥១:១១]

**ស៖** ខ្ញុំសូមអានសារព័ត៌មាន លិខិតទំនាក់ទំនងសារព័ត៌មានរបស់ ហ្វឹង នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ៧៥ ចុះហត្ថលេខាដោយ ខៀវ សំផន ហើយគេបានចាក់ផ្សាយនៅក្នុងវិទ្យុរបស់ ហ្វឹង គឺឯកសារ

លេខ E3/117 លេខយោងអង់គ្លេសគឺទំព័រ 00166772, បារាំងមានលេខ 00281432, ខ្មែរមានលេខ 00242309។ កថាខណ្ឌមួយនៅក្នុងលិខិតទំនាក់ទំនងនោះ គឺរួមសរសេរនូវសេចក្ដីថ្លែងការណ៍ដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី "ពាក់ព័ន្ធទៅនឹងបនក្បត់ទាំងប្រាំពីរនៅក្នុងទីក្រុងភ្នំពេញ។ សន្និបាតជាតិបាន សម្រេចដូចខាងក្រោម៖ ជនក្បត់ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និងសូស្ដែន ហ្វែណង់ដែស គឺជាមេក្បត់ និងខ្សែដឹកជនក្បត់ធ្វើរដ្ឋប្រហារ។ ក្នុងនាម ហ្វីង និង ប្រ៊ុក្រុង និងកងទ័ពរំដោះប្រជាជន សន្និបាតជាតិបានប្រកាសថា ចាត់វិធានការចាំបាច់ទាំងឡាយ ដើម្បី សម្លាប់ជនក្បត់ បនក្បត់ទាំងប្រាំពីរនេះ"។ បញ្ចប់ការដកស្រង់សម្ដី។ ខ្ញុំចង់សួរលោកថា តើលោកនឹក ឃើញ ការផ្សាយរបស់វិទ្យុហ្វីង ពាក់ព័ន្ធទៅនឹងការកាប់សម្លាប់បនក្បត់របស់ លន់ នល់ ដែរឬទេ?

[០៩:៥៣:២៨]

**ឆ៖** ខ្ញុំមិនដែលបានធ្លាប់ឯកសារ ឬក៏អត្ថបទដែលបានសរសេរដោយអ្នកសារព័ត៌មានដូច្នេះ ណាស់ ក៏ប៉ុន្តែខ្ញុំពិតជាបានឮ អង្គហេតុដែលបានប្រកាសថា មានបុគ្គលមួយចំនួនត្រូវតែយកទៅសម្លាប់ ចោលអ៊ីចឹងមែន។

**ស៖** តើលោកអាចបញ្ជាក់ជូនយើងខ្ញុំដែរឬទេ? តើគេដឹងជាទូទៅពាក់ព័ន្ធទៅនឹងការផ្សាយថា នឹងសម្លាប់បនក្បត់ទាំងនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនអាចបញ្ជាក់ថា តើគេដឹងត្រឹមកម្រិតណា នរណាដឹងខ្លះនោះទេ? ខ្ញុំគ្រាន់តែដឹងថា ក្រុមរបស់ខ្ញុំ ជាអ្នកសារព័ត៌មានស៊ីឈ្នួល ធ្វើទៅតាមកម្រែនេះ គឺថាបានឲ្យដឹងទៅលើបញ្ហានេះ។

**ស៖** ក្នុងអំឡុងពេលរហូតទៅដល់ខែមេសា ឆ្នាំ៧៥ តើលោកធ្លាប់ឮការផ្សាយវិទ្យុដោយខ្មែរ ក្រហមណាមួយពាក់ព័ន្ធនឹងបញ្ហានេះដែរឬទេ?

[០៩:៥៤:៣៧]

**ឆ៖** អត់ធ្លាប់ឮទេ។

**ស៖** ខ្ញុំនៅពេលនេះ សូមសួរអំពីប៉ុន្មានថ្ងៃមុនពេលខែមេសា ឆ្នាំ៧៥វិញម្ដង។ តើលោកអាច ជម្រាបជូនយើងខ្ញុំបានដែរឬទេ តើលោកនៅម្ដុំណា? ស្នាក់នៅម្ដុំណា? ប៉ុន្មានថ្ងៃមុនខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** ខ្ញុំមានបន្ទប់ធំមួយនៅពេលនេះគឺជាសណ្ឋាគារអាស៊ីតាមមហាវិថីមុនីវង្ស ខ្ញុំធ្លាប់នៅម្ដុំនុ៎ង។

**ស៖** តើលោកអាចបញ្ជាក់បន្ថែមដែរឬទេ ដែលនៅពេលនោះគេហៅថាសណ្ឋាគារភ្នំនោះ?

**ឆ៖** ខ្ញុំទៅទីនោះញឹកញាប់ ហេតុផលគឺដោយសារតែខ្ញុំជាអ្នកកាសែតមួយរូប ហើយនៅទីនោះ

គឺមានកន្លែងទីតាំងរបស់សមាគមអ្នកកាសែត មានភោជនីយដ្ឋានល្អ មានអាងហែលទឹក គឺមួយប្លុកតែប៉ុណ្ណោះពីក្រសួងព័ត៌មានដែលនៅទីនោះយើងប្រជុំអ្នកសារព័ត៌មានប្រចាំសប្តាហ៍។ ខ្ញុំទៅញឹកញាប់ ហើយខ្ញុំទៅជាទូទៅបញ្ចប់ពេលដែលខ្ញុំបញ្ចប់បេសកម្មនៅតាមមូលដ្ឋាន ខ្ញុំទៅកន្លែងនោះ។ ខ្ញុំទាក់ទងជាមួយនឹងសារព័ត៌មាន អា.អេហ្វេ.ប៉េ ដែលនៅទីនេះគឺមានការិយាល័យបន្ទប់មួយបន្ទប់នៅទីនោះនៅក្នុងសណ្ឋាគារ។ ជាការពិតខ្ញុំទៅកន្លែងនោះញឹកញាប់ណាស់ ហើយពេលខ្លះខ្ញុំស្នាក់នៅទីនោះផងដែរ។ ខ្ញុំនៅទីនោះគឺនៅបន្ទប់ដែលជួលដោយ ឡូសអាន់ជឺលេស ប្រចាំឆ្នាំតែម្តង។ ហើយខ្ញុំគឺថា នៅទីនោះ ហើយអ្នកដែលជាស្មៀនទទួលបដិសណ្ឋារកិច្ចពេលខ្លះឲ្យខ្ញុំដឹងដែរ ហើយជម្រាបខ្ញុំអំពីព័ត៌មានមួយចំនួននៅពេលដែលមានគេមកជួប។

[០៩:៥៧:០០]

**ស៖** តើលោកអាចប្រាប់អំពីទីតាំងអូតែល នៅម្តុំជិតភ្នំនោះដែរឬទេ? ឬសណ្ឋាគារដែលគេថាសណ្ឋាគារភ្នំនោះ តើនៅជិតម្តុំសណ្ឋាគារ ឡឺរ៉ូយ៉ាល់ ឬក៏យ៉ាងណា?

**ឆ៖** បាទ តាមពិតទៅវាគឺជាសណ្ឋាគារតែមួយតែប៉ុណ្ណោះ។

**ស៖** តើលោកនៅចាំទេ នៅពេលមួយនោះ គឺថាមានក្រុមកាកបាទក្រហមនោះចូលទៅដល់អូតែលឡឺភ្នំនេះ សណ្ឋាគារឡឺភ្នំនេះ? ហើយបានបង្កើតទីតាំងនៅកន្លែងនោះមួយតែម្តងនៅទីនោះ តើលោកចាំទេ?

**ឆ៖** បាទ គឺមានបុគ្គលិកកាកបាទក្រហមដែលធ្វើការនៅអូតែលនោះ មានបង់កាឡូ មួយចំនួនដែលថាទីភ្នាក់ងារទៅធ្វើការទីនោះជាប្រចាំប្រហែល១សប្តាហ៍មុនពេលចប់សង្គ្រាមនោះ។ ប្រហែលជាពេលដែលសហរដ្ឋអាមេរិកដកខ្លួនចេញនៅថ្ងៃទី១២ ខែមេសា។ ហើយកាកបាទក្រហមបានប្រកាសថាកន្លែងនោះជាតំបន់សុវត្ថិភាព គឺមានរបាំង ហើយគេដាក់សញ្ញាកាកបាទក្រហមនៅទីនោះ ហើយអ្នកណាដែលត្រូវការព្យាបាលជាបន្ទាន់នោះ គឺអាចទៅទីនោះបាន គឺមានមនុស្សរាប់ពាន់ដែលរស់នៅទីនោះដើម្បីចូលទៅកន្លែងអូតែលនោះដើម្បីទីជម្រក។ កាកបាទក្រហមក៏បានបង្កើតនូវមន្ទីរពេទ្យបណ្តោះអាសន្នមួយនៅខាងក្រោយអូតែលនោះដែរ ប៉ុន្តែនៅថ្ងៃទី១៧ ខែមេសា ទោះជាយ៉ាងណាក្តីគឺពួកអ្នកទាំងនោះត្រូវបានគេបណ្តេញចេញពីទីតាំងនោះផងដែរ។

[០៩:៥៨:៥១]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំ យើងនឹងចូលទៅដល់ហេតុការណ៍នោះជាលម្អិតបន្តិចទៀត

នៅថ្ងៃនេះ។ ខ្ញុំចង់បង្ហាញជូនលោកអំពីរូបថតមួយចំនួនដែលយកបានមកពី -- ដែលលោកជាអ្នកថត គឺនៅក្នុងសៀវភៅមួយដែលនិយាយអំពីការធ្លាក់ចុះនៃរបបខ្មែរក្រហម។

**លោក ខេល លីសាក់៖**

លោកប្រធាន ឯកសារ D313/1.2.11 ៗ បាទ ឯកសារដែលខ្ញុំចង់ជូនសាក្សីនោះ គឺនៅទំព័រ 00432437 ហើយសូមអនុញ្ញាតដើម្បីបង្ហាញលើអេក្រង់ ហើយខ្ញុំជូនឯកសារលើក្រដាសទៅលោកសាក្សីផងដែរ។ សូមអនុញ្ញាតលោកប្រធាន!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១០:០០:២៦]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ខ្ញុំចង់ឲ្យលោកមើលរូបថតមួយលោក រ៉ុក្កូហ្វ លោកជម្រាបតុលាការ ថាលោកអាចថាតើនៅលើរូបថតនេះមានអ្វីខ្លះដែលថាតាមដែលលោកចងចាំនោះ?

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** បាទនេះជាអូតែលរ៉ូយ៉ាល់។ អគារដែលយើងមើលនៅខាងក្រោយគឺមានបដាររបស់កាកបាទក្រហម។ ខ្ញុំបានឃើញចម្លែកណាស់ ដោយថារូបថតនេះខ្ញុំបានឃើញ -- មិនឃើញមានមនុស្សសោះនៅទីនេះ ដែលជាទូទៅខ្ញុំឃើញរាប់រយ ហើយនៅខាងក្រោយរាប់ពាន់ ប៉ុន្តែនេះជាកន្លែងនោះហើយ ជាអូតែលលើភ្នំ ដែលហៅថា “ឡឺរ៉ូយ៉ាល់”។

**ស៖** លោកមើលទៅសញ្ញាដែលថា ស្លាកកាកបាទក្រហមហ្នឹងនៅហ្នឹង ដែលថាជាការពិតដែលលោកបានឃើញនៅទីនោះទេ លើរូបថតនេះនៅពេលនោះ?

[១០:០១:២៦]

**ឆ៖** បាទ។

**ស៖** ឥឡូវនេះខ្ញុំចង់ចូលទៅដល់ហេតុការណ៍នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សូមលោកជម្រាបតុលាការមើល៍ ថាតើមានហេតុការណ៍អ្វីខ្លះ? ថាតើមានហេតុអ្វីបានជាលោកបានដឹង? ដឹង

ដោយរបៀបណាថាទ័ពខ្មែរក្រហមបានចូលមកទីក្រុងភ្នំពេញនោះបាទ?

**ឆ៖** គឺនៅយប់ថ្ងៃ១៦ មេសា ហើយខ្ញុំនៅជិតការិយាល័យមន្ទីរប្រៃសណីយ៍បាទ ដែលមាន ស៊ីដនី សាន់ប៊ឺជ មកពីញូវយ៉កថៃមស៍ផងដែរ ចនស្វេន ផង ហើយយើងអាចនឹងបញ្ជូនឯកសារចេញ ដែលថាគ្រឿងម៉ាស៊ីន*ថេឡេថាយ*របស់យើងនៅតែបញ្ជូនចេញបាន។ ហើយគឺមានការបាញ់កាំភ្លើងដ៏ធំ នៅជិតស្ពានមុនីវង្ស ហើយមានគ្រាប់ផ្លោងកាន់តែខ្លាំងនៅជ្រោយចង្វាផងដែរ។ ការចង្អុលបង្ហាញទី១ នោះគឺថា ខ្ញុំដឹងថាខ្មែរក្រហមចូលមកដល់ហើយ គឺនៅក្នុងប្រហែលម៉ោងប្រាំបីពេលព្រឹក។ ហើយ ត្រឡប់មកអូតែលរ៉ូយ៉ាល់វិញ ហើយគឺខ្ញុំបានឃើញរថក្រោះ រថពាសដែកមកដល់ឡឺរ៉ូយ៉ាល់ទៅហើយ។ ហើយខ្លះទៀតក៏ទៅខាងជើង ហើយឆ្លងទៅទូតបារាំង ហើយពួកគេក៏បាននាំមកអ្នកនយោបាយរបស់គេ ហើយក៏បានឈប់នៅមុខ នៅព្រះវិហារកាតូលិកមួយដែលនៅជិតនោះ នៅជិតព្រះមុនីវង្ស វិថីព្រះមុនីវង្ស ហើយមានក្រុមមនុស្សជាច្រើនក៏បានចាប់ផ្ដើមប្រមូលផ្ដុំ ហើយកម្មាភិបាលដែលមានមីក្រូហ្វូនគេប្រកាស ថា "សង្គ្រាមចប់ហើយៗ"។

[១០:០៣:៤០]

អ្វីសព្វយ៉ាងគឺថាមិនមានបញ្ហាអ្វីទេនៅពេលនោះ ប្រជាជនមិនមានភ័យខ្លាចទេ ហើយគេបាន ទៅមើលទាហានទាំងអស់នោះ ជនស៊ីវិលក៏ធម្មតា។ ប៉ុន្តែ១ម៉ោងក្រោយមកអ្វីៗវាបានកែប្រែ។ អ្វីៗ ដែលខ្ញុំបានឃើញដំបូងហ្នឹងគឺថាពួកគេដឹកមកតាមរថយន្តធំៗ ហើយមកក្បែរស្ថានទូតនៅទីនោះ គឺ ម៉ោងប្រាំបីនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥នោះ។

**ស៖** នៅកន្លែងណា ហើយពេលណាដែលលោកបានឃើញដោយខ្លួនឯងថាទាហានខ្មែរក្រហម បានចូលមកដល់ទីក្រុងនោះ?

**ឆ៖** ប្រហែលជាម៉ោងប្រាំបីព្រឹក នៅអូតែលរ៉ូយ៉ាល់ ដូចខ្ញុំដែលបាននិយាយ គឺថាមកពីទិស ខាងត្បូង មកពីខាងទូតបារាំង។ មានក្រុមផ្សេងចូលមកពីទិសដៅផ្សេងទៀតដែរ។ ក្រុមដែលជួបក្រុម មួយទៀតដែលមកពីទូតបារាំងនោះ គឺក្រុមមកពីមុនីវង្សខាងត្បូង ផ្លូវមុនីវង្សខាងត្បូង ហើយអ្នកខ្លះគឺ បានចូលមកពីខាងកើត ប្រហែលជាផ្លូវ១០៨ ជាទីតាំងពីដើមនៃក្រសួងព័ត៌មាន។ ហើយមានមួយចំនួន គេរត់ចូលកន្លែងនោះដើម្បីមកការពារ។ ហើយខ្ញុំចំណាយពេល១ម៉ោង ២ម៉ោង ៣ម៉ោង ខ្ញុំមើលនៅ ក្រុង ហើយខ្ញុំបានទៅជាមួយកងទ័ព ហើយអាចធ្វើដំណើរបានស្រួល។ ហើយខ្ញុំអាចទៅដល់វិមាន ឯករាជ្យបាន ហើយរហូតទៅដល់ផ្លូវត្រឡែងកែងមុនីវង្ស ហើយនិងផ្លូវសីហនុបាន។ ប្រហែលជា១

ម៉ោងខ្ញុំអាចធ្វើដំណើរនៅពេលនោះ។

[១០:០៥:២៩]

ខ្ញុំបានថតរូបអារុធដែលដាក់គរ ហើយនិងទាហានយោធា ហើយក្រុមទាហានមកច្រើនដែលកំពុងធ្វើដំណើរដោយមានការយាមកាមផង ដែលបញ្ជូនទៅស្តាតអូឡាំពិកជាដើម។ ហើយខ្ញុំបានឈរក្បែរនៅកម្មាភិបាលម្នាក់ដែលគេនិយាយភាសាបារាំង ហើយ រ៉ូឡង់ ណឺវ៉ឺ (Roland Neveu) បាននិយាយថាខ្ញុំជាអ្នកកាសែត។ ហើយគេសួរជាភាសាបារាំង ខ្ញុំសប្បាយអង្កាល់ណោះ ខ្ញុំមិននិយាយភាសាបារាំង។ ហើយក្រោយមកខ្មែរក្រហមមួយចំនួនបានមកក្បែរៗនោះ ហើយបានឃើញខ្ញុំ បានឃើញដើរនៅចំកណ្តាលអ្នកដែលថាឈ្លើយសឹករបស់រដ្ឋាភិបាល។ ហើយខ្ញុំព្យាយាមទៅផ្នែកមួយទៀត ហើយខ្ញុំបានជួបខ្មែរក្រហមម្នាក់នាក់ទៀត ហើយគេឲ្យយើងលើកដៃ គេឲ្យឈប់ ហើយខ្ញុំអាចដើរ ហើយខ្ញុំអាចដើរ២០ម៉ែត្រទៀតទៅខាងស្តាំ ហើយឃើញរថយន្តមួយ ឃើញប្រហែលជា២, ៣នាទី ហើយអាចត្រឡប់មកវិញមិនមានបញ្ហាអ្វីទេ។ ហើយខ្ញុំគ្រាន់តែមិនចង់ឲ្យអ្នកណាម្នាក់សួរខ្ញុំជាភាសាបារាំង ដូចថា សួរថាអ្នកឯងជាអ្នកណា? ខ្ញុំជៀសពីបញ្ហាហ្នឹង។ ហើយខ្ញុំបានចាប់ផ្តើមត្រឡប់មកវិញខាងជើង ខាងផ្លូវមុនីវង្ស ហើយ *វ៉ាយពូហ្ស* គឺថាជាឡានប៉ីហ្ស-សមួយ ដែលខ្មែរជាអ្នកបើកបរទេ គឺ ហើយគាត់កំពុងបើកបរ ហើយគាត់បញ្ឈប់ គេបញ្ឈប់។

[១០:០៧:០៦]

ហើយខ្ញុំសូមគេជិះជាមួយផងអង្កាល់នោះ ហើយដោយមានអ្នកយាម ហើយគេសួរខ្ញុំជាភាសាបារាំង។ ខ្ញុំមិនយល់ទេ។ គេសួរថាអ្នកឯងមកពីណា? ខ្ញុំថាអាមេរិកាំង។ គេក៏ភ័យ។ គេនិយាយថា អ្នកឯងមកពី -- ខ្ញុំមកពីព្រះកេតុមាលា។ គេបានបណ្តេញប្រជាជនអ្នកជំងឺចេញពីមន្ទីរពេទ្យ។ ហើយខ្ញុំត្រឡប់មកអូតែលរ៉ូយ៉ាល់។ សូមអភ័យទោស។ ហើយខ្ញុំចូលមកដល់អូតែល ខ្ញុំដើរចូលទៅ ខ្ញុំបានឃើញគឺថា ឃើញ ឌិត ប្រាន (Dith Pran) ហើយជាអ្នកជំនួយការឲ្យ ស៊ីដនី សាន់ប៊ឺជ ។ ខ្ញុំមកដល់គឺ ស៊ីដនីបានក្រោកឡើង គឺថាយើងបានជិះឡានរបស់ ស៊ីដនី សាន់ប៊ឺជ ហើយយើងបានធ្វើដំណើរទៅមន្ទីរពេទ្យព្រះកេតុមាលា។

**ស៖** សូមបញ្ឈប់លោកត្រឹមនេះសិន ហើយត្រឡប់ទៅ នៅពេលដែលលោកចូលទៅដល់មន្ទីរពេទ្យហើយ ខ្ញុំនឹងសួរលោកសំណួរមួយចំនួនអំពីហេតុការណ៍ដែលលោកបានឃើញនៅពេលព្រឹក ដែលថា លោកបាននិយាយខាងដើមអំមិញនេះ។ លោកបានរៀបរាប់ប្រាប់តុលាការថា នៅទីក្រុងពេលនោះ

លោកបានថតរូប លោកបានដើរមើលឃើញទិដ្ឋភាពជាច្រើន។ ខ្ញុំសួរសំណួរមួយចំនួនទាក់ទងរឿងនេះ គឺថា តើសេចក្តីសង្កេតរបស់លោកថាទ័ពខ្មែរក្រហមដែលបានចូលមកដល់ទីក្រុងភ្នំពេញនោះដំបូង តើលោកអាចនៅចាំបានអ្វីខ្លះ ថាតើនិយាយពីអាយុរបស់យោធានោះថាតើអាយុប៉ុន្មាន? ជាកុមារ ឬក៏ជាមនុស្សចាស់ដែរ ជាកងទ័ពនោះ?

[១០:០៩:១១]

**ឆ៖** គឺថាមានអាយុវ័យជាក្មេងៗប្រហែលជា អាយុប្រហែល -- ខ្ញុំមិនអាចបញ្ជាក់ច្បាស់ទេ ប្រហែលជា១៦ឆ្នាំ បាទ។ ហើយដែលខ្ញុំតែងតែបានឃើញនៅក្នុងសមរភូមិបន្ទាប់ពីមានការស្លាប់របួសនោះ ឃើញមានខ្មែរក្រហមហ្នឹងគឺក្មេងៗ។ ហើយទាហានលន់ នល់ខ្លះក៏ក្មេងនោះដែរ។

**ស៖** ខ្ញុំបង្ហាញរូបថតលោក ដែលថានៅក្នុងសំណុំរឿងហើយឯកសារនេះ លោកប្រធានខ្ញុំសូមអនុញ្ញាតជម្រាបថាឯកសារនេះ D366/7.1.416 នេះជាឯកសារ D366/7.1.416។ សូមអនុញ្ញាតបង្ហាញលើអេក្រង់ ហើយសូមជូនឯកសារនេះទៅលោកសាក្សីផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:១០:៣០]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក រ៉ូកូហ្វ មើលរូបថតនេះ ហើយតើលោកស្គាល់រូបថតនេះដែរឬទេបាទ?

**លោក អាល់ រ៉ូកូហ្វ៖**

**ឆ៖** បាទ ខ្ញុំស្គាល់។ នេះជារូបរបស់ខ្ញុំ ដែលខ្ញុំបានថតនៅព្រឹកថ្ងៃទី១៧ ខែមេសា។

**ស៖** តើលោកអាចប្រាប់អំពីទីតាំងនៃការថតរូបនេះទេ ថតនៅកន្លែងណា?

**ឆ៖** នេះជាផ្លូវត្រឡែងកែង ផ្លូវមុនីវង្ស ហើយនិងផ្លូវព្រះសីហនុ។

**ស៖** ថាតើលោកស្គាល់ទេ អ្នកដែល -- អ្នកឈរនៅក្នុងរូបថតនេះកាន់ឧបករណ៍ ឬក៏អាវុធនេះលោកស្គាល់? បាទនៅខាងក្រោយនោះផងដែរ។

**ឆ៖** បាទ នេះជាខ្មែរក្រហម។

[១០:១១:៣០]

**សៈ** តើលោកនៅនឹកឃើញទេ ថាតើលោកអាចប្រាប់អំពីចំនួន -- ពីអាយុរបស់គាត់ ពួកគាត់នោះទេប្រហែលជាអាយុប៉ុន្មានដែរ ពួកទាហានទាំងអស់ហ្នឹង?

**ប្រធានអង្គជំនុំៈ**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក វិចទ័រ កូប៉េៈ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់សំណួរនេះ សាក្សីមិនមានជំនាញក្នុងការធ្វើការប្រមាណពីអាយុរបស់ទាហានខ្មែរក្រហម ឬទាហានខ្មែរបានទេ តាមដែលខ្ញុំពិនិត្យនោះ។

**លោក ឌេល លីសាក់ៈ**

នេះគឺជាបញ្ហាទាក់ទងដែលថា សាក្សីឬក៏អាចផ្តល់ជាការអាយុប៉ាន់ប្រមាណដោយថាគាត់មានបទពិសោធន៍។ ហើយយើងគឺថា យើងមិនឲ្យគាត់បញ្ជាក់ពីអាយុបែបវិទ្យាសាស្ត្រច្បាស់លាស់ទេ ឲ្យគាត់ប្រមាណតាមការយល់ដឹងដែលគាត់មានបទពិសោធន៍ពីលក្ខណៈប្រទេសនេះ។

[១០:១២:៣៨]

**ប្រធានអង្គជំនុំៈ**

បាទ សេចក្តីជំទាស់មិនសមស្របទេ បដិសេធសេចក្តីជំទាស់នេះ។ ហើយសាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញា។

**លោក អាល់ រ៉ុក្កូហ្វៈ**

**ឆៈ** សំណួរនោះគឺថា ថាតើខ្ញុំជឿថាអាយុប៉ុន្មាននោះ? ខ្ញុំគិតថាអាយុប្រហែល១៦, ១៧ឆ្នាំទេពួកអស់នោះនោះ។

**សួរដោយលោក ឌេល លីសាក់ៈ**

**សៈ** លោកអាចរៀបរាប់ជូនតុលាការបានទេ តើទាហាននោះក៏បានដាក់អីខ្លះនៅនឹងចង្កេះនោះមានក្រវាត់ មានជាឧបករណ៍អាវុធ គ្រាប់រំសេវអ្វីខ្លះបាទ?

**ឆៈ** គាត់មាន *ពីយ៉ូណែត* ហើយមានគ្រាប់បែក កាំបិតចំពុះទុង ហើយគឺថាមានកាបូបសម្រាប់ឃោធាមានអាវុធ ហើយជាឧបករណ៍ដូចគ្នាដែលរបប លន់ នល់ ក៏ប្រើឧបករណ៍នុំងដែរ គឺថាមានកាំបិតចំពុះទុង ហើយមានអឹមសី។ គឺថាភាគីទាំងសងខាងមានប្រើអាវុធដូចគ្នាអ៊ីចឹង។

[១០:១៣:៥៧]

**ស៖** សួរថាតើលោកនៅចាំដែរទេ ដែលថាអាវុធដែលទាហាននេះដែលកាន់នៅខាងស្តាំដៃ តើជាអាវុធអ្វី?

**ឆ៖** នេះគឺជាអាវុធ គឺជាអឹមសី របស់អាមេរិកាំង គឺជាអាវុធផលិតនៅអាមេរិកាំងបាទ។

**ស៖** បន្ថែមទៅលើទាហាននេះ តើលោកអាចជម្រាបតុលាការបានទេ តើមានប្រភេទអាវុធអីផ្សេងទៀត ដែលលោកបានឃើញថាទាហានទាំងអស់នោះបានប្រើ? ជាពិសេសទាហានខ្មែរក្រហម ដែលចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា នោះ។

**ឆ៖** ភាគច្រើននៃខ្មែរក្រហមទាំងអស់នោះគេកាន់អាវុធអាកា-៤៧ អ្នកខ្លះកាន់អាវុធ អឹមសី ឬហៅ អឹម-១៦ ប៉ុន្តែមិនច្រើនទេ។ អ្នកខ្លះក៏ហៅថា បេ-៤០នោះផងដែរបាទ។ ភាគច្រើនគឺថា ជាអាវុធប្រភេទហ្នឹង ហើយមានរថពាសដែកដែលខ្មែរក្រហមមកហ្នឹង ដែលមានជាយានយន្តហ្នឹងគឺថាជាពិសេសគឺសុទ្ធតែដែលគេដណ្តើមបាននៅព្រឹកថ្ងៃទី១៧ នោះឯង។

[១០:១៥:២៩]

**ស៖** ខ្ញុំសូមបង្ហាញលោកអំពីរូបថតមួយចំនួនទៀតដែលយកបានមកពី និយាយអំពីការដួលរលំនៃទីក្រុងភ្នំពេញ។ សូមអភ័សទោសដល់ខ្ញុំ ជាពិសេសគឺសូមទោសដោយសារបង្ហាញរូបថតនេះ ជារូបថតរបស់អ្នកលោកទៅវិញ។ ប៉ុន្តែដើម្បីគោលបំណងរបស់តុលាការ គឺយើងចង់ឲ្យឃើញថា ពេលខ្លះគឺមានការអត្ថាធិប្បាយដែលថា មានការបំផ្លាញទីក្រុងដោយគ្រាប់បែក ដោយអ្វីៗផ្សេង។ ដូច្នេះ ខ្ញុំនឹងបង្ហាញជូនអំពីរូបថតដូច្នេះ គឺថាលោកអាចនឹងយល់អំពីគោលបំណងរបស់ខ្ញុំថាហេតុអីបានជាខ្ញុំបង្ហាញរូបថតរបស់លោកឲ្យលោកឆ្លើយអ៊ីចឹង?

**លោក ឌេល លីសាក់៖**

អ៊ីចឹងសូមអនុញ្ញាតលោកប្រធាន រូបថតដែលខ្ញុំចង់បង្ហាញនេះ គឺឯកសារ D313/1.2.11 ជាសៀវភៅ រ៉ូឡង់ ណឿរ៉ី ហើយរូបថតពីរដែលខ្ញុំចង់បង្ហាញគឺមួយ គឺនៅទំព័រ 00432444, ហើយរូបថតទី២ គឺនៅទំព័រ 00432458។ សូមអនុញ្ញាតតុលាការដើម្បីបង្ហាញជូនរូបថតនេះទៅសាក្សីនូវរូបថតនេះ ហើយសូមអនុញ្ញាតលើអេក្រង់ផងដែរពីរូបថតទី១ ទៅបាទ។

[១០:១៧:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក រ៉ូកូហ្វ ខ្ញុំសូមចង់ចាប់ផ្តើមអំពីរូបថតទី១ ដែលបានបង្ហាញជូនលោក លោកគឺមើលទំព័រនៅខាងក្រោមហ្នឹង គឺលេខ 00432444។ សំណួរជូនទៅលើនោះ គឺថាតើលោកអាចកំណត់អត្តសញ្ញាណអំពីអាវុធ ដែលគេកាន់បានទេ? បុគ្គលម្នាក់ៗនេះ គេកាន់អាវុធអ្វីខ្លះ លោកស្គាល់ទេ អាចប្រាប់បានទេបាទ?

**លោក អាល់ រ៉ូកូហ្វ៖**

**ឆ៖** បាទ រូបថតហ្នឹង គឺ រ៉ូឡង់ ណឿរ៉ឺ ជាអ្នកថតនៅផ្លូវសីហនុ ខ្វែងនឹងផ្លូវមុនីវង្ស ខ្មែរក្រហមនៅខាងមុខនេះ គឺកាន់អាវុធ អ័រ.ប៊ី.ជី ហៅថា បេ-៤០។ ទី២នោះ គឺកាន់អាវុធបាញ់គ្រាប់បែក គេហៅថា អឹម-សឺវេនធីណាយ គឺថា អឹមសឺវេនធីណាញ។ គឺថាដែលមានគ្រាប់បាល់វា ទំហំវា៤០មីល្លីម៉ែត្រ។ ដូច្នេះគ្រប់នៅ នឹងផ្ទុះសេនៅទ្រូងគាត់ គាត់យកមកច្រកដើម្បីបាញ់ គឺថាមាន អ័រ.ភី.ជី អាវុធជាច្រើនប្រភេទហ្នឹង គេប្រើ។

**ស៖** សំណួរដែលខ្ញុំចង់សួរលោកផងដែរអំពី យើងមើលរូបថតនេះទៅនៅថ្ងៃនោះ តើលោកអាចកំណត់អត្តសញ្ញាណខ្មែរក្រហមដោយរបៀបម៉េច ហើយថាដឹងដូចម្តេចថាខុសពីទាហានរបស់លន់ នល់ នោះ? តើមានវិធីអ្វីដែលលោកបែងចែកបាន ចំពោះយើងខ្ញុំនេះដូចពិបាកនឹងបែកចែកថា ទ័ពខាងណាជាខាងណា? តើលោកអាចពន្យល់តុលាការបានទេ?

[១០:១៩:៣០]

**ឆ៖** មិនជាការងាយស្រួលទេ ដើម្បីបែកចែកអំពីឯកសណ្ឋានទ័ពនោះ គឺជួនកាលយើងច្រឡំគ្នា ក៏ប៉ុន្តែនៅពេលដែលខ្មែរក្រហមចូលមកម៉ោងបីប្រាំ នៅថ្ងៃទី១៧ នោះ គឺថាទាហាន លន់ នល់ នោះ គឺមិនមានអាវុធតទៅទៀតទេ។ អានេះគឺជាភាពខុសគ្នាត្រង់ហ្នឹង។

**ស៖** តើខ្ញុំអាចសួរលោកតទៅទៀត ថាតើមានភាពខុសគ្នាអំពីទ្រនាប់ជើងពួកទាហានខ្មែរក្រហម ហើយនិងទាហាន លន់ នល់ ដែរឬទេ?

**ឆ៖** ខ្មែរក្រហមជាច្រើនគេបានពាក់ទ្រនាប់ជើងផ្ទាត់ ភាគីច្រើនក៏អត់មានពាក់ទ្រនាប់ជើងទេ។ អ្នកខ្លះគេហៅថា មានទ្រនាប់ជើងប៊ូត គេហៅថា ទ្រនាប់ជើងកវែងនោះ សម្រាប់ដើរកាត់ព្រៃដែរ

ផលិតនៅអាមេរិកកាំង។ ជួនកាលគឺថា មិនសូវមានច្រើនទេ ប៉ុន្តែមានខ្លះដែរ ហើយខ្ញុំធ្លាប់មានទ្រនាប់ជើងឃ្លុបរបស់កងទ័ពហ្នឹង ប៉ុន្តែក្រោយមកគេលួចរបស់ខ្ញុំ។

**ស៖** និយាយអំពីទាហាន លន់ នល់ វិញ ថាតើពួកគេធ្លាប់ដើរជើងទទេ ឬក៏មានទ្រនាប់ជើងផ្ទាត់អ្វីដែរឬទេ?

**ឆ៖** ខ្ញុំទៅសមរភូមិដែរ ជាមួយកងទ័ពរដ្ឋាភិបាល ហើយពួកគេមានឯកសណ្ឋានត្រឹមត្រូវ គឺកម្រនឹងមានពាក់ទ្រនាប់ជើងនោះណាស់។ ហើយខ្ញុំមិនបានឃើញអ្វីដែលគេហៅថា ដែលថាកងចំពោះដូចថាទ្រនាប់ជើងកង់ឡានបែប ហូ ជីមិញទេ ពួកទាហាន លន់ នល់ ប៉ុន្តែខ្មែរក្រហមគេមាននៅពេលដែលឃើញ យើងឃើញទៅដល់សមរភូមិយើងឃើញមានសាកសពដែលថាខ្មែរក្រហមស្លាប់ឃើញមានទ្រនាប់យើងកង់ឡានហ្នឹង។ ប៉ុន្តែទ័ពរបស់រដ្ឋាភិបាលគឺថាជាអង្គភាពត្រឹមត្រូវគឺថាមានឯកសណ្ឋានត្រឹមត្រូវមានទ្រនាប់ជើងឃ្លុបរបស់ទាហានអីជាឯកសណ្ឋានត្រឹមត្រូវ។

[១០:២១:៤៨]

**ស៖** នៅថ្ងៃទី១៧ ខែមេសា នៅពេលនោះ តើលោកបានឃើញខ្មែរក្រហមណាដែលប្រាស្រ័យទាក់ទងគ្នាតាមវិទ្យុទាក់ទងអ្វីដែរទេ?

**ឆ៖** បាទ គឺថាគេមានបណ្ដាញវិទ្យុទាក់ទងល្អណាស់។ ខ្មែរក្រហមខ្លះមានវិទ្យុ បាទ សហរដ្ឋអាមេរិកទៀត គេហៅ ភីអ័រស៊ី-២៥ (PRC-25) តេប្រាំ គេហៅ តេវ៉ាំងសែង នោះ បាទ ហើយពេលខ្លះគេមានរបស់ចិន។ គេមានវិទ្យុហៅថា ម៉ូតូរ៉ូឡា គេប្រើជាបង់ដ៏ទេ ប៉ុន្តែមិនមានច្រើនទេ។ ប៉ុន្តែតាមធម្មតា គឺគេមានអ្នកទទួលខុសត្រូវ គេមានអ្នកប្រើវិទ្យុទាក់ទងនៅក្បែរក្រុមរបស់គេហ្នឹងដែរ។

**ស៖** ខ្ញុំចង់សួរលោកបន្តិចទៀត ហើយខ្ញុំនឹងបង្ហាញរូបថតមួយចេញពី វ៉ូឡង់ ណឺរ៉ុ នេះដែរ។

**លោក ឌេល លីសាក់៖**

លោកប្រធានជាឯកសារដដែលទេ គឺ D313/1.2.11 រូបថតនេះនៅទំព័រ 00432453។ សូមអនុញ្ញាតតុលាការដើម្បីបង្ហាញនៅលើអេក្រង់ ហើយនិងបង្ហាញជូនសាក្សីផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:២៣:៣៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងរូបថតនេះ លោកសាក្សី ហើយមានទាហាននៅក្នុងជួរកណ្ដាល ហើយនិងសួរលោកថាតើលោកអាចនូវស្គាល់ពីឧបករណ៍គ្រាប់រំសេវដែលទាហាននេះប្រើដែរឬទេ? ដែលឃើញនៅក្នុងរូបថតនេះ ដែលគាត់ទំនងជាកាន់អ្វីស្ដាប់នឹងត្រចៀករបស់គាត់ផង?

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** មិនសូវជាច្បាស់ប៉ុន្មានទេ ប៉ុន្តែខ្ញុំជឿថា អានេះជាប្រដាប់ឆ្លើយទាក់ទងតាមវិទ្យុទាក់ទងហើយ ប៉ុន្តែខ្ញុំមិនអាចអះអាងឲ្យប្រាកដទេ។

**ស៖** តើលោកអាចស្គាល់ទីតាំងនៃរូបថតនេះដែរឬទេ? តើលោកអាចជម្រាបតុលាការ តើពួកនេះជាកងទ័ពខ្មែរក្រហម ឬក៏ទាហានខាងណា?

**ឆ៖** បុរសនៅកណ្ដាលនេះ ដែលកាន់វិទ្យុដើម្បី -- ដែលមានស្ពាយអាវុធនេះ ខ្ញុំមិនអាចនិយាយថា គាត់ជាខាងណាទេ ប៉ុន្តែម្នាក់ទៀតនៅខាងស្ដាំនៃរូបថតនេះ មើលទៅគឺដូចខ្មែរក្រហមណាស់។ ប៉ុន្តែអ្នកដែលនិយាយវិទ្យុនេះ ខ្ញុំមិនអាចអះអាងបានទេ ពីព្រោះគាត់មានអាវុធដែលខ្ញុំអាចនឹងមិនប៊ានសន្និដ្ឋានដោយច្បាស់ថាជាខ្មែរក្រហមទេ។

[១០:២៥:១៦]

**ស៖** សូមអរគុណ។ លោកបាននិយាយនៅក្នុងសេចក្ដីពណ៌នាដំណើរនៅក្នុងទីក្រុងនៅពេលនោះ ហើយលោកបានយោងទៅរកដំណើរដែលថាលោកមកពីខាងត្បូងផ្នែកខ្លះនៃទីក្រុងនោះ។ នៅក្នុងការធ្វើដំណើរនោះនៅទីក្រុងពេលព្រឹកនោះ តើលោកបានសង្កេតឃើញអ្វីខ្លះអំពីខ្មែរក្រហមដែលថា ដែលមកពីកន្លែងណាហើយមកកាន់ខាង កាន់កាប់ភាគខាងត្បូងនៃទីក្រុងហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបានឃើញចំនួនខ្មែរក្រហមមួយចំនួនច្រើនមកពីខាងជើងចូលមកតម្រង់វិមានឯករាជ្យ កងទ័ពទាំងអស់នេះមើលទៅដូចជានឿយហត់ ហើយអារម្មណ៍មិនសូវល្អទេ ខោអាវគគ្រិចចូលមកទីក្រុងមកពីកន្លែងមួយដែលថា អាចថាជាកន្លែងដែលច្បាំងគ្នាហើយនៅជិតស្ពានព្រះមុនីវង្សនេះឯង តាមខ្ញុំគិត។ ខ្ញុំសម្រេចចិត្តថាមិនទៅឲ្យឆ្ងាយជាងនឹងទៀតទេ ហើយខ្ញុំក៏ត្រឡប់មកវិញមកពីវិមានឯករាជ្យមកខាងជើង ហើយបន្ទាប់មកក៏ខ្ញុំចេញទៅផ្លូវមុនីវង្សវិញ បន្ទាប់មកក៏ត្រឡប់មកផ្លូវត្រឡែកែង ផ្លូវព្រះសីហនុ និងផ្លូវមុនីវង្សវិញ។ ខ្ញុំនៅកន្លែងហ្នឹងប្រហែលជា១ម៉ោង ហើយគឺជាការបាញ់អាវុធហ្នឹងមិនសូវច្រើនប៉ុន្មានទេ ប៉ុន្តែមានខ្មែរក្រហមជាច្រើនបានមកនៅទីនេះជាច្រើន ប៉ុន្តែមិនទាន់ធ្វើអ្វីនោះទេ

ខ្មែរក្រហមមកជិះរថយន្តហើយក៏បានហូប ពេបស៊ី ទឹកក្រូច ប៉ុន្តែម្នាក់ៗគឺមានអារម្មណ៍ជាធម្មតាដូចជាមិនបង្ហាញភាពតានតឹងប្រកួតប្រជែងអីទេ ហើយជនស៊ីវិលក៏នៅម្ដុំហ្នឹងដែរ។

[១០:២៧:២១]

បាទរូបថតរបស់ខ្ញុំគឺបង្ហាញថា ខ្មែរក្រហមមានកាន់អាវុធ អឹមសី ហើយខ្មែរក្រហម នៅក្បែរស្ថានីយ៍សាំងនោះផងដែរ។ ប៉ុន្តែគឺថា បន្ទាប់មកគឺថាពួកគេមានមកជាច្រើនដោយមានអាវុធមានក្មេងមានកូនសិស្ស មានក្មេងៗដែលគេចាត់តាំងឲ្យប្រមូលអាវុធយកមកដាក់លើរថយន្តរបស់គេនោះ។

**លោក ខេល លីសាក់៖**

នៅពេលនេះលោកប្រធានខ្ញុំចង់បង្ហាញជូនរូបថតពីរទៀត ជូនលោកសាក្សីមកពីសៀវភៅ ដដែលហើយនៅទំព័រ 00432481 ហើយនិង 00432482 បាទ សូមអនុញ្ញាតិបង្ហាញរូបថតលើអេក្រង់កុំព្យូទ័រ ហើយសូមអនុញ្ញាតិលោកប្រធានដើម្បីបង្ហាញរូបថតលើក្រដាសជូនសាក្សីផងដែរបាទ។

[១០:២៨:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតិ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក រ៉ូក្លូហ្វ សូមឲ្យលោកមើលរូបថតពីរសន្លឹកដែលខ្ញុំបញ្ជាក់អម្បាញ់មិញ។ តើលោកអាចបញ្ជាក់ទេថាតើមានរូបភាពអ្វីខ្លះនៅក្នុងរូបថតនេះ?

**លោក អាល់ រ៉ូក្លូហ្វ៖**

**ឆ៖** ជាអាវុធដែលគេបានរឹបអូសដាក់ប្រមូលផ្ដុំគ្នាពីទាហាន លន់ នល់។ ខ្ញុំជឿថារូបថតលើលេខ 91 និង92 របស់សៀវភៅ រ៉ូឡង់ ហ្នឹងគឺថាខ្ញុំបានថតនៅតាមផ្លូវមុនីវង្ស និងផ្លូវព្រះសីហនុ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកថតរូបថតទាហានដែលមកពីខាងត្បូងមហាវិថីមុនីវង្សតើនៅក្នុងពេលនោះលោកសង្កេតឃើញប្រជាជនត្រូវបានបណ្ដេញចេញពីទីក្រុងដោយទាហានខ្មែរក្រហមដែរឬទេ?

[១០:៣០:០០]

**ឆ៖** អត់ឃើញទេ។ ខ្ញុំមិនឃើញខ្មែរក្រហមយកប្រជាជនណាមួយចេញ បណ្ដេញពីទីក្រុងភ្នំពេញនោះទេ។ ក៏ប៉ុន្តែខ្ញុំឃើញ គ្រាន់តែដំបូងនោះឃើញមានការឲ្យប្រជាជន ជម្លៀសប្រជាជននោះ

ប្រហែលជា១ម៉ោង ២ម៉ោងចេញពីទីក្រុងភ្នំពេញ។

**ស៖** ខ្ញុំសូមអានការដកស្រង់អត្ថបទមួយចេញពីសៀវភៅលោក ចន ស្វេន ដែលនៅក្នុងនោះគឺយោងទៅលើអ្វីដែលលោកបានប្រាប់ទៅគាត់។ ព្រឹកមិញនេះលោកនិយាយអំពី ចន ស្វេន ដែរ តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះទេ ចន ស្វេន ហ្នឹងជានរណាគេដែរ?

**ឆ៖** គឺជាអ្នកកាសែតសរសេរសៀវភៅរបស់ជនជាតិអង់គ្លេស។

**ស៖** តើនៅថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ និងថ្ងៃខាងមុខបន្តបន្ទាប់ទៀតនោះ តើលោកមាននៅជាមួយគាត់ដែរឬទេ?

**ឆ៖** ជាការពិតនៅរសៀលថ្ងៃ១៧ ខែមេសា ៧៥ និងប៉ុន្មាន១អាទិត្យ ២អាទិត្យក្រោយមកទៀត។

[១០:៣១:៣៤]

**ស៖** នៅក្នុងអំឡុងពេលនោះតើលោកឃើញមាន ឃើញលោក ស្វេន នេះ កត់ត្រាទុកនៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ទេ នូវព័ត៌មានមួយចំនួននោះ?

**ឆ៖** បាទ ខ្ញុំឃើញគាត់កត់ទុក។

**លោក ឌេល លីសាក់៖**

លោកប្រធាន នៅពេលនេះ ខ្ញុំសូមអនុញ្ញាតអានការដកស្រង់ចេញពីអត្ថបទរបស់លោក ចន ស្វេន សៀវភៅចំណងជើងថា "ការដួលរលំទីក្រុងភ្នំពេញ" ឯកសារ D313/1.2.6។ ខ្ញុំសូមកែតម្រូវចំណងជើងសៀវភៅ គឺជំពូកសៀវភៅនោះ គឺជំពូកនោះគឺថា មានចំណងជើង "ដួលរលំទីក្រុងភ្នំពេញ" ហើយចំណងជើងសៀវភៅនោះគឺ *"រីវើ អូហ្វ ថាមស៍"* លេខERN គឺមានលេខ -- សៀវភៅជាភាសាខ្មែរមានលេខ 00738393 រហូតទៅដល់94, អង់គ្លេសមានលេខ 00431267 ដល់68។ ខ្ញុំសូមដកស្រង់សម្ដី "រ៉ុក្ហូ មកពីខាងត្បូង ហើយនៅក្នុងនោះ ពេលនោះ គឺថាឃើញខ្មែរក្រហម។ ខ្មែរក្រហមស្លៀកពាក់សម្លៀកបំពាក់ឯកសណ្ឋាន ហើយដើរចុះដើរឡើង។ យើងឃើញមានរដ្ឋាភិបាលទាហានដែលត្រូវបានគេដកហូតអាវុធ ទាហាន យើងឃើញ ហើយឃើញមានទាហានរដ្ឋាភិបាល ដែលត្រូវបានគេដកហូតអាវុធ ហើយត្រូវបានគេបណ្ដើរទៅកន្លែងផ្សេង"។ ខ្ញុំសូមបញ្ចប់ការដកស្រង់សម្ដី។ តើលោកចាំដែរឬទេថាលោកបានប្រាប់លោក ស្វេន ថាគេបណ្ដើរទាហានរដ្ឋាភិបាលចេញចេញពីទីក្រុងភ្នំពេញ? តើលោកបានឃើញហេតុការណ៍ហ្នឹងនៅក្នុងពេលណាដែរ នៅពេលដែលលោកនៅទីក្រុងភ្នំពេញ? ហើយ

លេខឯកសារជាភាសាបារាំងគឺ 00763811។

[១០:៣៤:១៤]

**ឆ៖** ខ្ញុំមិនបានឆ្លើយប្រាប់ ចន ស្វេន ថា គេបណ្ដើរចេញទៅទីក្រុង -- ចេញប្រជាជនពីទីក្រុងភ្នំពេញនោះទេ។ អ្វីដែលគាត់សរសេរនោះ ក៏ប្រហែលជាពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលគេបានដកហូតអាវុធចេញពីទាហានរដ្ឋាភិបាល ហើយនៅពេលនោះឃើញមានទាហានបែបហ្នឹងនៅតាមផ្លូវមុនីវង្សមហាវិថីមុនីវង្ស និងមហាវិថីព្រះសីហនុ ហើយយើងឃើញមានគេប្រមូលផ្ដុំបណ្ដើរទៅពហុកីឡាដ្ឋានជាតិអូឡាំពិក។ ហើយខ្ញុំមិនបាននិយាយថា គេបណ្ដើរចេញពីទីក្រុងភ្នំពេញនោះទេ។

**ស៖** នៅពេលព្រឹកថ្ងៃនោះ តើលោកនៅចាំទេ ហើយលោកបានឃើញគេបណ្ដើរទាហាន លន់ នល់ចេញទៅតាមទិសខាងលិច តាមមហាវិថីព្រះសីហនុ និងព្រះមុនីវង្សដែរឬទេ?

**ឆ៖** ជាការពិត ហើយគឺថា ហើយទាហានដែលគេបណ្ដើរចេញមួយភាគបីនោះ គឺគេឲ្យលើកដៃឡើងលើ មិនមានខ្មែរក្រហមច្រើននាក់ ដើរអមជាមួយនឹងទាហានលន់ នល់ នៅពេលនោះទេ។

**ស៖** តើលោកចាំទេ ទាហានលន់ នល់ ប៉ុន្មានដែរដែលត្រូវបានគេបណ្ដើរទៅទិសខាងលិច?

**ឆ៖** ខ្ញុំគិតថាមិនងាយស្រួលស្មានចំនួននោះទេ នៅពេលដែលខ្ញុំដើរចំ ដើរទៅក្នុងកណ្ដាលហ្វូងនោះគឺថា ខ្ញុំបានឆ្លើយបញ្ជាក់ថា ខ្ញុំទៅពួននៅខាងស្ដាំឡាន ហើយបន្ទាប់មកខ្ញុំក៏នៅចូលក្នុងហ្វូងនោះដែរ គឺខ្ញុំមិនបានចូលក្នុងហ្វូងនោះអចិន្ត្រៃយ៍នោះទេ គឺខ្ញុំចេញចូលៗ ហើយពួននៅខាងស្ដាំឡាន។

[១០:៣៦:២៤]

**លោក ឌេល លីសាក់៖**

លោកប្រធាន គឺនៅពេលនេះ ខ្ញុំសូមបង្ហាញរូបថតមួយចំនួនទៀតនៅក្នុងសៀវភៅនេះ ឯកសារនេះ គឺD313/1.2.11។ រូបថតនេះគឺនៅត្រង់លេខ ERN 00432469 និង 00432470។ យើងខ្ញុំអាចបង្ហាញរូបថតនេះនៅលើអេក្រង់ ហើយយើងអនុញ្ញាតផ្ដល់ឯកសារជាក្រដាសជូនទៅដល់សាក្សីផងដែរលោកប្រធាន។ សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ប្រសិនបើលោកអាចមើលរូបថតទាំងពីរនេះ គឺថាខ្ញុំសូមសួរលោក លោកស្គាល់ទេ

ហេតុការណ៍ហ្នឹង ហេតុការណ៍អ្វីដែរ? ហើយទីតាំងថតហ្នឹងនៅកន្លែងណាដែររូបថតទាំងពីរនេះ?

**លោក អាល់ រ៉ុក្ហូ៖**

**ឆ៖** ខ្ញុំច្បាស់ណាស់ គឺក្រុមទាហានដដែលទេ ដែលខ្ញុំបានមកថតពីមុនដែរ។ ក្រុមទាហានទាំងអស់នេះ គឺញញឹម សើចនៅពេលដែលខ្ញុំដើរជាមួយពួកគាត់។ ក៏ប៉ុន្តែ ហើយខ្ញុំច្បាស់ថា នៅកែងផ្លូវមហាវិថីមុនីវង្ស និងព្រះសីហនុ។

**ស៖** តើលោកចាំទេនៅថ្ងៃតែមួយដែលលោកនៅទីតាំងដែលលោកបានបញ្ជាក់អម្បាញ់មិញនោះ ឬក៏យ៉ាងម៉េច? សូមឲ្យលោកបញ្ជាក់ថតនៅពេលណាដែរ? ហើយថតនៅកន្លែងតែមួយដូចដែលលោកបញ្ជាក់នៅពេលមុន ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនបានពាក់នាឡិកាមើលបញ្ជាក់ពេលច្បាស់លាស់នោះ ប្រហែលជានៅពេល បានន័យថានៅជិតថ្ងៃត្រង់ហើយ នៅកែងមហាវិថីព្រះមុនីវង្សនិងមហាវិថីព្រះសីហនុ។ ខ្ញុំបានទៅទីនោះប្រហែលជានៅទីនោះមួយម៉ោង ខ្ញុំមិនដឹងថាបុគ្គលម្នាក់ទៀតឈ្មោះ ឡូរ៉ង់ នោះទៅរសៀលថ្ងៃ១៧ មេសា គាត់បានទៅម្តងទៀត ឬក៏យ៉ាងណានោះឡើយ។

[១០:៣៩:០០]

**ស៖** ប្រសិនបើលោកមើលរូបថតទី២ សូមអនុញ្ញាតបញ្ចាំងនៅលើអេក្រង់ គឺត្រង់ទំព័រ៨០ លេខ ERN គឺ00432470 តើលោកចាំទេទីតាំងហ្នឹង មុំណាដែរ?

**ឆ៖** ខ្ញុំមិនច្បាស់ទេ មិនច្បាស់ថានៅផ្លូវកែងមហាវិធីព្រះមុនីវង្ស ឬព្រះសីហនុនោះទេ។

**ស៖** តាមការចងចាំរបស់លោក តើរូបថតនេះ គឺបង្ហាញអំពីទិដ្ឋភាពជាក់ស្តែងនៅពេលដែលលោកថតនៅពេលនោះដែរឬទេ ដែលថាទាហានរដ្ឋាភិបាល លន់ នល់ ត្រូវបានខ្មែរក្រហមបណ្តើរចេញទៅនោះ?

**ឆ៖** រូបថតនេះបង្ហាញទិដ្ឋភាពជាក់ស្តែងតែម្តងនៅថ្ងៃនោះ ហើយ ឡូរ៉ង់ នុំងក៏បានថតដែរ ហើយថតអំពីការធ្វើដំណើររបស់អ្នកទោសដែលគេបណ្តើរចេញទៅ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន យើងខ្ញុំប្រហែលជាចូលទៅដល់ប្រធានបទមួយទៀតដែលចំណាយពេលប្រហែលជាមួយព្រឹកនេះ ដូច្នេះតើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្ត ឬសម្រាកពេលព្រឹក?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០ នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០ នាទី ដល់ម៉ោង ១១:០៣ នាទី)*

[១១:០៣:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ មុនខ្ញុំចាប់ផ្ដើមសួរសំណួរ មុនពេលដែលយើងចាប់ផ្ដើមព្រឹកនេះគឺក្រឡាបញ្ជីបានស្នើសុំថា លោក -- ថារូបថតខ្លះរបស់លោក រ៉ុក្ហូ នៅទីក្រុងបានខូចហើយ ហើយសូមទាក់ទងទៅនឹង ឌី.ស៊ី.ខេម ថាតើមានរូបថតអ្វីដែរទេ? ហើយយើងបានស្នើសុំ។ ហើយជាឯកសារអេឡិចត្រូនិច ហើយបានទទួលបាន។ ខ្ញុំមិនទាន់បានមើល ដើម្បីថាតើរូបថត រូបថតផ្សេងទៀតមាននៅក្នុងសំណុំរឿងដែរឬទេនោះទេ។ ប៉ុន្តែអ្វីដែលយើងចង់ជម្រាបជូននោះ គឺយើងនឹងជូនទៅអង្គជំនុំជម្រះ និងភាគីនូវឯកសារអេឡិចត្រូនិច ហើយនៅក្នុងពេលសម្រាកពិសាអាហារថ្ងៃត្រង់នេះ បើសិនជាវាមានភាពខុសគ្នានៅក្នុងរូបថតរបស់ រ៉ុក្ហូ នេះ យើងសូមជម្រាបតុលាការថា ខ្ញុំនឹងជម្រាបជូនដល់

ភាគីផងដែរ ឲ្យបានជ្រាបពីបញ្ហានេះ។ ខ្ញុំថានឹងប្រើរូបថតមួយចំនួននោះដែរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក រ៉ុក្ខហ្វ ទាក់ទងទៅនឹងសំណួរយើងចាប់ផ្ដើមឡើងវិញ លោកបាននិយាយថា នៅក្នុងអារម្មណ៍ស្ងប់ស្ងាត់ ដំបូងនោះស្ងប់ស្ងាត់ ហើយបន្ទាប់មកគឺវាមានការកែប្រែ ថាតើអំពីស្ថានភាពអាការៈ អារម្មណ៍របស់មនុស្សនៅពេលនោះ ថាតើវាមានការកែប្រែដូចម្ដេច តាមដែលលោកសង្កេតអង្កាល់នោះ?

**លោក អាល់ រ៉ុក្ខហ្វ៖**

**ឆ៖** នៅប្រហែលជាពាក់កណ្ដាលថ្ងៃ គឺថាមនុស្សចាប់ផ្ដើមចាកចេញទីក្រុង ហើយទៅ -- ហើយយើងដើរជុំវិញ ក៏ប៉ុន្តែ ហើយកម្មាភិបាលដែលមានមីក្រូ ហើយក៏បានប្រកាសថាត្រូវតែចេញពីទីក្រុង ពីព្រោះអាមេរិកាំងនឹងទម្លាក់គ្រាប់បែក។ ហើយអារម្មណ៍ ហើយនិងស្ថានភាពការកែប្រែនោះ គឺថាខ្ញុំផងដែរនៅទៅពេទ្យព្រះកេតុមាលា គឺថាមានក្រុមអ្នកកាសែតមួយចំនួន គឺថាខ្មែរក្រហមបាននាំយើងទៅកន្លែងមួយនោះផងដែរ។

[១១:០៦:៣០]

**ស៖** ហើយខ្ញុំនឹងសួរសំណួរនេះនៅពេលបន្តិចទៀត តើនៅពេលណាមួយ ថាតើមានការលួចឆក់ប្លន់របស់អីនៅក្នុងទីក្រុងទេ? ពួកខ្មែរក្រហមបានធ្វើបែបនោះដែរឬទេ?

**ឆ៖** ប្រសិនបើមានមែន គឺខ្ញុំមិនបានឃើញដោយផ្ទាល់ភ្នែកខ្លួនឯងទេ។

**ស៖** ផ្អែកអ្វីដែលលោកបានសង្កេតតើលោកបានឃើញ ថាតើខ្មែរក្រហមប៉ុនប៉ងដើម្បីការពារ ហើយនិងរក្សាផ្ទះសម្បែងក្រុមហ៊ុន ឬក៏ស្ថានទូតរបស់អាមេរិកនៅទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** ខ្ញុំមិនអាចនិយាយថា ខ្ញុំបានឃើញដោយខ្លួនឯងទេ ប៉ុន្តែហេតុការណ៍នោះគឺគេបានប្រាប់ខ្ញុំនៅពេលដែលខ្ញុំនៅស្ថានទូតបារាំង ដោយអ្នកថតរូប គ្រីស្តូ ម៉ារី ប្រូដា ជាអ្នកថត គាត់បានថតជាខ្សែភាពយន្តឯកសារ ហើយគាត់បានពិនិត្យមើលហើយឡើងវិញ ហើយដោយសារព័ត៌មានអាសូស៊ីអេតធីតប្រេស។ ហើយយើងបានឃើញរូបថតខ្មែរក្រហម កម្មាភិបាលគឺថា ដើរមានអាវុធនៅក្នុងដៃ គ្រីស្តូហ្វ បាននិយាយថា វាគឺជា គាត់ព្យាយាមឲ្យមនុស្សចេញ។ ខ្មែរក្រហមគឺថា ប្រាប់ថា មិនឲ្យចូលទៅក្នុងហាងលក់ទេ។ ប៉ុន្តែមិនបានឃើញថាបាញ់មនុស្សនោះទេ។ ហើយគាត់បាន គ្រីស្តូហ្វ គាត់បានថតរូបថតមួយដែលថាគេបានបោះពុម្ពផ្សាយច្រើនបន្ទាប់ពីក្រោយមក និយាយពីសៀវភៅ "ការដួលរលំនៃ

ភ្នំពេញ"។ ប៉ុន្តែខ្ញុំមិនបានឃើញការលួចឆក់ប្លន់ដោយខ្លួនឯងទេ។

[១១:០៨:២៥]

**ស៖** ខ្ញុំចង់និយាយអំពីព្រះកេតុមាលាជាមន្ទីរពេទ្យនោះ ដែលលោកបាននិយាយខាងដើម តើលោកអាចជម្រាបប្រាប់ខ្ញុំបានទេ ប្រហែលថាជាម៉ោងប៉ុន្មានដែលលោកបានទៅដល់ទីនោះ? ហេតុអ្វីបានជាលោកសម្រេចចិត្តទៅកន្លែងមន្ទីរពេទ្យនោះ?

**ឆ៖** ខ្ញុំមិនប្រាកដពីពេលវេលាទេ ខ្ញុំមិនបានពាក់នាឡិកាដៃ ហើយខ្ញុំក៏មិនសូវបានកត់ត្រាពីពេលវេលាម៉ោងទេ ព្យាយាមថតតែរូបតែប៉ុណ្ណឹង។ អ្វីដែលខ្ញុំទៅដល់មន្ទីរពេទ្យ គឺថាខ្ញុំបានទៅឆាប់ ខ្ញុំចេញពីត្រឡែងកែងមុនីវង្ស ព្រះសីហនុ *វ៉ាយពូហ្សូ* នោះគឺថា ឡានប៉ឺហ្សូពណ៌សក៏បានឈប់ ហើយគាត់ថាគាត់ទៅធ្វើការនៅព្រះកេតុមាលា គាត់មានឯកសណ្ឋាន។ ហើយម្នាក់ៗគឺមានអារម្មណ៍ភ័យខ្លាច គឺថាដោយសារតែខ្ញុំជាអាមេរិកាំងជិះឡាននោះ ហើយគាត់ប្រាប់ថាខ្មែរក្រហមកំពុងតែបណ្តេញមនុស្សចេញពីមន្ទីរពេទ្យ ថាម្នាក់ៗត្រូវតែចេញ។ ហើយខ្ញុំបានចុះនៅវ៉ូយ៉ាល់។ ហើយ ឌិន ប្រាន, ចន ស្វេន ក៏បានទៅជាមួយ ឌិត ប្រាន ទៅមន្ទីរពេទ្យ។ យើងចូលទៅអគារមួយ យើងឃើញសាកសពនៅលើកម្រាល ហើយឃើញមាន ហើយមានឈាមនៅគ្រប់ទីកន្លែង ហើយឈាមនៅសើមនៅឡើយ។ ហើយមានអ្នករបួស ហើយមានកម្មាភិបាលខ្មែរក្រហម ហើយមានរថយន្ត ហើយឃើញ ហើយ យើងខ្ញុំបានថតរូបនៅពេលដែលចូលទៅដល់នុ៎ងគឺថា វេជ្ជបណ្ឌិតបារាំងកំពុងតែធ្វើការនៅទីនោះ។

[១១:១០:០០]

នៅក្នុងអគារនេះគឺខ្មែរក្រហមចូលមកខាងមុខមន្ទីរពេទ្យហ្នឹង ឃើញ។ ៥នាទីក្រោយមក គឺថាមានស្ថានភាពតឹងតែងណាស់ ពួកគេបានសុំឱ្យ ឌិត ប្រាន សួរសំណួរ ខ្ញុំមិនស្តាប់ភាសាខ្មែរទេមិនដឹងថាគេសួរអី គេគំរាមអី គឺគេថា គេគំរាមថាឱ្យគាត់ចេញពីកន្លែងហ្នឹង ហើយខ្មែរក្រហមមានកាំភ្លើងខ្លីភ្ជង់ក្បាលខ្ញុំ ពីរនាក់នៅខាងក្រោយខ្ញុំ គឺកាន់តែចូលមកជិតខ្ញុំ។ ដូច្នេះខ្ញុំក៏ភ័យ ហើយបន្ទាប់មកយើងនឹងចូលទៅដល់រថពាសដែកមួយ ដែលជារថពាសដែកអតីតរបស់ខាង លន់ នល់ ទេ ប៉ុន្តែខ្មែរក្រហមយកមកប្រើ គឺថាអ្នកបើកបរនៅក្នុងនោះនៅឡើយ។

គេដាក់យើង អេ.ភី.ស៊ី ហើយពិបាកនឹងមើលណាស់ ពីព្រោះថាគេបិទគម្របខាងលើ យើងមើលអ្វីសងខាងមិនឃើញទេ។ ប្រហែលជាមួយគីឡូ ហើយឈប់មួយគីឡូម៉ែត្រ ហើយគឺឃើញមន្ត្រីមួយចំនួនគឺថាមានការភ័យ ហើយគេយកមន្ត្រីទាំងអស់នោះទៅឱ្យដាក់នៅអង្គុយនៅបង់មួយ ហើយពួក

គេមានការភ័យខ្លាចខ្លាំងណាស់។ ហើយយើងបានជិះប្រហែលជា២-៣មីនុតទៅទៀតនេះគឺថារថពាសដែកនោះបានឈប់។ ប្រហែលជាគេត្រឡប់ ប្រហែលជាមុំ៩០ដឺក្រេ ឬក៏អាចត្រឡប់ទៅក្រោយ ហើយគឺគេបើកខាងក្បាលខាងលើ គឺថា គឺយើងឃើញពន្លឺ ហើយយើងឃើញទន្លេ។ គេប្រាប់យើង គឺថាឲ្យយើងនៅ -- យើងមើលទៅឃើញស្ពានមិត្តភាពខ្មែរ-ជប៉ុន គឺស្ពានជ្រោយចង្វានេះឯង។

[១១:១២:០៥]

អ្វីដែលកើតឡើងនោះគឺថា បន្ទាប់មកយើងចុះកន្លែងហ្នឹង គឺចំពោះមន្ត្រីផ្សេងទៀត ដែលនៅក្នុងនោះដែរ គឺយើងមិនដឹងថាជោកវាសនាយ៉ាងម៉េចទេក្រោយមកនោះ។ ហើយប្រហែលជាពិបាកនឹងគឺថាយើងអាចនឹងពិបាកនឹងកត់ត្រាឲ្យជាក់លាក់ តាមដានឲ្យជាក់លាក់ណាស់ ពីព្រោះសភាពការណ៍វាតានតឹង គឺថាមួយរយៈកាលក្រោយមក ឃើញថា គឺមនុស្សជាច្រើនក៏បានចាកចេញ ហើយគេក៏បាននិយាយប្រហែលជា១ម៉ោងក្រោយពីការឃុំខ្លួននោះ គឺគេបញ្ជូនយើងទៅក្រសួងព័ត៌មាន គេដឹកឡានយើងទៅទីនោះ ជាឡានធំ។

**ស៖** សូមលោកឈប់បន្តិច ហើយយើងមុននឹងចូលទៅដល់ក្រសួងព័ត៌មាន ឥឡូវនេះសូមឲ្យលោកត្រឡប់ទៅបញ្ជាពីហេតុការណ៍មួយចំនួនដែលគេចាប់លោកចេញពីមន្ទីរពេទ្យនោះទៅនោះ។ ជាបឋមតើលោករៀបរាប់ប្រាប់ខ្ញុំបានទេ អំពីមនុស្សដែលឃុំខ្លួនលោក ហើយក៏ដាក់ចូលលោកទៅក្នុងរថពាសដែក ហើយដឹកជញ្ជូនលោកដូចដែលលោករៀបរាប់ លោកអាចជម្រាបបន្ថែមបានទេបាទ?

[១១:១៣:២២]

**ឆ៖** គឺពួកខ្មែរក្រហម។

**ស៖** តើខ្មែរក្រហមប៉ុន្មាននាក់នៅពេលនោះនៅក្នុងរថពាសដែក?

**ឆ៖** ប្រហែលជានៅក្បែរៗយើងខ្ញុំហ្នឹងគឺថា ប្រហែលជាប្រាំមួយប្រាំពីរនាក់ គឺយើងយកពីទ្វារមុខគឺថា ទៅដាក់រថពាសដែកនោះគឺមានខ្មែរក្រហមនៅខាងមុខខ្លោងទ្វារកន្លែងយើងចេញមកនោះដែរ។ ប៉ុន្តែខ្ញុំមិនដឹងថាមានប៉ុន្មាននាក់។ ប៉ុន្តែប្រហែលជាប្រាំមួយ ឬប្រាំពីរនាក់ដែលនៅក្នុងរថពាសដែកជាមួយយើងនោះ។

**ស៖** នៅមន្ទីរពេទ្យនោះ ថាតើក្រុមមនុស្សនោះជាអ្នកណាដែលៗខ្មែរក្រហមយកចាប់ខ្លួនទៅជាមួយលោកនោះមានអ្នកណាខ្លះ?

**ឆ៖** មានខ្ញុំមួយ មាន ស៊ីដនី សាន់ប៊ឺដ, ឌិត ប្រាន ដែលធ្វើឲ្យ ស៊ីដនី សាន់ប៊ឺដ និង ចន ស្វេន

មួយទៀត ហើយនិងអ្នកបើកបរមួយទៀតផងដែរបាទ គឺជាអ្នកបើកបររបស់ស៊ីដនី។ ហើយខ្ញុំជឿថា ឈ្មោះគាត់ សារុន អ្នកបើកបរហ្នឹង។

[១១:១៤:៤៣]

**សះ** នៅពេលដែលគេឃុំខ្លួនលោកដំបូងនោះ តើខ្មែរក្រហមចង់យកលោកទាំងបួននាក់ហ្នឹង ឬក៏គេចាប់អារម្មណ៍អ្នកណាម្នាក់ក្នុងក្រុមហ្នឹងទេ ឬក៏គេចង់យកទាំងបួនហ្នឹង?

**ផះ** ប្រហែលជាគេចង់បាន ឌិត ប្រាន ហើយគាត់ប្រាប់ថាយើងជាអ្នកកាសែតបារាំងទេ ដើម្បីយកព័ត៌មានពីការជោគជ័យ ហើយទាល់តែ១អាទិត្យក្រោយមកទើបយើងដឹងថា គេចង់ឲ្យពួកអាមេរិកាំងបំបែកចេញពីជនជាតិផ្សេងៗទៀត ហើយជាពិសេសយើងទៅដល់ស្ពានជ្រោយចង្វានោះ យើងនៅជាមួយគ្នានៅឡើយទេ គេមិនទាន់បែងចែកថាអ្នកណាបារាំង-អាមេរិកាំងនៅឡើយទេ។

**សះ** ខ្ញុំចង់យោងទៅរកសេចក្តីស្រង់អំពីអត្ថបទរបស់ ចន ស្វេន ដែលនិយាយឯកសារ E3/51 ទំព័រយោងនោះ គឺថាអង់គ្លេស S00003278, ខ្មែរ S00644706 រហូតទៅដល់ 644707, បារាំង 00597834។ នៅក្នុងអត្ថបទរបស់ ចន ស្វេន នេះ គាត់និយាយថា គាត់បាននិយាយដូចខាងក្រោមនេះ សូមដកស្រង់ "លោក ប្រាន បានពន្យល់ថាខ្មែរក្រហមបានប្រាប់គាត់ថា គាត់មានសេរីភាពនឹងទៅបាន ប៉ុន្តែបន្ទាប់ពីអ្នកមាន ហើយនិងពួកគហបតីប៉ុណ្ណោះ"។ សូមបញ្ចប់ដកស្រង់។ តើខ្លឹមសារនេះធ្វើឲ្យនៅចងចាំ នឹកឃើញឡើងវិញទេអំពីការពន្យល់របស់ ឌិត ប្រាន នោះទេ? អំពីមូលហេតុដែលខ្មែរក្រហមយកលោកទាំងប៉ុន្មាននាក់ដើម្បីទៅឃុំខ្លួននោះ?

[១១:១៧:០០]

**ផះ** គេមិនដែលពន្យល់ខ្ញុំទេ អំពីមូលហេតុដែលគេចាប់យើងនោះទេ។ ប៉ុន្តែខ្ញុំយល់ច្បាស់ដោយខ្លួនឯងហើយថា មូលហេតុអីនោះ។

**សះ** លោកបាននិយាយថា ខ្មែរក្រហមម្នាក់បានមានអាវុធភ្ជង់លោកនោះ តើគេភ្ជង់នឹងអាវុធអ្វីដែរ?

**ផះ** បាទ ជាអាវុធមួយតូច ចុងកាណុងតូចទេ គឺបើមើលទៅនោះ។ ជាអាវុធ រ៉ឺវុលវែរ មិនមែនជាអាវុធកាំភ្លើងដៃខ្លីរបស់ទាហានទេ ជាអាវុធ រ៉ឺវុលវែរ ទេ។

**សះ** គេភ្ជង់លោកនោះចម្ងាយប៉ុនណា?

**ផះ** បាទ ប្រហែលជាបីហ្វីតពីខ្ញុំទេ គឺថា ហើយគេឈោងដៃភ្ជង់មកទៀតនោះ អាវុធក្បែរខ្ញុំ

កៀកមែនទែន។

**ស៖** តើខ្មែរក្រហម ទាហានខ្មែរក្រហមនោះឃុំខ្លួនលោក ហើយដឹកលោកនោះ គឺគេមេបញ្ជាការគេដែរឬទេ?

**ឆ៖** ខ្ញុំមិនអាចបញ្ជាក់ថាអ្នកណាម្នាក់ជាបញ្ជាការទេ ប៉ុន្តែមានអ្នកខ្លះដែលធ្វើសេចក្ដីសម្រេចដែលត្រូវយកយើងទៅដាក់នៅក្នុងយានយន្តនោះ ហើយបញ្ជូនយើងទៅជិតស្ពាន ហើយបន្ទាប់មកគេបញ្ជូន យើងទៅក្រសួងព័ត៌មាន ប្រាកដជាមានអ្នកណាម្នាក់ជាអ្នកបញ្ជា ហើយនិងប្រាស្រ័យទាក់ទងឲ្យធ្វើការ ដឹកយើងតាមដំណើរហ្នឹង ក្នុងលក្ខណៈឃុំខ្លួនហ្នឹងហើយ។

[១១:១៩:០៤]

**ស៖** នៅពេលដែលឃុំខ្លួនលោកដោយដឹកផងអីផងបែបនេះ តើគេបានសួរសំណួរអ្វីទេ ពីលោក ឬក៏ពីសមាជិកដូចជាលោក ស្វេន ឬក៏លោក សាន់ប៊ឹជ ជាពិសេសពួកខ្មែរក្រហមនោះ បានសួរសំណួរដេញដោលអ្វីពួកលោកទេ?

**ឆ៖** ក៏មិនមានការសួរតឹងតែងទេ គឺយើងមានការសន្ទនារវាង ឌិត ប្រាន ហើយនិងខ្មែរក្រហម ខ្ញុំមិនអាចយល់បានថាគេពិភាក្សាអ្វីទេ។ ស៊ីដនី និយាយថាគាត់ប្រាប់យើងទាំងអស់គ្នាជាអ្នកកាសែតបារាំងដើម្បីយកព័ត៌មានពីរឿងជោគជ័យនេះទេ គឺថាយើងមានការមិនសប្បាយចិត្ត ហើយនិងខកចិត្តណាស់ពេលដែលគេនិយាយថា "អ្នកឯងកុំនិយាយភាសាអង់គ្លេស" គឺថាបន្ទាប់មក យើងមកដល់១ម៉ោងមកដល់ស្ពានហ្នឹង គឺថាវាមានការសួរសំណួរ -- សួរចម្លើយអ្វីទេ ហើយយើងនៅទីនោះគឺ -- ហើយគេពិនិត្យមើលកាបូបរបស់យើងមានអ្វីខ្លះ? តើកាបូបស៊ីដនីមានអ្វីខ្លះ? នៅក្នុងកាបូបខ្ញុំ ហើយខ្មែរក្រហមលើកក្រដាស១០០ដុល្លារចេញមក គឺ -- ហើយដកមកវិញ គឺថាឃើញមានខោទ្រនាប់អ្វីជាដើម គឺថាលុយពេលនោះ គឺមិនមានតម្លៃអីសម្រាប់ពួកគេទេពេលនោះ ពួកគឺគេដាក់ឲ្យមកក្នុងមកវិញ ហើយគេបន្ទាប់មកគេឲ្យកាមេរ៉ាមកខ្ញុំវិញ ហើយគេប្រាប់ឲ្យយើងឡើងៗរថយន្តធំតទៅទៀត។ ជាសំណាងល្អណាស់កាលនោះ គេមិនត្រឡប់មកខ្ញុំម្ដងទៀតទេ បើសិនជាគេមកសួរខ្ញុំដេញដោលគឺថាខ្ញុំប្រាកដជាចប់នៅពេលនោះ។

[១១:២១:០៧]

**ស៖** តើលោកនៅចាំដែរឬទេ ថាតើខ្មែរក្រហមដែលយកលោកទៅឃុំខ្លួន ថាតើពួកគេប៉ុនប៉ងនឹងបែងចែករកពួកអាមេរិកាំងថាក្នុងចំណោមហ្នឹងមានអាមេរិកាំងដែរឬទេ? តើគេធ្លាប់ថាអ៊ីចឹងដែរឬទេ?

**ឆ៖** ប្រសិនបើគេសួរសំណួរ ឌិត ប្រាន នោះបែបគេសួរមិនដឹង ប៉ុន្តែខ្ញុំមិនដឹងទេ ពីព្រោះថាខ្ញុំមិនចេះខ្មែរ ហើយពួកគេមិននិយាយភាសាអង់គ្លេសទេ។ ដូច្នេះ ខ្ញុំមិនអាចដឹងច្បាស់បាន។

**ស៖** លោកបាននិយាយថា បន្ទាប់ពីគេដាក់លោកទៅក្នុងរថពាសដែកនោះ ហើយៗមានអ្នកផ្សេងទៀត គឺថាម្នាក់នោះមកពីកងនាវា។ តើនៅពេលណាដែលគេយកមកដាក់នៅក្នុងការឃុំខ្លួនជាមួយលោកនោះ?

**ឆ៖** នៅពេលដែលចាកចេញពីព្រះកេតុមាលាមក គឺថារថពាសដែកនោះ គឺថាបានចាកចេញ។ ខ្ញុំមិនដឹងទៅកន្លែងណាជាក់លាក់ទេ ពីព្រោះគេបិទអាដំបូលខាងលើ យើងមិនអាចមើលឃើញអ្វីទេ។ ប្រហែលថា ៥នាទីក្រោយពីចេញពីមន្ទីរពេទ្យមក គឺថាគឺមន្ត្រីនាវាម្នាក់ខាងកងទ័ពនាវាម្នាក់ត្រូវបានគេដាក់បញ្ចូលមកនោះ ខាងទ័ពជើងទឹកបាទ។ ហើយគេបានឆែកឆេរគាត់ គេយកអត្តសញ្ញាណគាត់ ហើយនិងយកកាបូបដៃ ហើយបោះចោលមិនឲ្យគាត់បានមកវិញទេ។

[១១:២២:៤៩]

**ស៖** តើលោកដឹងថា គាត់ហ្នឹងជាកងមន្ត្រីជើងទឹកហ្នឹងដោយរបៀបណា?

**ឆ៖** ពីព្រោះគាត់មិនបានដោះឯកសណ្ឋានជាកងទ័ពរបស់គាត់ទេថ្ងៃនោះ។

**ស៖** លោកបានរៀបរាប់អំពីពេលដែលថាគេដឹកលោកទៅមាត់ទន្លេនោះ មុខមាត់ទន្លេយើងនេះ តើកងទ័ពខ្មែរក្រហមនោះបានជួបលោកទេ នៅពេលដែលៗលោកទៅដល់មាត់ទន្លេក្បែរស្ពានជ្រោយចង្វានោះ ដែលថាស្ពានមិត្តភាពខ្មែរ-ជប៉ុននោះ?

**ឆ៖** បាទ ខ្ញុំមិនអាចប្រាប់ពីចំនួនច្បាស់លាស់ទេ ប៉ុន្តែមានខ្មែរក្រហមមួយចំនួននៅតាមបណ្តោយមាត់ទន្លេនោះ គឺថាភាគីច្រើនសុទ្ធតែខ្មែរក្រហមនោះឯង។ ខ្ញុំអាចនិយាយ គឺថាប្រហែលជាៗមានដល់២ពាន់ជាងឯណោះ នៅក្នុងតំបន់ជុំវិញនៅទីនោះ។

**ស៖** លោក រ៉ុក្កូហ្វ ប្រហែលជាពេលហ្នឹងយូរហើយកន្លងមក។ ដូនេះ ខ្ញុំចង់ដកស្រង់អត្ថបទរបស់ ចន ស្វេន ដើម្បីឲ្យលោកអាចឆ្លើយខ្ញុំបានដែរឬទេ?

**លោក ខេល លីសាក់៖**

លោកប្រធាន នេះជាឯកសារ E3/51 ហើយទំព័រនោះ អង់គ្លេស S0003278, ខ្មែរ S006 44707, ហើយនិងបារាំង 00597834។ នេះគឺជាឯកសារនិយាយពីពេលវេលា ដែលៗអ្នកទោសជាទាហានជើងទឹកហ្នឹងត្រូវបានដាក់បន្ថែមចូលទៅក្នុងរថពាសដែកជាមួយលោកនោះ។ សូមដកស្រង់

[១១:២៥:០៩]

"យើងបានជិះនៅតាមផ្លូវ ហើយឈប់តាមផ្លូវ ហើយគេដាក់អ្នកទោសពីរដែលថាជាជនស៊ីវិលម្នាក់ គឺថាមានពុកមាត់ គឺថាពាក់អាវស ហើយខោកាប៊ីយ។ បុរសតូចនោះ គឺថាស្លៀកពាក់គឺថា មានអាវ ហើយទាំងពីរជាមន្ត្រី ហើយមានអារម្មណ៍ភ័យខ្លាចណាស់តាមដែលយើងសង្កេត។ បុរសមាឌធំនោះ យើងស្គាល់ថា គឺជាកងមេបញ្ជាការទី២នៅក្នុងកងទ័ពជើងទឹក"។ ខ្ញុំសួរលោកថាតើលោកនៅចងចាំនឹកឃើញទេ ក្រោយពីស្តាប់ខ្លឹមសារដែលខ្ញុំអាន តើលោកនៅ -- បញ្ហានេះ លោកនឹកឃើញទេ តើឲ្យលោកចងចាំទាក់ទងទៅនឹងចំនួនមនុស្ស មន្ត្រី លន់ នល់ ដែលគេយកមកដាក់រថពាសដែករបស់លោកដែលលោកគេឃុំខ្លួននោះ ថាតើលោកនឹកឃើញទេពីបញ្ហានោះ?

**ឆ៖** ខ្ញុំចាំមន្ត្រីមួយដែលថាគេដកកាបូបលុយពីគាត់ ខ្ញុំមិនសូវច្បាស់នោះគឺថា ខ្ញុំចាប់អារម្មណ៍តែម្នាក់ដែលអង្គុយទាល់មុខខ្ញុំហ្នឹង។ គាត់មើលទៅគឺថា គាត់ជាកងទ័ព ពីព្រោះថា គាត់មិនមានឯកសណ្ឋានទាំងស្រុងទេ ប៉ុន្តែឯកសណ្ឋានដែលជាប់ជាមួយហ្នឹង គឺជាទោះបីជាអាវយឺតក៏ដោយ ក៏ជារបៀបទាហាន។ ខ្ញុំមិនដឹងថា ឋានៈខ្ពស់យ៉ាងណានោះទេ។ ខ្ញុំមិនដឹងថា តើ ឱន ប្រាន ហ្នឹងបានស្គាល់គាត់ច្បាស់ មិនច្បាស់ទេ។ ប៉ុន្តែគេដកប័ណ្ណរបស់គាត់ ប៉ុន្តែប័ណ្ណនោះប្រហែលជា ខ្ញុំមិនបានឃើញមិនដឹងសរសេរភាសាខ្មែរក៏មិនដឹង។

[១១:២៧:០៧]

**ស៖** សូមអរគុណដែលលោកបានឆ្លើយ។ ហើយលោកបានឆ្លើយបញ្ជាក់ថា នៅពេលដែលគេឃុំខ្លួនលោក ហើយបានទៅដល់ក្បែរ នៅក្បែរស្ពានជ្រោយចង្វានោះ ហើយលោកបានឃើញមនុស្សជាច្រើនបានចាកចេញពីទីក្រុង។ តើលោកអាចសង្កេតឃើញទេនៅកាលណោះ នៅពេលណាមួយ នៅពេលថ្ងៃ ថាតើខ្មែរក្រហមមានប្រើកម្លាំង ឬក៏ការគំរាមកំហែងដើម្បីធានាថា ឬក៏ការបង្ខំឲ្យប្រជាជនចេញពីទីក្រុងដែរឬទេ?

**ឆ៖** ខ្ញុំមិនបានឃើញគេប្រើកម្លាំងអ្វីបង្ខំឲ្យចេញពីទីក្រុងនោះទេ កាលណោះ។

**ស៖** តើលោកបានឮពីអ្នកណាទេ ថាតើខ្មែរក្រហមបានប្រើកម្លាំងដើម្បីជម្លៀសទីក្រុងភ្នំពេញនោះ?

**ឆ៖** ខ្ញុំបានស្តាប់សម្តីរបស់មនុស្សមួយចំនួន ថានៅល្ងាចនោះគឺថា -- ហើយគេបានឆ្លើយភ្ជាប់ទៅនឹងជនបរទេសមួយចំនួនដែលថាទៅលាក់ខ្លួននៅស្ថានបារាំង នៅថ្ងៃទី១៧ ខែមេសា ជាពិសេសគឺថា

មុនថ្ងៃនោះទេ គឺថាមានមនុស្សមួយចំនួនដែលបានចូលទៅដល់ទីនោះ។ ជាកត់សម្គាល់ហ្នឹងគឺថា ពួកប៉ាគីស្ថានដែលនៅទីនេះ ដែលបានដើរទៅតាមផ្លូវជាតិលេខ៥ ហើយពីរបីថ្ងៃក្រោយមក គេបញ្ជូនមកវិញ មកភ្នំពេញ ហើយគេបញ្ជូលមកទូតបារាំង។ គេបានឃើញថា គេបណ្ដេញចេញ ពេលខ្លះគេសម្លាប់អ្នកហ្នឹងនៅតាមផ្លូវ ហើយគេបំបែកបុរសចេញពីស្ត្រី។ នេះគឺជាសាក្សីដែលបានឃើញផ្ទាល់ភ្នែកបាននិយាយបែបនេះ។ ប៉ុន្តែនៅថ្ងៃទី១៧ ខែមេសា គឺខ្ញុំមិនបានឃើញផ្ទាល់ភ្នែកនៅភ្នំពេញនេះទេ។

[១១:២៩:២៧]

**ស៖** សូមអរគុណ។ ឥឡូវនេះ លោកបាននិយាយថា នៅចំណុចពេលមួយចំនួននោះ គេបានដោះលែង -- ខ្មែរក្រហមដោះលែងលោកចេញពីម្ដុំមាត់ទន្លេនៅជិតស្ពានជ្រោយចង្វាហ្នឹង។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់ទៅ នៅពេលដែលលោកចូលទៅដល់ក្រសួងព័ត៌មាននៅកាលនោះ។ ចំណុចទី១ដែលខ្ញុំចង់ដឹងតើលោកនៅនឹកឃើញដែរឬទេ នៅថ្ងៃនោះ ថាតើមានការផ្សាយតាមវិទ្យុដែរឬទេថា អំពាវនាវឲ្យមន្ត្រីរដ្ឋាភិបាល លន់ នល់ មកប្រមូលគ្នានៅក្រសួងព័ត៌មាននោះ?

**ឆ៖** គេបានប្រាប់ខ្ញុំនៅល្ងាចនោះថា យើងមានការប្រកាសបែបនោះ។ ខ្ញុំមិនបានដឹងមុនទេ។ អ្វីដែលយើងទៅដល់ស្ពានជប៉ុននោះ គឺថាយើងមិនបានដឹងទេ ប៉ុន្តែនៅពេលដែលយើងចេញពីរថយន្តហើយគេប្រាប់យើងថា គេយកទៅក្រសួង ហើយខ្ញុំអាចឃើញនៅខាងស្ដាំនេះអគារនោះប្រហែលជាមានមនុស្ស២៤នាក់ ឬក៏លើសពីហ្នឹងជាអតីតមន្ត្រីរបបចាស់ ហើយនៅទីនោះ នៅខាងស្ដាំមានខ្មែរក្រហមនៅខាងស្ដាំ។ ម្នាក់នៅក្នុងចំណោមមន្ត្រី លន់ នល់ នោះគឺពិភាក្សា គឺចង់ពន្យល់ពីមូលហេតុឲ្យខ្មែរក្រហមយល់ដើម្បី -- ហើយខ្មែរក្រហមបានមើល ហើយខ្មែរក្រហមម្នាក់បានថតរូបយើងចេញពីរថយន្ត ហើយគេ -- ហើយខ្ញុំមានកាមេរ៉ា ហើយគេថតខ្ញុំផងដែរ នៅពេលដែលខ្ញុំព្យាយាមថត គេឆក់យកកាមេរ៉ា ពីដៃខ្ញុំ គឺថា ហើយខ្ញុំទើបតែថតអំពីមន្ត្រីក្រសួងការបរទេស ហើយនិងក្រសួងរបស់ លន់ នល់ ហ្នឹង។

[១១:៣១:៣៩]

នៅពេលដែលខ្ញុំយកឧបករណ៍កាមេរ៉ា មក គឺថា ក្រោយមកគេប្រាប់ឲ្យយើងទៅស្ថានទូតបារាំងហើយពេលនោះ គេយកកាមេរ៉ាមកឲ្យខ្ញុំវិញមានហ្វីល មានអ្វីនៅក្នុងនោះផង ប៉ុន្តែ -- ហើយខ្ញុំអង្គាល់នោះភ័យ ខ្ញុំព្រួយក្រែងតែបាត់រូបថតនោះហើយ នៅពេលយើងនៅទីនោះប្រហែល១ជា៥ ឬក៏១០មីនុត។ ស៊ីដនី សាន់ប៊ឺជ ហើយនិង ឌិត ប្រាន បាននិយាយជាមួយមនុស្សមួយចំនួន។ ខ្ញុំមិនដឹងថា អ្នក

ណាខ្លះទេ។ ពេលនោះ ក៏មានឡានតូចមួយមក ហើយចូលមកដល់ ហើយក្រោយមកគឺយើងមកឃើញមានអតីតនាយករដ្ឋមន្ត្រី ឡុង បូរ៉េត ហើយប្រពន្ធរបស់គាត់ ហើយក៏ឃើញមានខ្មែរក្រហមមកជាមួយ ហើយគេភ្ជង់អាវុធទៅលើពួកគាត់ផង។ យើងមើលឃើញច្បាស់អ៊ីចឹង គឺថាអ្នកហ្នឹងគឺជាអ្នកទោសហើយ។ ស៊ីដនី សាន់ប៊ឺជ គឺថាបានចំណាយពេលបន្តិចចង់សួរ ហើយសុំថត ប៉ុន្តែគឺថា កុំឲ្យថាអ្វីដែលខ្ញុំមានរូបថតហ្នឹងគិតថា គឺជារូបថតដែលយើងដើរចូលឡាននោះទេ។ ១មីនុតក្រោយមកទៀត ហ្នឹងគឺថា ២មីនុត ក្រោយមកគឺថា ឡុង បូរ៉េត ហើយនិងប្រពន្ធគាត់ត្រូវបានគេដឹកចេញទៅ។ ហើយគេប្រាប់យើងឲ្យទៅស្ថានទូតបារាំង។ យើងត្រូវតែរាយការណ៍ជូនស្ថានទូតបារាំង ហើយនៅតាមផ្លូវទៅនោះ គឺថាមានអូតែលរ៉ូយ៉ាល់ យើងឈប់នៅទីនោះ ដើម្បីទទួលយក -- ដើម្បីឧបករណ៍សម្រាប់គ្រាអាសន្នខ្លួនខ្ញុំ។

[១១:៣៣:១៤]

**ស៖** សូមបញ្ជាប់លោកហើយ ឥឡូវនេះ ខ្ញុំត្រឡប់ទៅសួរលោកអំពីសំណួរមួយចំនួនអំពីពេលវេលាដែលលោកនៅក្រសួងការបរទេសដែលលោកបាននិយាយ។ បន្ទាប់មកយើងនឹងចូលទៅអ្វីដែលកើតឡើងនៅក្នុងអូតែលភ្នំបន្ទាប់ពីនោះមក។

**លោក ខេល លីសាក់៖**

ហើយអ្វីដែលខ្ញុំចង់សួរលោកប្រធាន នៅពេលនេះ ខ្ញុំសូមចាក់វីដេអូឃ្លីបមួយ ដែលបានផ្ដល់មកយើង -- យើងផ្ដល់ទៅឲ្យខាងប្រព័ន្ធសោតទស្សន៍ហើយ គឺជាឃ្លីបវីដេអូខ្លីមួយ អំពីនិយាយថា "ប៉ុលពត *ឃីលលីង អេមប្រេស*" ហ្នឹង D108/32.2R បាទ .188 -- បាទ 988 បាទ។ នៅក្នុងហ្សាយឡេបដែលបានគេហៅថា E3/32 -- បាទ 2355R ដោយអង្គជំនុំជម្រះសាលាដំបូង។ ហើយខ្សែភាពយន្តនេះ គឺថា D00172454 ហើយឃ្លីបនោះ នៅត្រង់គឺពីឯកសារដើម គឺ ២៥មីនុត ដល់ ២២សឺហ្គុង រហូតទៅដល់ ២៥សឺហ្គុង ហើយនិង២៦មីនុត និង៥សឺហ្គុង ជាឯកសារដើម។ នេះ គឺជាវីដេអូ ដែលសូមអនុញ្ញាតតុលាការ ដើម្បីបង្ហាញវីដេអូឃ្លីបដំបូងដោយមិនមានសំឡេង បន្ទាប់មក ហើយខ្ញុំសូមឲ្យបញ្ចាំងម្ដងទៀត ដោយមានសូមផ្អាក។ ដូច្នេះសូមអនុញ្ញាតដើម្បីបញ្ចាំងវីដេអូឲ្យលោកសាក្សីបានមើលសុំអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត!

អ្នកបច្ចេកទេសខាងសោតទស្សន៍ដាក់បញ្ចាំងនូវវីដេអូឃ្លីបលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា។

[១១:៣៥:៣០]

*(ការបង្ហាញឯកសារជាវីដេអូ)*

[១១:៣៦:២៤]

**លោក ឌេល លីសាក់៖**

នៅពេលនេះ គឺថាខ្ញុំនឹងឱ្យខាងសោតទស្សន៍ចាក់ឡើងវិញហើយឈប់ត្រង់ចំណុចមួយចំនួន។ រូបថតនេះ គឺវាមានលើកឡើងនៅក្នុងឯកសារមួយចំនួន តើលោកនៅចាំទេថា ចាំអំពីរូបថតខ្សែវីដេអូដែលបានចាក់ផ្សាយអំបាញមិញនេះដែរឬទេ?

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** ខ្ញុំចាំ។ ភាគច្រើនទៅ គឺជារូបថតដែលខ្ញុំបានថត។

**ស៖** ជាពិសេសតើលោកស្គាល់រូបថតចុងក្រោយដែលបានបញ្ចាំងក្នុងពេលដែលកាមេរ៉ាគេថតពីស្តាំទៅឆ្វេងនោះតើលោកចាំទេ?

**ឆ៖** ខ្ញុំចាំ គឺទីតាំងនៃក្រសួងព័ត៌មាន។ កាមេរ៉ានោះ គឺចាប់ផ្តើមថតពីខាងស្តាំទៅដល់ខាងឆ្វេងហើយឃើញខ្មែរក្រហម ហើយឃើញមានខ្មែរក្រហមថតរូបយើង បន្ទាប់មកខាងឆ្វេងយើងឃើញ មន្ត្រីរបប លន់ នល់ ហើយយើងឃើញមានបុគ្គលម្នាក់បញ្ចាក់តវ៉ាដែលគាត់ឡើងមកតវ៉ាជាមួយនឹងគេ។ នេះគឺជារូបថតនៅក្នុងផ្នែកនោះដែរ ដែលវាបង្ហាញអំពីទីតាំងហ្នឹង។ នេះគឺជារូបថតរបស់ខ្ញុំ។ ខ្ញុំចាត់ទុកថាវាជារូបថតប្រវត្តិសាស្ត្រដ៏សំខាន់មួយ គឺជានិន្នាការផ្លាស់ប្តូរមួយនៅក្នុងពេលនោះ។

**ស៖** ខ្ញុំសូមបញ្ជាក់ឱ្យបានច្បាស់លាស់តើរូបថតនោះហើយ ដែលលោកបានបញ្ជាក់ថាលោកបានថតនៅពេលដែលលោកនៅក្នុងក្រសួងព័ត៌មាននោះគឺអម្បាញ់មិញ ពីរបីនាទីនោះ គឺថាលោកបានបញ្ជាក់ថា លោកបានលើកកាមេរ៉ាថតហើយតែអត់ឱ្យគេកត់សម្គាល់ថា លោកបានលើកកាមេរ៉ាថតនោះទេ។ តើអ៊ីចឹងដែរឬទេ គឺជារូបថតហ្នឹងហើយ?

[១១:៣៨:៣៥]

**ឆ៖** គឺពិតជារូបថតហ្នឹងមែន។

**ស៖** លោកបាននិយាយថា ឡុង បូរ៉េត បានមកដល់ទីតាំងក្រសួងហ្នឹង តើលោកចាំទេ ចាំអ្នក

ផ្សេងមន្ត្រីរដ្ឋបាល លន់ នល់ ផ្សេងទៀត ដែលត្រូវបានគេប្រមូលផ្តុំនៅក្នុងទីតាំងក្រសួងព័ត៌មាននោះទៀត ដែរឬទេ?

**ផ៖** ខ្ញុំមិនស្គាល់ទេ។ ភាគច្រើនខ្ញុំហាក់ដូចជាស្គាល់។ ក្នុងនាមជាអ្នកកាសែតថតរូបនោះ គឺថាខ្ញុំមិនបានសរសេរប្រវត្តិអ្នកទាំងអស់នោះ ហើយក៏មិនស្គាល់បុគ្គលម្នាក់ជាក់លាក់នោះទេ។ បុគ្គលដែលខ្ញុំបានធ្លាប់ស្គាល់នោះ គឺបានរត់គេចពីប្រទេសនេះបាត់អស់ហើយ។

**ស៖** ដើម្បីឱ្យខ្ញុំយល់ហើយតាមការចងចាំតើលោកបានចងចាំដែរឬទេ ខ្ញុំសូមអានការដកស្រង់សម្តីមួយចំនួនចេញពីឯកសារខ្លះ។ ដំបូងខ្ញុំសូមសួរលោក លោកបានបញ្ជាក់ថា ស៊ីដនី សាន់ប៊ឺដ គឺគាត់ក៏នៅទីនោះដែរ តើលោក ស្វេន នៅមានវត្តមាននៅកន្លែងនោះដែរឬទេនៅក្នុងពេលនោះ?

[១១:៤០:០០]

**ផ៖** ជាការពិត ពាក់ព័ន្ធទៅនឹងក្រសួងព័ត៌មាន មានយើងមួយក្រុម ហើយគឺថាតាំងពីពេទ្យព្រះកេតុមាលា និងស្ពានមិត្តភាពជប៉ុន-កម្ពុជានោះមកដល់ក្រសួងព័ត៌មានគឺមួយក្រុមយើងតែម្តង។

**ស៖** ខ្ញុំសូមអានអត្ថបទមួយ ចេញមកពីសៀវភៅ -- ដំបូងចេញពីសៀវភៅ ចន ស្វេន គឺសៀវភៅកំណត់ហេតុរបស់គាត់ថ្ងៃ១៧ ខែមេសា។ ឯកសារ E3/51 អង់គ្លេសគឺត្រង់ទំព័រ S00003 278, ខ្មែរមានលេខ S00644709, បារាំងមានលេខ 00597835។ នៅក្នុងកំណត់ហេតុរបស់លោក ចន ស្វេន គាត់បានសរសេរថា នៅម៉ោងបួន ថ្ងៃ១៧ មេសា នោះ គឺសរសេរដូចតទៅ៖ "មាន៥០នាក់នៅឈរនៅខាងមុខក្រសួង -- អគារក្រសួង ហើយមាន លន់ ណុន ដែលជាបងរបស់ លន់ នល់ ឈរនៅទីនោះផងដែរ។ យើងឃើញមានឧត្តមសេនីយ៍មួយចំនួន និង ហង់ ស៊ិន ដែលជានាយខុទ្ទកាល័យរបស់ ឡុង បូរ៉េត ក៏នៅទីនោះផងដែរ"។ បញ្ចប់ការដកស្រង់សម្តី។

[១១:៤១:៣២]

ខ្ញុំសូមដកស្រង់អត្ថបទមួយទៀត ដែលសរសេរនៅក្នុងខែឧសភា ឆ្នាំ៧៥ សេរសេរដោយ ស៊ីដនី សាន់ប៊ឺដ និយាយថា "ទីក្រុងបានដួលរលំ"។ ឯកសារ D365/1.1.22 អង់គ្លេសត្រង់លេខ 00444 900, ខ្មែរមានលេខ 00656314, បារាំងមានលេខ 00664021។ ការដកស្រង់ចេញពីអត្ថបទរបស់លោក សាន់ប៊ឺដ នោះមានដូចតទៅ៖ "នៅពេលដែលយើងទៅដល់ ប្រហែលជាអ្នកទោស៥០ ឈរនៅខាងក្រៅអគារ។ នៅក្នុងនោះគឺមានលោក លន់ ណុន ប្អូនប្រុសពៅប្រធានាធិបតី លន់ នល់ ដែលបាននិរទេសខ្លួនបាត់ហើយ។ ហើយលោកឧត្តមសេនីយ៍ ជិម ឈួន ដែលជាមនុស្សជំនិតរបស់អតីតប្រធានា

ធិបតីផងដែរ។ ឧត្តមសេនីយ៍រដ្ឋមន្ត្រីដទៃទៅទីនោះដែរ ហើយកំពុងភ័យយ៉ាងខ្លាំង តែពួកគេព្យាយាមធ្វើហាក់ដូចជាគ្មានបញ្ហាអ្វី"។ បញ្ចប់ការដកស្រង់សម្ដីនេះ។ លោក រ៉ុក្ហូ តើការដកស្រង់សម្ដីត្រង់នេះឲ្យលោកចាំទេ ថានៅពេលនោះគឺមានរដ្ឋមន្ត្រី លន់ នល់ នោះក៏មានវត្តមាននៅក្នុងក្រសួងនោះផងដែរ នៅពេលដែលលោកនៅទីនោះ? តើលោកនៅចាំទេ?

**ឆ៖** គឺធ្វើឲ្យខ្ញុំចាំមែន។ ពាក់ព័ន្ធទៅនឹង លន់ ណុន ប្អូនប្រុសរបស់ លន់ នល់ នោះគឺគាត់មានវត្តមាននាពេលក្រោយមកតែប៉ុណ្ណោះ។ នៅពេលនោះ គឺខ្ញុំ មុនដំបូងខ្ញុំមិនចាំ មិនគិតថាគាត់នៅទីនោះទេ តែក្រោយមកបន្តិច គឺខ្ញុំគិតថាគាត់ឈរ មានវត្តមាននៅទីនោះ។

[១១:៤៣:៣៩]

**ស៖** ខ្ញុំសូមសួរលោកមួយសំណួរពីរសំណួរទៀត ពាក់ព័ន្ធទៅនឹងវត្តមានរបស់ខ្មែរក្រហម ទាហានខ្មែរក្រហមនៅក្នុងក្រសួងនោះ។ តើលោកនៅចាំទេ ទាហានខ្មែរក្រហមចំនួនប្រហែលជាប៉ុន្មាននាក់ដែរ ដែលនៅក្នុងក្រសួងនាពេលនោះ?

**ឆ៖** ប្រហែលជារាប់សិបនាក់ដែរនៅក្រៅអគារ ហើយខ្ញុំមិនដឹងថានៅក្នុងអគារ ឬក៏នៅជុំវិញនៅខាងក្រោយនោះប៉ុន្មាននាក់ដែរនោះទេ។

**ស៖** តើទាហាននោះមានអាវុធកាន់កាប់ដែរឬទេ?

**ឆ៖** មាន ក៏ប៉ុន្តែទាហានខ្មែរក្រហមភាគច្រើននោះ គឺថាមិនមានអាវុធវែងនោះទេ មានតែកាំភ្លើងខ្លីតែប៉ុណ្ណោះ។

**ស៖** តើលោកឃើញមានមេបញ្ជាការ ឬក៏មេដឹកនាំដែលបានមកនិយាយនៅក្រសួងព័ត៌មានពេលនោះ និយាយតំណាងឲ្យខ្មែរក្រហមដែរឬទេ?

[១១:៤៤:៤២]

**ឆ៖** នៅពេលនោះ នៅពេលដែលខ្ញុំថតរូបនោះ មន្ត្រីរបប លន់ នល់ បានពិភាក្សាគ្នា ហើយលើកឡើងបញ្ជាក់ចំណុចសង្កត់ធ្ងន់ចំណុចមួយចំនួន។ គឺមានចំណុចពីរដែលពាក់ព័ន្ធទៅនឹង ការនិយាយជជែកនៅពេលនោះ នៅពេលដែលមានវត្តមានអ្នកកាសែត ស៊ីដនី សាន់ប៊ឺជ នោះគឺថាមាន គាត់បានបញ្ជាក់ នៅពេលនោះគឺថាមានបុគ្គលម្នាក់ជនជាតិខ្មែរនោះ ដើរមកជិត ស៊ីដនី សាន់ប៊ឺជ ហើយបាននិយាយ ខ្ញុំមិនដឹងថាបាននិយាយអ្វីខ្លះនោះទេ?

**លោក ខេល លីសាក់៖**

លោកប្រធាន នៅពេលនេះគឺខ្ញុំសូមឲ្យចាក់ខ្សែវីដេអូឡើងវិញនោះ គឺវីដេអូដដែល ហើយនៅពេលនេះ គឺថាសុំឲ្យចាក់ ក៏ប៉ុន្តែខ្ញុំនឹងឲ្យអង្គភាពសោតទស្សន៍នោះឈប់ត្រង់នាទី ៣២:០០ គឺខ្ញុំស្នើសុំឲ្យធ្វើការចាក់ខ្សែវីដេអូនេះឡើងវិញ ក៏ប៉ុន្តែឲ្យឈប់ត្រង់ចំណុចលេខ៣២។

**ប្រធានអង្គជំនុំ៖**

បុគ្គលិកផ្នែកខាងសោតទស្សន៍ចាក់វីដេអូឃ្លីបនៅលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១១:៤៦:២៣]

*(ការបង្ហាញឯកសារជាវីដេអូ)*

[១១:៤៦:៥១]

**លោក ខេល លីសាក់៖**

សូមអរគុណ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** បុគ្គលដែលឃើញនៅក្នុង នៅកណ្តាលគេនៅពីមុខអ្នកថតរូបនេះ គឺបុគ្គលមួយរូបដែលលោកនិយាយអម្បាញ់មិញថាជាអ្នកតំណាងនិយាយ អ្នកនិយាយតំណាងឲ្យខ្មែរក្រហមហ្នឹង ឬក៏យ៉ាងម៉េច?

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** នៅពេលដែលខ្ញុំចុះពីលើឡាន ហើយដើរសំដៅទៅអគារ ខ្ញុំឃើញបុគ្គលទាំងអស់នេះនៅទីនោះ។ បុគ្គលម្នាក់ដែលកាន់ក្រដាសនេះ នៅខាងឆ្វេងនេះ គឺគាត់កាន់ក្រដាសដៃឆ្វេង គឺខ្ញុំមិនឃើញគាត់ជួបជជែកជាមួយនឹងអ្នកណានោះទេ គឺខ្ញុំអត់បានឃើញទេ។ ហើយបុគ្គលដែលកាន់ក្រដាសនៅដៃខាងឆ្វេងនេះ មិនមែនជាអ្នកបុគ្គលម្នាក់ដែលក្រោយមកទៅនិយាយជាមួយជាមួយនឹង ស៊ីដនី សាន់ប៊ឺដនោះទេ។

[១១:៤៨:០០]

**លោក ខេល លីសាក់៖**

សូមអរគុណដែលលោកបានបញ្ជាក់ ខ្ញុំសូមឲ្យចាក់ខ្សែវីដេអូនេះបន្តទៀត។ នៅពេលនេះគឺ

ឲ្យបញ្ឈប់ត្រឹមលេខ៤១វិនាទីវិញ។ សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

បុគ្គលិកផ្នែកខាងសោតទស្សន៍ចាក់ផ្សាយវីដេអូឃ្លីប តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១១:៤៨:៣២]

*(ការបង្ហាញឯកសារជាវីដេអូ)*

[១១:៤៨:៥១]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ប៉ុន្មាននាទី ២-៣នាទីអម្បាញ់មិញនេះ លោកបានបញ្ជាក់ថា មានអ្នកតំណាងពីមន្ត្រី លន់ នល់ នោះមកនិយាយតំណាងមន្ត្រី លន់ នល់។ តើលោកអាចបញ្ជាក់ទេ តើមួយណាដែលនឹងមកនិយាយតំណាងមន្ត្រីរបប លន់ នល់ នោះ?

**លោក អាល់ រ៉ុក្វូហ្វ៖**

**ឆ៖** ខ្ញុំមិនស្គាល់បុគ្គលហ្នឹងជាអ្នកណានោះទេ។ ហើយបុគ្គលមួយហ្នឹង គឺគាត់និយាយជាមួយនឹងអ្នកតំណាងខ្មែរក្រហម ហើយគាត់បានបញ្ជាក់លើកដៃស្តាំរបស់គាត់ ហើយគាត់យកដៃហ្នឹងមកផ្គុំចូលគ្នាជាមួយនឹងដៃឆ្វេង ហើយនិងក្រោយមកគឺថាមានឃើញគេដើរមកជិតគាត់។

**ស៖** នៅពេលនេះ ខ្ញុំសូមអានអត្ថបទដកស្រង់ចេញពីកំណត់ហេតុ ចន ស្វេន គឺឯកសារលេខ E3/51 ត្រង់លេខ ERN S00003278 ខ្មែរមានលេខ S007644710, បារាំងមានលេខ 00597835 គឺមានការដកស្រង់សម្តីសរសេរដូចតទៅ "នៅក្រសួងព័ត៌មានបុគ្គលប្រហែលជាអាយុ៣៥ ហាក់ដូចជាមេដឹក -- ជាប្រធានរបស់ក្រុមក្នុង។ គឺនៅឯក្រសួងព័ត៌មានវិញនោះ បុរសម្នាក់ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅអាយុខ្ទង់ ៣៥ ជាមេដឹកនាំផងដែរ បានស្រែកដាក់មីក្រូទៅកាន់អ្នកទោសទាំងអស់ ដើម្បីបែងចែកពួកគេជាបីក្រុម គឺកងទ័ព នយោបាយ និងជនស៊ីវិលធម្មតា។ ខ្មែរក្រហមដែលកំពុងតម្រង់កាំភ្លើងមករកអ្នកទោសទាំងអស់នោះ ហាក់ដូចជាតឹងរ៉ឹងមាំមួន"។

តើលោកនៅចាំទេថា នៅក្នុងក្រសួងព័ត៌មាននៅពេលនោះនុះ? គេបានបែងចែកទាហាន លន់ នល់ ហ្នឹងជាបីក្រុម តើអ៊ីចឹងដែរឬទេ?

[១១:៥១:១៥]

**ឆ៖** ខ្ញុំមិនដឹងថា តើគេបានបែងចែកជាបីក្រុម ហើយខ្ញុំមិនដឹងតើស្ថានភាពនោះវាកើតឡើងបន្ត យ៉ាងម៉េចទៀតទេ ប៉ុន្មាននាទីក្រោយមកនោះ។

**ស៖** លោកបញ្ជាក់ថា នៅពេលដែលលោកមានវត្តមាននោះ នាយករដ្ឋមន្ត្រី ឡុង បូរ៉េត បាន មកដល់ក្រសួងព័ត៌មាន។ តើលោកអាចរៀបរាប់ពិពណ៌នា តើអាការៈ រូបរាងរបស់គាត់នោះយ៉ាងម៉េច ដែរនៅពេលដែលគាត់មកដល់ក្រសួងនោះ ហើយគាត់បានប្រគល់ខ្លួនឱ្យខ្មែរក្រហមនោះ?

**ឆ៖** គាត់មិនបានប្រគល់ខ្លួនឱ្យខ្មែរក្រហមនៅទីនោះទេ គឺខ្មែរក្រហមនាំគាត់មកក្រសួងនេះ។ គឺគេយកគាត់ពីកន្លែងទីតាំងផ្សេងមកដាក់ទីនេះ។ ខ្ញុំបានឮរឿងរ៉ាវប៉ុន្មានថ្ងៃមុនហ្នឹងដែរ កើតឡើងចំពោះ គាត់ គឺថា ក្រោយមកគឺនៅថ្ងៃនោះ គឺគេនាំគាត់មកក្នុងក្រសួងនេះ ខ្ញុំមិនចាំថាអ្នកណាគេដឹកគាត់មក ទេ។ នៅពេលមកដល់ គឺថាគេ -- គាត់ចេញមកពីក្នុងឡាន ហើយក្រោយមកទៀត គេ -- គឺគាត់ដើរ ចូល គេយកគាត់ហ្នឹងដាក់ចូលឡានដដែលនេះ ហើយបើកចេញទៅ។ ហើយខ្ញុំមិនចាំអ្វីទៀតទេ។

[១១:៥២:៣៥]

**ស៖** តើលោកបានទទួលព័ត៌មានអ្វីទៀតដែរឬទេ នាពេលក្រោយមក? តើលោកបានទទួល ព័ត៌មានថា មានអ្វីកើតឡើងចំពោះ ឡុង បូរ៉េត និងមន្ត្រីរដ្ឋាភិបាល លន់ នល់ នៅពេលនោះដែលត្រូវ បានគេប្រមូលផ្តុំនៅក្នុងក្រសួងនោះ? តើលោកដឹងថា ក្រោយមកកើតឡើងអ្វីចំពោះពួកគាត់ទាំងអស់ គ្នានោះ?

**ឆ៖** ខ្ញុំមិនបានដឹង។ អ្នកទាំងអស់នោះ ក៏មិនបានដឹងថា តើនឹងមានអ្វីកើតឡើងចំពោះពួកគេ នោះទេ។ គេប្រាប់យើងឱ្យចាកចេញទៅក្រសួង -- ស្ថានទូតបារាំង។ មន្ត្រីទាំងអស់នោះនៅក្នុងក្រសួង នោះដដែល។ អ្នកទាំងអស់នោះ ត្រូវបានគេប្រហែលជានាំយកទៅខាងជើង ទិសខាងជើងពីយើង។ ហើយខ្ញុំបានដឹងដែរថា ក្រោយមកមានការកើតឡើងលើ រឿងរ៉ាវលើពួកអ្នកទាំងអស់នោះ ប៉ុន្តែខ្ញុំមិនដឹង ថា -- ខ្ញុំមិនបានឃើញអ្វីកើតឡើងចំពោះពួកគាត់នោះទេ គ្រាន់តែដឹងថា មានរឿងកើតឡើងចំពោះ គាត់។

[១១:៥៣:៣៨]

**ស៖** តើលោកដឹងថា ស្តាប់ឮថាមានរឿងអ្វីកើតឡើងចំពោះអ្នកទាំងអស់នោះទេ?

**ឆ៖** ខ្ញុំស្ដាប់ឮថា គឺគេបានប្រមូលអ្នកទាំងអស់នោះ ទៅកន្លែងលេង ថិននីស ហើយដែលស្ថិតនៅក្នុងស្ថានទូតបារាំង ផងដែរ ហើយត្រូវបានគេកាប់សម្លាប់ចោល។ នេះជាអ្វីដែលខ្ញុំបានស្ដាប់ឮ។

**ស៖** តើលោកចាំទេ លោកស្ដាប់ឮព័ត៌មាននេះពីនរណាគេមកដែរ?

**ឆ៖** ខ្ញុំមិនចាំស្ដាប់ -- ខ្ញុំមិនចាំថា បានស្ដាប់មកពីនរណានោះទេ គឺចេញមកពីប្រភពមួយផ្សេងដែលខ្ញុំមិនស្គាល់ដែរ។

**លោក ឌេល លីសាក់៖**

លោកប្រធាន នៅពេលនេះ ខ្ញុំសូមអនុញ្ញាតអានចេញពីឯកសារ E3/604 វិញម្ដង គឺអត្ថបទសារព័ត៌មាន បាងកកប៉ុស្ដិ៍ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ៧៥ ស្ដីអំពីការកាប់សម្លាប់ ហើយខ្ញុំសូមអនុញ្ញាតធ្វើការបញ្ចាំង រួមទាំងឲ្យឯកសារក្រដាសទៅដល់សាក្សីផងដែរ លោកប្រធាន។

[១១:៥៥:១០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឯកសារដែលខ្ញុំប្រគល់ឲ្យលោកនោះ គឺអត្ថបទចុះផ្សាយនៅក្នុងកាសែតបាងកកប៉ុស្ដិ៍ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ៧៥ ដែលក្នុងនោះរួមមានសរសេរដូចតទៅ៖ “ឧបនាយករដ្ឋមន្ត្រីកម្ពុជា អៀង សារី បានបញ្ជាក់កាលពីម្សិលមិញនេះថា មេដឹកនាំកំពូលពីររូបនៅក្នុងអតីតរបបភ្នំពេញ ត្រូវបានប្រហារជីវិតដោយក្រុមប្រឹក្សាប្រជាជនបន្ទាប់ពីជ័យជំនះរបស់ខ្មែរក្រហម”។ ការបញ្ជាក់របស់ អៀង សារី ថា អតីតប្រធានាធិបតី ឡុង បូរ៉េត និង លន់ ណុន ជាប្អូនប្រុសរបស់អតីតប្រធានាធិបតី លន់ នល់ ត្រូវបានសម្លាប់នោះ បានកើតឡើងក្រោយពីមានរបាយការណ៍មិនច្បាស់ការណ៍ ដែលអះអាងកាលពីមុននេះថា បានរត់ចេញពីប្រទេស”។ បញ្ចប់ការដកស្រង់សម្ដី។ តើលោកនឹកឃើញនៅចាំទេ មានសេចក្ដីថ្លែងការណ៍ប្រកាសមួយចេញមកពី អៀង សារី ក្នុងចុងឆ្នាំ៧៥ ពាក់ព័ន្ធនឹងការកាប់សម្លាប់ ឡុង បូរ៉េត និង លន់ ណុន ពេលនោះ?

[១១:៥៦:៣៣]

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** នេះគឺជាលើកដំបូងដែលខ្ញុំបានឃើញអត្ថបទនេះ។ នៅក្នុងអំឡុងថ្ងៃនោះ កម្រ និងពិបាក

ក្នុងការឃើញអត្ថបទបែបនេះណាស់។ អត្ថបទបែបនេះគឺថា ខ្ញុំបានអាននាពេលក្រោយតែប៉ុណ្ណោះ។ ខ្ញុំមិនអាចឆ្លើយបានទេ។

**ស៖** ក្រោយពីលោកចាកចេញពីក្រសួងព័ត៌មាន តើលោកធ្លាប់បានឃើញឡុង បូរ៉េត និង លន់ ណុន សាជាថ្មីទៀតដែរឬទេ ក្រោយពីចេញពីក្រសួងព័ត៌មានមក?

**ឆ៖** ខ្ញុំមិនដែលធ្លាប់ឃើញគាត់ទៀតទេ។

**ស៖** នៅពេលនេះខ្ញុំសូមចូលទៅដល់ហេតុការណ៍មានអ្វីកើតឡើងក្រោយពីលោកចាកចេញពីក្រសួងព័ត៌មាននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥? លោកបានចាប់ផ្តើមនិយាយថា ក្រោយមកលោកទៅសណ្ឋាគារឡឺភ្នំ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ តើមានអ្វីកើតឡើងនៅពេលដែលលោកបានត្រឡប់ទៅសណ្ឋាគារឡឺភ្នំ ក្រោយពេលដែលលោកចេញពីក្រសួងព័ត៌មានទៅសណ្ឋាគារឡឺភ្នំនោះ តើមានអ្វីកើតឡើងដែរនៅថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ នាពេលនោះ?

[១១:៥៧:៤៧]

**ឆ៖** គឺខ្ញុំបានយកក្មេងមួយរូប ដែលរស់នៅរស់រានមានជីវិត ខ្ញុំឲ្យអាហារទៅដល់ក្មេងហ្នឹង ហូប ហើយខ្ញុំយកក្មេងនោះទៅស្ថានទូតបារាំងជាមួយខ្ញុំ។ ស៊ីដនី សាន់ប៊ឺជ គឺក៏ឲ្យក្មេងនោះចូលដែរ។ ខ្ញុំញ៉ាំអាហារក្រៀមជាច្រើននៅទីនោះ។ ស៊ីដនីបានចូលទៅបន្ទប់ ហើយគាត់បានយកកំណត់សម្គាល់មួយចំនួន ហើយគាត់ទៅទិសខាងជើង នៃស្ថានទូតបារាំង ហើយនៅពេលនោះ គឺវាងងឹតដែរ។ ហើយគេបានប្រាប់យើងឲ្យចូលក្នុងស្ថានទូតបារាំងនៅប្រហែលជាម៉ោងប្រាំ។ នៅពេលដែលយើងដើរចូលទៅស្ថានទូតបារាំង នៅពេលដែលយើងកំពុងតែដើរទៅស្ថានទូតបារាំងនោះ គឺថាយើងឃើញមានទាហានខ្មែរក្រហមជាច្រើនកាន់កាំភ្លើងបាញ់។ ហើយខ្ញុំបានថតរូបថតកងទ័ពខ្មែរក្រហមដើរខាងឆ្វេង ជួរខាងឆ្វេង និងប្រជាជនកំពុងតែដើរជួរខាងស្តាំ។ នៅពេលដែលយើងទៅដល់ស្ថានទូតបារាំង គឺជញ្ជាំងស្ថានទូតពេលនោះមិនខ្ពស់ទេ។ ហើយវាទាបជាងជញ្ជាំងនាពេលបច្ចុប្បន្ន ហើយប្រជាជនជាច្រើនឃើញឡើងតោងជញ្ជាំងចូលក្នុងស្ថានទូត។

[១១:៥៩:២៧]

**ស៖** តើនរណាគេប្រាប់លោកឲ្យទៅស្ថានទូតបារាំងនៅពេលនោះ?

**ឆ៖** ឌិត ប្រាន (Dith Pran) បានប្រាប់បញ្ហាឲ្យយើងជាអ្នកពាំនាំបញ្ហានេះ ថាឲ្យយើងដើរទៅស្ថានទូតបារាំង គឺគាត់ជាអ្នកប្រាប់យើង។ គេមានគេនោះប្រាប់ថា ឲ្យយើងហ្នឹងទៅស្ថានទូតបារាំង

ហើយចំពោះស្ថានការណ៍នៅជាតិស្ថានមិត្តភាពកម្ពុជា-ជប៉ុន នោះយើងមិនដឹងថាមានអ្វីកើតឡើងនោះទេ។ យើងគ្រាន់តែ ទទួលបញ្ជាពាក្យថា ឲ្យយើងនេះ ពួកយើងនេះទៅស្ថានទូតបារាំងតែប៉ុណ្ណោះ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំគិតថា ពេលនេះហាក់ដូចជាដល់ម៉ោងអាហារថ្ងៃត្រង់ហើយ ខ្ញុំប្រហែលជានៅសល់ពេល៣០នាទីទៀត ដែលខ្ញុំចង់សាកសួរទៅកាន់សាក្សី។ ហើយខ្ញុំកំពុងតែរង់ចាំរូបថតដែលបញ្ជូនមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ ដើម្បីសាកសួរដេញដោលទៅលើសាក្សី។ ហើយខ្ញុំត្រូវការប្រហែលជានៅថ្ងៃនេះកន្លះម៉ោងទៀតសម្រាប់រូបខ្ញុំនេះ សួរទៅលើសាក្សីរូបនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ចុះតំណាង -- ចុះមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងម៉េចដែរ?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំត្រូវការរយៈពេល៤៥នាទីជាអតិបរមាលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ជម្រាបសួរភាគីទាំងអស់។ ខ្ញុំមានសំណើមួយ ដូចលោកចៅក្រមដឹងហើយថាគាត់ទើបតែចេញពីមន្ទីរពេទ្យ ហើយគាត់មានសុខភាពខ្សោយ ហើយគាត់ខំប្រឹងប្រែងសម្បើមណាស់ ដើម្បីមកចូលរួមក្នុងសវនាការនេះ យ៉ាងហោចណាស់ពេលព្រឹកនេះ ពីព្រោះថា សំខាន់ណាស់ចំពោះគាត់ក្នុងការមានវត្តមាននៅទីនេះ ពីព្រោះថាជាសវនាការដែលមានសាក្សី ក៏ប៉ុន្តែគាត់បានរៀបរាប់ថាគាត់ពិបាកនឹងអង្គុយនៅទីនេះ ដោយសារគាត់មានជំងឺរលាកទងសួត។ ដូច្នេះ គាត់សុំតាមដានសវនាការនេះនៅក្នុងបន្ទប់ខាងក្រោមនៅរសៀលនេះ។ ដូច្នេះ ជាសំណើជាពិសេសមួយ ពីព្រោះថាលោក ខៀវ សំផន គាត់ចង់មានវត្តមាននៅក្នុងសវនាការស្តាប់សាក្សី ដោយសារពេលខ្លះយើងអាចចោទសំណួរ ក៏ប៉ុន្តែថ្ងៃនេះគឺថាចំពោះគាត់ពិបាកមែនទែន ដោយសារគាត់បានជួបពេទ្យពេលសម្រាកនេះ។ អ៊ីចឹង គាត់សុំតាមដានសវនាការនេះនៅបន្ទប់ខាងក្រោម ហើយនិងសុំឲ្យគ្រូពេទ្យអាចពិគ្រោះជាមួយគាត់នៅពេលសម្រាក។ ដូច្នេះ គាត់សួរថាតើលោកប្រធានអនុញ្ញាតដែរឬក៏អត់? បើសិនជា

អនុញ្ញាត យើងនឹងធ្វើបំពេញលិខិតតាមសមស្របលោកប្រធាន។

[១២:០២:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

អរគុណលោកប្រធាន យើងខ្ញុំមិនជំទាស់នឹងសំណើសុំនេះទេ។ យើងខ្ញុំក្រោកឈរឡើងនេះ គឺដើម្បីបញ្ជាក់ថា សហសេរិកខាងជាតិបានបញ្ជាក់ថា ដូច្នេះខ្ញុំគ្រាន់តែបញ្ជាក់ថា ខាងខ្មែរគឺបក៣០នាទី គឺថាតាមពិតទៅខ្ញុំត្រូវការ ៣០ ទៅ៤៥ នាទី ដើម្បីបញ្ចប់ការដេញដោលសំណួររបស់ខ្ញុំ។

[១២:០៣:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៤:២៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់នូវសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាក្នុងការពន្យារពេល បន្ថែមពេលវេលាសម្រាប់សួរសាក្សីរូបនេះ ហើយអង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញថា សំណួរជាច្រើន ហើយនិងចម្លើយតបរបស់សាក្សីរូបនេះមានការពាក់ព័ន្ធ ហើយសំខាន់ដោយសារគាត់ជាសាក្សីដែលបានឃើញ បានដឹង បានឮដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយពាក់ព័ន្ធនឹងបណ្តាអង្គហេតុ នៅក្នុងសំណុំរឿង០០២/០១ ដែលអង្គជំនុំជម្រះបំបែកមកធ្វើសវនាការនៅដំណាក់កាលទី១នេះ។ ហើយ ដោយស្ថានភាពចាំបាច់ដូច្នេះ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតផ្តល់ពេលវេលាបន្ថែមជូនភាគីទាំងពីរ ទាំងតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយពេលនៅរសៀល នេះគឺពីម៉ោងចាប់ផ្តើមរហូតដល់ពេលសម្រាកនៅវេលារសៀល សម្រាកទី១។

ហើយអង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ ខៀវ សំផន ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការនៅរសៀលនេះ ដោយហេតុបញ្ហាសុខភាព ដោយលោក ខៀវ សំផន ទើបតែចេញពីមន្ទីរពេទ្យ។

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក ខៀវ សំផន ទៅបន្តតាមដានកិច្ចដំណើរការ

សវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់ពេលរយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយលោក ខៀវ សំផន លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទាប់សវនាការនេះ។

[១២:០៦:១២]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ប្រគល់ជូនមកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខាឬផ្ដិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់លោក ខៀវ សំផន។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក ខៀវ សំផន អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះសម្រាប់រយៈពេលនៃកិច្ចដំណើរការសវនា-ការនៅរសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៧នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សួស្តីលោក រ៉ុក្វហ្វ នៅពេលដែលយើងឈប់សម្រាកអាហារថ្ងៃត្រង់លោកបានរៀបរាប់អំពីពេលដែលលោកធ្វើដំណើរទៅស្ថានទូតបារាំង ហើយលោកបានបញ្ជាក់ថា ក្នុងពេលនោះលោកឃើញកងទ័ពខ្មែរក្រហមធ្វើដំណើរចូលទីក្រុងភ្នំពេញនេះពីទិសដៅចូលមក ហើយប្រជាជននេះដើរចេញពីទីក្រុងភ្នំពេញ។ ដូច្នេះ ខ្ញុំចង់សួរថា ប្រជាជនដែលត្រូវបានគេដឹកចេញពី-- ដែលដើរចេញពីទីក្រុងភ្នំពេញនោះ រួមទាំងចាស់ ហើយនិងកុមារផង និងមនុស្សឈឺផងដែរឬទេ?

**លោក អាល់ រ៉ុក្វហ្វ៖**

**ឆ៖** ឃើញមានប្រជាជនចាស់ និងអ្នកឈឺ ហើយយើងឃើញអ្នក១៧ មេសា គ្រួសារនោះគឺរួមទាំងមនុស្សចាស់ផងដែរចាកចេញពីទីក្រុងភ្នំពេញ។ ចំពោះអ្នកឈឺវិញ ឃើញគេប្រដេញចេញពីមន្ទីរពេទ្យរួមទាំងមន្ទីរពេទ្យកាល់ម៉ែតផងដែរ។ ហើយគឺថាខ្ញុំឃើញដែរ ថ្ងៃទី២ឃើញអ៊ីចឹងដែរ ដោយសារខ្ញុំមើលតាម មើលពីក្នុងស្ថានទូតបារាំងមកវិញ ខ្ញុំឃើញអ៊ីចឹង។ គឺអ្នកឈឺនោះ ត្រូវបានគេបណ្តេញចេញពីពេទ្យកាល់ម៉ែត ហើយរួមទាំងអ្នកខ្លះហ្នឹងឃើញគេសែងនៅក្នុងប្រង់កាផងដែរ។

[១៣:៣៤:២៧]

**ស៖** តើលោកបានសង្កេតឃើញ ការបណ្តេញចេញអ្នកឈឺពីមន្ទីកាល់ម៉ែតដែរឬទេ ពីស្ថានទូតបារាំងនោះ តើលោកមើលឃើញគេបណ្តេញចេញដែរឬទេ?

**ឆ៖** គឺខ្ញុំគ្រាន់តែឃើញប្រជាជននោះដើរចេញពីទីក្រុងភ្នំពេញឆ្ពោះទៅទិសខាងជើងតែប៉ុណ្ណោះ ហើយឆ្លងកាត់ទូតហ្នឹងទៅ ខ្ញុំមើលឃើញ ខ្ញុំមើលមិនឃើញថាគេបណ្តេញ ឬមិនបណ្តេញពីមន្ទីរពេទ្យកាល់ម៉ែតនោះទេ។

**ស៖** ហើយថាតើនៅពេលដែលគេជម្លៀសទីក្រុងភ្នំពេញនោះ តើយើងឃើញថាប្រាកដជាមានការខ្វះខាតអាហារ ហើយបញ្ហាស្បៀងមនុស្សធម៌នេះ ខ្មែរក្រហមមានផ្តល់ជូនជំនួយផ្នែកមនុស្សធម៌ ថ្នាំពេទ្យ អាហារអីទៅដល់អ្នកដែលត្រូវបានជម្លៀសដែរឬទេ? ខាងខ្មែរក្រហមគេមានជួយអ៊ីចឹងទេ?

**ឆ៖** ខ្ញុំមិនឃើញខ្មែរក្រហមផ្តល់ការជួយជ្រោមជ្រែងណាមួយនោះទេ។ ចំពោះការជួយផ្តល់ម្ហូបអាហារ គឺយើងឃើញតែបន្លែបង្កា...។ល។ នោះ ដែលគេផ្តល់មកឲ្យមនុស្សនោះក្នុងស្ថានទូតបារាំងតែប៉ុណ្ណោះ យើងខ្ញុំបានទទួល។ ហើយខ្មែរក្រហមនោះ អនុញ្ញាតឲ្យយើងទទួលបាននូវបន្លែបង្កាម្ហូបអាហារ ក៏ប៉ុន្តែខ្ញុំមិនដឹងថានៅខាងក្រៅខ្មែរក្រហមអនុញ្ញាតផ្តល់ជំនួយអ៊ីចឹងដែរឬទេ នោះឡើយ។

[១៣:៣៦:១២]

**ស៖** ខ្ញុំចង់សួមសួរលោកត្រឡប់ក្រោយបន្តិច កាលពីព្រឹកមិញដែលលោកបានលើកឡើងអំពីកាកបាទក្រហមបានបើកបេសកម្មរបស់ពួកគេនៅក្នុងសណ្ឋាគារឡឺភ្នំ តើខ្មែរក្រហមមានអនុញ្ញាត នៅតែបន្តអនុញ្ញាតឲ្យខាងកាកបាទក្រហមនេះ ដំណើរការបេសកម្មមនុស្សធម៌នៅក្នុងសណ្ឋាគារ ឡឺភ្នំ នេះបន្តទៀតដែរឬទេ?

**ឆ៖** អត់ទេ គឺគេក៏ជម្លៀសក្រុមកាកបាទក្រហមនេះចេញជាមួយនឹងប្រជាជនផងដែរ។ គឺក្រុមដែល -- ក្រុមខ្ញុំនេះមានលោក ចន ស្វេន, ឌិត ប្រន ជាមួយនិងបុគ្គលមួយទៀត ហើយយើងខ្ញុំនេះទៅជាមួយខាងក្រុមកាកបាទក្រហម ហើយយើងទៅជាមួយពួកគេ។ យើងឃើញមានឡានតូចមួយដែលថាទៅជាមួយក្រុមកាកបាទក្រហមនេះ ហើយយើងទៅជាមួយនឹងក្រុមនុំងទាំងអស់។ យើងទៅដល់ស្ថានទូតបារាំងនេះ នៅពេលដំណាលគ្នា។

[១៣:៣៧:២៥]

**ស៖** តើលោកមានវត្តមានទេនៅក្នុងសណ្ឋាគារឡឺភ្នំនេះ នៅពេលដែលគេបញ្ជាឲ្យក្រុមកាកបាទក្រហមនេះចេញពីសណ្ឋាគារឡឺភ្នំនេះ តើលោកមានវត្តមាននៅពេលនោះដែរឬទេ? លោកឃើញឬទេ? លោកឃើញទេ?

**ឆ៖** ខ្ញុំមិនឃើញផ្ទាល់ភ្នែកនោះទេ ខ្ញុំមិនឃើញគេបញ្ជាក្រុមកាកបាទក្រហមឲ្យចាកចេញដោយផ្ទាល់នោះទេ។ ហើយគឺទៅដល់ យើងធ្វើដំណើរទៅដល់ឈប់នៅក្រសួងព័ត៌មាន ហើយយើងត្រូវទៅសណ្ឋាគារហ្នឹង ដើម្បីប្រមែប្រមូលអីវ៉ាន់ ហើយបន្ទាប់ពីចេញពីសណ្ឋាគារឡឺភ្នំនេះ គឺថាយើងចេញទៅរហូតតែម្តង ហើយខ្ញុំមិនឃើញទេ ការបញ្ជាថាឲ្យចាកចេញនោះ។ ខ្ញុំគ្រាន់តែថា ទៅដល់គឺគេឲ្យយើងចេញរួមគ្នា។

**ស៖** ខ្ញុំសួមសួរពេលដែលលោកនៅស្ថានទូតបារាំង តើលោកអាចចាប់ផ្តើមជម្រាបយើងខ្ញុំទេអំឡុងពេលណាដែរ? ក្រោយពីលោកទៅដល់ស្ថានទូតបារាំងនៅពេលល្ងាចថ្ងៃទី១៧ ខែមេសា នោះ? នៅពេលទៅដល់នោះ តើលោកស្នាក់នៅស្ថានទូតបារាំងហ្នឹងរយៈពេលប៉ុន្មានដែរ?

[១៣:៣៨:៤៥]

**ឆ៖** ខ្ញុំគិតថា ខ្ញុំឆ្លង -- ពេល១ខ្ញុំទៅសល់ព្រំដែនថៃនោះ ចំណាយពេលពីស្ថានទូតបារាំងនេះ ២ថ្ងៃ ប្រហែលជា២ថ្ងៃកន្លះ។ ខ្ញុំមិនច្បាស់ទេ ហើយគឺថាក្រុមដឹកជញ្ជូន ឬក៏ឡានហ្នឹងទៅដល់ព្រំដែននៅ

ថ្ងៃណានោះទេ។

**ស៖** បានន័យថាយ៉ាងម៉េច? លោកចាកចេញពីស្ថានទូតនៅថ្ងៃ០៦ ឧសភា ឬក៏យ៉ាងណា?

**ឆ៖** គឺខ្ញុំចាកចេញ -- បាទ គឺថាខ្ញុំចាកចេញពីស្ថានទូតហ្នឹងថ្ងៃ១៧ ឧសភា មែន ហើយយើងទៅដល់ឆ្លងដែនព្រំដែនថៃហ្នឹង គឺថ្ងៃ១៩។

**ស៖** តើលោកនៅចាំទេថា នៅពេលដែលលោកនៅក្នុងស្ថានទូតនោះ មានកងកម្លាំងខ្មែរក្រហមនោះនៅយាមកាមខាងក្រៅស្ថានទូតដែរឬទេ?

[១៣:៣៩:៥៥]

**ឆ៖** ខ្ញុំឃើញពួកគេដើរចុះដើរឡើង គឺពីរបីនាក់។ ពេលខ្លះកម្មាភិបាលខ្មែរក្រហមដើរចូលមកស្ថានទូត ហើយមន្ត្រីកុងស៊ុលបារាំង ហើយគឺគាត់ដើរមកអមជាមួយកម្មាភិបាលខ្មែរក្រហម គឺថាជាធម្មតា គឺខ្មែរក្រហមដើរចូលមកឆែកឆេរ ហើយគេបណ្តេញជនជាតិខ្មែរហ្នឹងចេញពីស្ថានទូតបារាំងបើសិនជាឃើញ។ នៅពេលមួយនោះខ្មែរក្រហមក្មេងម្នាក់ដើរចូលមកស្ថានទូតបារាំង ហើយពេលដែលទៅគឺមានបញ្ហា។ ហើយពេលដែលកម្មាភិបាលសួរថាមកធ្វើអីនោះ គឺខ្មែរក្រហមក្មេងនោះថាមកសុំបារីនៅពេលដែលឃើញអ៊ីចឹងកម្មាភិបាលខ្មែរក្រហមបានទាត់ក្មេងទាហានខ្មែរក្រហមហ្នឹង។

ហើយនៅក្នុងស្ថានទូតហ្នឹងមានអ្នកកាសែតជប៉ុនម្នាក់ឈ្មោះ ប៊ូគី ហើយដែលយើងឃើញថាគឺគាត់ហ្នឹងនៅក្នុងហ្នឹង។ ខ្ញុំក៏បានទៅជួប ហ្វូដឹមដារ៉ល (តាមសំឡេងបកប្រែ) ហើយខ្ញុំក៏បានទៅកន្លែងបឹង១កក់ហ្នឹងខ្ញុំទៅដុសលាងខ្លួនងូតទឹកនៅទីនោះ ហើយ ប៊ូគី ហ្នឹងដែលជាអ្នកជនជាតិជប៉ុនហ្នឹងក៏ចេះក៏នៅទីនោះដែរ។ គាត់ចេះភាសាខ្មែរច្បាស់ណាស់។ ហើយគឺខ្ញុំបានទៅបឹងកក់ហ្នឹងប្រហែលជា ១៥ ម៉ែត្រទេពីស្ថានទូត។ ខ្មែរក្រហមនៅពេលដែលខ្ញុំនិយាយជាមួយនៅក្នុងខ្ទមមួយហ្នឹង គឺថាខ្មែរក្រហមហ្នឹងមកសុំបារីពីយើងខ្ញុំ១។ ហើយខ្មែរក្រហមហ្នឹងញញឹមសើចដាក់ខ្ញុំ។ ខ្ញុំក្រោយមកត្រឡប់ទៅស្ថានទូតបារាំងវិញ ហើយខ្ញុំទៅយកកាមេរ៉ាខ្ញុំ ហើយនៅពេលក្រោយបន្តិចគេដឹងថាខ្ញុំនេះដើរចេញពីស្ថានទូតដូច្នេះខ្ញុំវា មានបញ្ហានៅពេលនោះ។

[១៣:៤២:០៧]

**ស៖** ខ្ញុំគិតថាចំណុចហ្នឹងហើយ លើកហ្នឹងហើយពេលដែលចុងក្រោយដែលលោកចាកចេញពីស្ថាន ទូតបារាំងហ្នឹងគឺពេលហ្នឹងមែនទេ ពេលចុងក្រោយចាកចេញពីស្ថានទូតបារាំង?

**ឆ៖** បាទគឺហ្នឹងហើយ ពេលដែលចុងក្រោយដែលខ្ញុំចាកចេញពីទីតាំងស្ថានទូតបារាំង។

**លោក ឌេល លីសាក់៖**

លោកប្រធាន នៅពេលនេះខ្ញុំសូមអនុញ្ញាតចាក់ផ្សាយខ្សែវីដេអូ គឺវីដេអូឃ្លីបចេញមកពីខ្សែវីដេអូចំណងថា "បទប្រល័យពូជសាសន៍ខ្មែរក្រហម"។ គឺឯកសារ D108/32.2R លេខ 994 អ៊ីចឹង ឯកសារនោះមាននៅក្នុង*ហ្សាយឡេប*។ ឯកសារនោះមានលេខ E3/2348 គេដាក់លេខ E អ៊ីចឹងដែរ។ ហើយលេខនោះគឺមានលេខ 00172516 ឃ្លីបហ្នឹងចាក់ពីនាទី ២៧:១០ ទៅដល់ ២៧:៥៨។ យើងខ្ញុំបានផ្តល់ខ្សែវីដេអូឃ្លីបទី២ នេះទៅឲ្យខាងសោតទស្សន៍រួចហើយ។ ដូច្នេះហើយស្នើសុំលោកប្រធានឲ្យអាចយើងខ្ញុំនេះមានលទ្ធភាពចាក់ខ្សែវីដេអូនេះ ហើយសូមឲ្យខាងអង្គភាពសោតទស្សន៍នោះ ជួយចាក់ខ្សែវីដេអូដូចដែលខ្ញុំបានអានអម្បាញ់មិញនេះផងដែរ។

[១៣:៤៣:៤២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលិកផ្នែកសោតទស្សន៍ចាក់បង្ហាញនូវវីដេអូឃ្លីបលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា។

[១៣:៤៣:៥៥]

*(ការបង្ហាញឯកសារជាវីដេអូ "បទប្រល័យពូជសាសន៍ខ្មែរក្រហម")*

[១៣:៤៤:៥៥]

**សួរដោយលោក ឌេល លីសាក់៖**

សំណួរទី១របស់ខ្ញុំជូនលោក រ៉ូក្វហ្វ តើលោកចាំទេទីតាំងអម្បាញ់មិញនៅកន្លែងណាដែរ? ហើយនៅក្នុងហេតុការណ៍ណាមួយដែរនៅក្នុងខ្សែវីដេអូហ្នឹង?

**ឆ៖** ខ្ញុំចាំ គឺស្ថិតនៅក្នុងស្ថានទូតបារាំង ទីតាំងហ្នឹង។

**ស៖** តើខ្សែវីដេអូហ្នឹងថតក្រោយថ្ងៃ១៧ មេសា នៅពេលដែលលោកទៅជ្រកកោននៅក្នុងស្ថានទូត ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនអាចបញ្ជាក់ថា ក្រោយថ្ងៃ១៧ មេសា ឬក៏យ៉ាង -- ឬនៅថ្ងៃទី១៦ ឬ១៧នោះទេ ក៏ប៉ុន្តែខ្ញុំចាំថាអ្នកទាំងអស់នៅក្នុងខ្សែវីដេអូហ្នឹង ខ្ញុំធ្លាប់បានឃើញនៅក្នុងស្ថានទូត។ សូមអធ្យាស្រ័យខ្ញុំមិនអាចបញ្ជាក់ថ្ងៃច្បាស់លាស់ទេ។

[១៣:៤៥:៥១]

**ស៖** តើលោកស្គាល់ទេ ស្គាល់មនុស្សក្នុងហ្នឹងមួយចំនួនទេ ក្នុងខ្សែវីដេអូហ្នឹង? តើលោកអាចជម្រាបទេថាស្គាល់អ្នកណាខ្លះក្នុងខ្សែវីដេអូហ្នឹង?

**ឆ៖** ខ្ញុំមិនអាចចាំឈ្មោះទេ ក៏ប៉ុន្តែខ្ញុំនៅចាំខ្លះដែរ។ ចាំអ្នកសារព័ត៌មានមួយចំនួន ហើយនៅក្នុងហ្នឹងមានអ្នកខ្លះជាអ្នកនៅក្នុងសហគមន៍នៅក្នុងប្រទេសហ្នឹង។

**ស៖** នៅពេលដែលលោកនៅក្នុងស្ថានទូត តើលោកធ្លាប់ឃើញអ្នកណាម្នាក់ដែលមានកាមេរ៉ាថត សម្រាប់ថតវីដេអូ ឬក៏ថតរូបភាពអីដែរឬទេ?

**ឆ៖** មនុស្សជាច្រើនគាត់អត់ឃើញមានកាមេរ៉ាវីដេអូទេ មានតែថតរូបភាពធម្មតា។ ហើយយើងឃើញថា អ្នកនៅខាងក្រៅដែលអ្នកកាន់កាមេរ៉ាផ្សេងទៀត ដែលអាចថតរូបភាពថ្ងៃ១៧ មេសា កងទ័ពខ្មែរក្រហម រួមទាំងរូបថតផ្សេងទៀតនៅខាងក្រៅស្ថានទូតនោះអាចលោកស្រី គ្រីស្ទួហ្វ ម្នាក់ទៀតដែលថតនៅខាងក្រៅស្ថានទូតបារាំង។

[១៣:៤៧:០៦]

**ស៖** សូមអរគុណ។ ចំណុចមួយទៀត ដែលខ្ញុំសូមសួរលោកនោះគឺ លោកបានបញ្ជាក់ចំណុចហ្នឹងខ្លីៗរួចមកហើយក្នុងនៅពេលដែលលោកស្ថិតនៅក្នុងស្ថានទូតបារាំង។ តើលោកមានបានដឹងអំពីការពិភាក្សា ឬក៏ចរចាណាមួយរវាងតំណាងខ្មែរក្រហម និងតំណាងស្ថានទូតបារាំងដែរឬទេ?

**ឆ៖** គឺអ្នកសារព័ត៌មានផ្សេងទៀតបានប្រាប់ខ្ញុំដែរ ថាមានការចរចាគ្នា។ ខ្មែរក្រហមអនុញ្ញាតឲ្យស្ថានទូតបារាំងនេះទាក់ទងតាមវិទ្យុនេះជាមួយនឹងអ្នកនៅខាងក្រៅបាន ក្រៅពីហ្នឹងគឺថាខ្ញុំគ្មានដឹងអ្វីទេ។

**ស៖** ខ្ញុំសូមអានជូនលោក អត្ថបទដកស្រង់ចេញពីសៀវភៅកំណត់ហេតុ ចន ស្វេន។ លេខនោះគឺម៉ោងប្រាំមួយល្ងាច ថ្ងៃទី១៨ ខែមេសា ឆ្នាំ៧៥។ ឯកសារ E3/51, ត្រង់លេខ ERN អង់គ្លេស S00003280, ខ្មែរមានលេខ S00644717 និងបារាំងមានលេខ 00597840។ ការដកស្រង់នៅក្នុងហ្នឹង គឺពាក់ព័ន្ធនឹងការប្រជុំមួយដែលនៅក្នុងហ្នឹងមាន យូនីសេហ្វ បានប្រជុំដែរ ដែលថាបុគ្គលិកអន្តរ-ជាតិ រួមទាំងអ្នកសារព័ត៌មាន២២នាក់ សមាជិកកាកបាទក្រហម និងក្រុមគ្រូពេទ្យជនជាតិស្កុតឡែន ១៥នាក់ មន្ត្រីអង្គការសហប្រជាជាតិប្រាំមួយនាក់ ព្រមទាំងជនបរទេស និងជនជាតិអាមេរិកផងដែរ។ ក្នុងពេលប្រជុំនោះគេបាននិយាយអំពីការវិវត្តថ្មីៗ។ គេបានលើកឡើងថា ក្នុងពេលនោះខ្មែរក្រហមទាំងពីរនាក់នោះ បានលើកឡើងអំពីគណៈកម្មធិការទីក្រុង។ ខ្ញុំសូមសួរលោក តើលោកនៅចាំទេ នៅពេល

នោះគណៈកម្មាធិការទីក្រុងនោះ គឺមានអ្នកតំណាងខ្មែរក្រហមនោះ គេមកនិយាយជាមួយខាងតំណាងស្ថានទូត។ តើលោកនៅចាំទេ?

[១៣:៤៩:៥២]

**ផ៖** ខ្ញុំមិនបានដឹងទេ មិនបានស្គាល់គណៈកម្មាធិការទីក្រុងនេះទេ។

**ស៖** កិច្ចប្រជុំមិនប្រជុំនៅក្នុងកន្លែងដែលជនបរទេស អ្នកសារព័ត៌មានបរទេសនោះ នៅទីនោះៗទេ គឺថាខ្ញុំនៅឆ្ងាយដាច់ពីកន្លែងនុ៎ង ខ្ញុំអត់ដឹងទេ។

**ស៖** តើលោកបានដឹងទេ ថាមន្ត្រីរបបលន់ នល់ មួយចំនួនក៏បានស្នើសុំជ្រកកោននៅក្នុងស្ថានទូតផងដែរ តែត្រូវគេបានផ្លាស់ប្តូរកន្លែងគាត់។ តើលោកចាំទេ?

**ផ៖** ខ្ញុំចាំ។ ស៊ីសុវត្ថិ សិរិមតៈ គឺថាខ្ញុំអត់នៅទីនោះៗទេ នៅពេលដែលគាត់ត្រូវតែចាកចេញពីស្ថានទូតបារាំង។ មន្ត្រី លន់ នល់ ក៏ស្ថិតនៅក្នុងហ្នឹងផងដែរ ក៏ប៉ុន្តែខ្មែរក្រហម ទាហានខ្មែរក្រហមនោះត្រូវបានគេស្វែងរកនៅក្នុងស្ថានទូតហ្នឹងយកចេញទៅ។ ទាហានដែលធ្វើប្រតិបត្តិការគឺបាននាំយកចេញទៅ ហើយមានបុគ្គលម្នាក់គឺថាត្រូវបានគេបាញ់សម្លាប់ចោល។ មានទាហានមួយចំនួនទៀតនៅក្នុងហ្នឹងដែរ ក្រុមជនជាតិភាគតិចមកពីទន្លេមេគង្គម្ខាងនោះ ប្រហែលជា៣០០នាក់នោះត្រូវបានគេបណ្តេញចេញពីស្ថានទូតហ្នឹង។ គឺ៣០០នាក់ដែលខ្ញុំនិយាយអំមិញហ្នឹង គឺជាទាហាន។

[១៣:៥១:៣៤]

**ស៖** ខ្ញុំនឹងសួរអំពីក្រុមបុគ្គលជាក់លាក់ហ្នឹងក្នុងពេលប៉ុន្មាននាទីទៀតនេះ។ នៅពេលនេះខ្ញុំសូមអានជូនលោក អត្ថបទដកស្រង់មួយទៀតគឺសារទូរលេខបញ្ជូនពី ចន ឌីរ៉ាក កុងស៊ុលបារាំងនៅថ្ងៃ១៨ មេសា ៧៥។ កម្មវត្ថុនៅពេលនោះគឺថាការសុំសិទ្ធិ សុំជ្រកកោននយោបាយ។ ឯកសារ D199/26.2.199 នៅក្នុងសារទូរលេខនេះគឺ "កុងស៊ុលបារាំងបញ្ជូនទៅមេរបស់គាត់នៅបារីស។ ក្រោយពេលដែលថ្ងៃកំណត់ឱសានវាទរបស់គណៈកម្មាធិការទីក្រុង ខ្ញុំធ្វើយ៉ាងណាព្យាយាមដាក់បញ្ចូលវត្តមានបុគ្គលមួយចំនួននៅក្នុងស្ថានទូតបារាំងហ្នឹង។ ទី១ យើងឃើញមានវត្តមាន ស៊ីសុវត្ថិ សិរិមតៈ, ទី២ ព្រះអង្គម្ចាស់ក្សត្រី មុំ ម៉ានីវង្ស មានដើមកំណើតឡាវ (ជាយាទី៣របស់សម្តេច សីហនុ) រួមនឹងកូនស្រីម្នាក់ កូនប្រសារប្រុសម្នាក់ និងចៅៗ។ ៣) លោក អ៊ឹង ប៊ុនហ៊ី ប្រធានរដ្ឋសភាជាតិ។ ៤) លោក លឿង ណាល់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ បើមិនមានបញ្ហាច្បាស់លាស់ និងបន្ទាប់ពីក្រសួងតម្រូវឱ្យខ្ញុំផ្តល់ឱ្យសិទ្ធិជ្រកកោននយោបាយដល់ឥស្សរជនដែលមានឈ្មោះដូចរៀបរាប់ខាងលើនេះទេនោះ ខ្ញុំត្រូវប្រគល់

ឈ្មោះទាំងនោះក្នុងរយៈពេលមិនលើសពី២៤ម៉ោង"។ ខ្ញុំសូមបញ្ចប់ការដកស្រង់សម្ដី។

[១៣:៥៣:៣០]

លោកបាននិយាយអំពីៗ ស៊ីសុវត្ថិ សិរិមតៈ។ តើលោកនៅចាំទេ ថាតើមានអ្នកណាខ្លះទៀតដែលបានសុំសិទ្ធិជ្រកកោននៅក្នុងស្ថានទូតបារាំងនោះ?

**ឆៈ** ខ្ញុំមិនចាំទេ មន្ត្រីផ្សេងទៀតដែលគាត់មកសុំជ្រកកោននៅក្នុងស្ថានទូតបារាំង។ ខ្ញុំបានឮតែលោក ស៊ីសុវត្ថិ សិរិមតៈ ២ថ្ងៃក្រោយប៉ុណ្ណោះ។ មានភាពច្របូកច្របល់ណាស់នៅ២ថ្ងៃដំបូង។ ហើយខ្ញុំមិនច្បាស់ទេអ្នកណាខ្លះនៅក្នុងហ្នឹងខ្លះនោះ។ ប៉ុន្មានថ្ងៃមុនហ្នឹងគឺថាខ្មែរក្រហមមិនមានឯកសារណាមួយដែលថាអ្នកណាខ្លះត្រូវបណ្ដេញចេញនោះទេ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ ដូចខ្ញុំចម្រាបអ៊ីចឹងគឺថាខ្ញុំមិនច្បាស់លាស់ទេថាតើវាមានអ្វីខ្លះនៅក្នុងហ្នឹង។

**សៈ** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ បួននាក់ដែលតម្រូវឲ្យចាកចេញពីស្ថានទូតបារាំងក្រោយស្នាក់នៅទីនោះប៉ុន្មានថ្ងៃនោះ? មុនពេលនុ៎ងគឺ មុនថ្ងៃ១៨ ខែមេសា ឆ្នាំ៧៥ តើលោកអាចដឹងទេនៅក្នុងស្ថានទូតបារាំងហ្នឹងមានអ្នកទៅជ្រកកោកក្នុងហ្នឹងប្រហែលជាប៉ុន្មាននាក់ដែរ?

[១៣:៥៤:៥៣]

**ឆៈ** សូមអធ្យាស្រ័យ ខ្ញុំមិនអាចដឹងទេ។ ខ្ញុំសូមទោស។

**សៈ** ខ្ញុំចង់សួរអំពីហេតុការណ៍ដែលកើតឡើងនៅថ្ងៃអាទិត្យ ថ្ងៃទី២០ មេសា ៧៥។ លោកប្រហែលជាបានរៀបរាប់អំពីហេតុការណ៍ហ្នឹងហើយ ក៏ប៉ុន្តែខ្ញុំចង់ឲ្យលោករៀបរាប់ជូនយើងខ្ញុំតាមលទ្ធភាពរបស់លោកនៅថ្ងៃដែលប្រជាជនជាតិនៅក្នុងស្ថានទូតបារាំងនោះតម្រូវឲ្យចាកចេញពីស្ថានទូតនោះ តើលោកចាំច្បាស់ទេហេតុការណ៍ហ្នឹង?

[១៣:៥៥:៤៦]

**ឆៈ** គឺថានៅថ្ងៃនោះ វាងងឹត ពពកច្រើនមេឃ ហើយគឺថាមានការលាគ្នារវាងអ្នកដែលជាជនជាតិខ្មែរដែលត្រូវចាកចេញពីស្ថានទូតហ្នឹង អ្នកដែលមិនអាចចាកចេញពីស្ថានទូតហ្នឹងបាន។ ខ្ញុំពិបាករៀបរាប់ណាស់ មានមិត្តរបស់ខ្ញុំពីរបីនាក់ដែរ ហើយប៉ុន្មានឆ្នាំក្រោយមក ទើបខ្ញុំរៀបរាប់ហេតុការណ៍កើតឡើងចំពោះមិត្តខ្ញុំពីរបីនាក់ហ្នឹង។ ចំពោះជនជាតិកម្ពុជានៅក្នុងស្ថានទូតនោះវិញ ហើយខ្ញុំស្គាល់តែម្នាក់ទេគឺ ឱត ប្រន។

**សៈ** តើលោកអាចសង្កេតឃើញថា នៅពេលដែលប្រជាជនចាកចេញពីស្ថានទូតបារាំង តើ

ប្រជាជនដែលឲ្យចេញពីស្ថានទូតបារាំងនោះ គឺត្រូវបានគេជម្លៀសឲ្យចេញពីទីក្រុងភ្នំពេញដូចប្រជាជនដូចប្រជាជនដែលគេជម្លៀសថ្ងៃមុនៗនោះដែរឬទេ?

**ធ៖** បុគ្គលទាំងអស់ហ្នឹង គឺត្រូវតែដើរទៅទិសខាងជើង ក្រុមទាហាន គ្រួសារ។ ខ្ញុំមិនច្បាស់ទេ ហើយដោយសារវាយូរហើយ យូរច្រើនឆ្នាំហើយ ខ្ញុំមិនដឹងទេ។ ក្រោយពីចាកចេញពីស្ថានទូតបារាំងនោះគឺថា ឮសំឡេងកាំភ្លើងបាញ់ដែរ ដែលនៅខាងជើងស្ថានទូតបារាំង ហើយអ្នកខ្លះថា គេបាញ់កាំភ្លើងហ្នឹងដោយសារតែបំបែកពពក មេឃកំពុងតែភ្លៀង គេនិយាយអ៊ីចឹង។ ប៉ុន្តែប៉ុន្មានឆ្នាំក្រោយមក ខ្ញុំទទួលព័ត៌មានថា នៅក្រៅបរិវេណស្ថានទូតនោះ ប្រជាជនដែលគេបណ្តេញចេញពីស្ថានទូតត្រូវបានគេបាញ់សម្លាប់ចោល។ ខ្ញុំមិនដឹងច្បាស់ទេ គឺខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹង ពាក់ព័ន្ធទៅនឹងបញ្ហាបាញ់កាំភ្លើង ស្នូរកាំភ្លើងហ្នឹង។

[១៣:៥៧:៥២]

**ស៖** នៅពេលណាដែរ ដែល ស៊ីសុវត្ថិ សិរិមតៈ ចាកចេញពីស្ថានទូតបារាំង? តើលោកឮហេតុការណ៍ហ្នឹងនៅពេលណាដែរ?

**ធ៖** នៅពេលនោះឃើញថាខ្ញុំមិនឮអ្វីទេភ្លាមៗនោះ ពីរបីថ្ងៃក្រោយមកមានការពិភាក្សា ហើយខ្ញុំឃើញថា អ្នកកាសែតបារាំងនោះ គឺគេមិនបានចែករំលែកព័ត៌មានឲ្យយើងបានដឹងច្បាស់លាស់នោះទេ តែខ្ញុំដឹងក្រោយពេលដែលខ្ញុំចាកចេញពីប្រទេសកម្ពុជាទេ ទើបគេប្រាប់ឲ្យខ្ញុំដឹងជាក់លាក់។

**ស៖** លោកបានលើកឡើងអំពីក្រុមមួយទៀត គឺក្រុមទាហាន។ គឺលោកលើកឡើងអំពីក្រុមទាហានហ្នឹង គឺក្រុមណាដែរ? ជាក្រុមដែល ជាក្រុមអ្នកព្រៃភ្នំហ្នឹង ឬក៏យ៉ាងណាដែរ?

**ធ៖** បាទ គឺថាអ្នកខ្លះនោះជាអ្នកព្រៃភ្នំ។ អ្នកខ្លះរស់នៅតាមព្រំដែនវៀតណាម គឺដូចជានៅតាមព្រំដែនវៀតណាម ហើយមានប្រជាជននៅតាម រស់នៅតាមភ្នំនោះ គឺយើងឃើញមានដែរ ហើយមានកងកម្លាំងវៀតណាមដែលត្រូវបានគេចាប់ខ្លួនមក។ ហើយមានការកាត់ទោសប្រហារជីវិតដែរទៅលើបុគ្គលមួយចំនួនដែលថារត់មកប្រទេសកម្ពុជា ហើយត្រូវបានគេចាប់យកទៅវិញនោះ។ ហើយយើងឃើញថា មានប្រជាជនមួយចំនួនជាជនជាតិភាគតិចរស់នៅខាងកើតទន្លេមេគង្គ។ ហើយចំពោះខ្មែរក្រហមដែលចាប់ខ្លួនបុគ្គលមួយចំនួន ក្រុមមួយទៀតនោះ គឺថាយើងឃើញ ប៉ាដូ, ក្រុម ប៉ាដូ នោះ លោក ប៉ាដូ មកទីក្រុងភ្នំពេញ ហើយខ្ញុំជួបគាត់ ខ្ញុំស្គាល់គាត់។ គាត់ប្រាប់ខ្ញុំ អំពីទីតាំងដែលនៅ២០ម៉ាលនោះ ពីទីក្រុងភ្នំពេញ។ ដូច្នេះហើយនៅពេលដែលគាត់នៅទីនោះ ខ្មែរក្រហមយាមកាម គឺគាត់មិនអាច

ចេញទៅណានោះទេ។ ខ្មែរក្រហមរាប់រយនាក់ គឺថាធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញ។ បុគ្គលមួយចំនួននោះ គឺថាមានប្ដីប្រពន្ធ កូនចៅរត់ចេញទៅ ហើយយើងឃើញថាពួកគេព្យាយាមរត់គេចខ្លួន។ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់នោះ គឺលោក ប៉ាដូ នេះ គឺថាគាត់ឃើញខ្ញុំផងដែរ ហើយយើងក៏បានជួបគ្នានៅថ្ងៃ ១២ ខែមេសា។ គាត់ក៏បានយកបុគ្គលមួយចំនួនយកទៅដាក់នៅក្នុងស្ថានទូតបារាំងផងដែរ។

[១៤:00:៥១]

**ស៖** ក្រុមជនទាហានដែលជាអ្នកព្រៃភ្នំនោះ តើគេវៃប្រឆាំងដើម្បីអ្វីដែរ? គឺថាគេនៅខាងវៀតណាម ធ្វើសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ឬក៏គេនៅខាងក្រុមខ្មែរក្រហម?

**ឆ៖** ពួកគាត់ហ្នឹង គឺថានៅខាងអាមេរិក មកជាមួយនឹងពួកវៀតណាម ក៏ប៉ុន្តែវាមានបញ្ហាឈ្លោះគ្នារវាងវៀតណាម និងក្រុមទាហានដែលរស់នៅតាមព្រៃភ្នំ ដែលមានការបះបោរ។ ពួកគេវៃនៅក្នុងស្រុករបស់ពួកគេ ហើយគឺថាក្រុមអ្នកទាហានជាអ្នកព្រៃភ្នំនេះ គឺថានៅរួមជាមួយនឹងអាមេរិក ធ្វើការងារស្និទ្ធស្នាលជាមួយនឹងអាមេរិក។ យើងឃើញថាមានក្រុមមួយចំនួននៅក្នុងក្រុមហ្នឹង គឺថាជាជនជាតិភាគតិចដែលនៅតាមព្រៃភ្នំ ក្រៅពីហ្នឹងគឺថាជាជនជាតិខ្មែរ។ យើងឃើញថា លោក ប៉ាដូ នេះ មានសាច់ញាតិនៅក្នុងប្រទេសកម្ពុជា គឺគាត់ជាអ្នកព្រៃ -- លោក ប៉ាដូ នេះគឺគាត់ជាអ្នកព្រៃភ្នំ រស់នៅតាមព្រៃភ្នំ ក៏ប៉ុន្តែគាត់មានសាច់ញាតិបងប្អូនជាជនជាតិខ្មែរ។

**ស៖** តើលោកអាចពន្យល់បានទេ អំពីតួនាទីពេញលេញរបស់ពួកគេ?

**ឆ៖** ខ្ញុំសូមប្រើប្រាស់ការពន្យល់របស់ខ្ញុំ គឺថាការ -- គឺថានេះគឺជាការប្រើប្រាស់ពាក្យបារាំងដែលមានន័យថា ក្រុមហ្វូលរ៉ូ នោះឯង។

[១៤:0២:៣២]

**ស៖** លោកបាននិយាយប៉ុន្មាននាទីមុននេះថា លោកនៅជាមួយពួកគេនៅពេលដែលក្រុមជនជាតិភាគតិចនេះត្រូវបានគេបង្ខំឱ្យចាកចេញពីស្ថានទូត។ តើលោកអាចប្រាប់បានដែរឬទេ តើលោកបានសង្កេតឃើញអ្វីនៅពេលដែលគេបណ្ដេញពួកជនជាតិភាគតិចឱ្យចេញពីស្ថានទូតបារាំងនោះ?

**ឆ៖** ហ្វុលប៉ាដូ ជាមួយនិងប្រពន្ធរបស់គាត់ បានគេឱ្យចាកចេញពីទូតបារាំង នៅពេលនោះទាហានកម្ពុជាដែលធ្វើប្រតិបត្តិការជាមួយកាកបាទក្រហមបានស្លាប់ ហើយគេបានបញ្ចុះសាកសពនៅទីនោះ។ ខ្ញុំគិតថា នៅពេលនោះពួកគេប្រហែលជាយកតាមខ្លួនមាសមួយគីឡូ ពីរគីឡូ ហើយនិងមានគ្រឿងអលង្ការមួយចំនួនផងដែរ។ ហើយមុនពេលដែលគេធ្វើការដឹកជញ្ជូនចេញហ្នឹង គេរុំមាសជាមួយ

នឹងគ្រាប់បែក ឬក៏គ្រាប់រំសេវផ្សេងៗ ហើយគេកប់បញ្ចុះទៅ។ ហើយក្រោយមកទៀត គឺគេបានចាកចេញពីទីនោះទៅ។ នេះគឺជាអ្វីដែលខ្ញុំបានសង្កេតឃើញ។ ក្រៅពីនេះទៀត ប្រហែលជាគេទទួលនូវវាសនាប្រហាក់ប្រហែលគ្នា គឺគេចាកចេញដោយស្ងប់ស្ងៀម គឺថាខ្ញុំមិនដឹងថាតើវាមានអ្វីឲ្យច្បាស់លាស់នោះទេ។

[១៤:០៤:០៥]

**ស៖** ប្រធានបទចុងក្រោយដែលខ្ញុំចង់សាកសួរលោក គឺទាក់ទងទៅនឹងការធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញរបស់លោក គឺលោកចាកចេញពីប្រទេសកម្ពុជា។ តើលោកអាចប្រាប់បានដែរឬទេ? តើលោកចាកចេញពីស្ថានទូតបារាំង ហើយចាកចេញពីប្រទេសកម្ពុជាហ្នឹងតាមរបៀបណា?

**ផ៖** ជនបរទេសត្រូវបានគេបំបែកចេញជាពីរក្រុម គឺក្រុមទី១ ត្រូវបានគេដឹកតាមឡាន ក្រោយមកពីរថ្ងៃត្រូវបានគេដឹកចេញតាមឡាន គឺឡានចិន ដែលគេដឹក២៤នាក់ ក្នុងមួយឡាន។ ហើយវាមានប្រាំមួយកៅអីដែលយើងអង្គុយ ហើយខ្ញុំអង្គុយនៅកណ្តាល ហើយយើងមានអីវ៉ាន់តាមជាមួយផង។ អ្នកបើកឡានគឺជាខ្មែរក្រហម ហើយមានទូតបារាំងគេតាមមើលជាមួយនោះដែរ។ ឡានដឹកមនុស្សនោះបានចាកចេញតាមផ្លូវមុនីវង្សបត់ស្តាំទៅព្រលានយន្តហោះ។ នៅព្រលានយន្តហោះនោះ គឺមានទង់ពណ៌ក្រហមធំមួយ ឡានបើកហួសព្រលានយន្តហោះប្រហែលជាប៉ុន្មានគីឡូ ហើយបត់ស្តាំ បត់ឆ្វេងមកវិញ។ យើងបានចេញពីឡាន ហើយយើងចូលទៅផ្លូវធ្វើដំណើរមួយទៀត។ ក្បួនឡាននោះបានបើកស្របតាមផ្លូវវិមានរដ្ឋាភិបាល ប៉ុន្តែយើងចុះទៅផ្លូវតូចទេ មិនមែនបើកតាមផ្លូវធំនោះឡើយ។ គិតថាប្រហែលជាបើកតាមផ្លូវជាតិលេខ៥ ប្រហែលជាផ្លូវឆ្ពោះទៅឧដុង្គប្រសិនបើយើងទៅខាងស្តាំយើងទៅដល់ឧដុង្គ។ ហើយយើងបើកយឺតនៅពេលដែលយើងមកដល់ផ្លូវនេះ ហើយនៅពេលនោះគឺទាហានខ្មែរក្រហមបានប្រាប់យើងឲ្យទៅផ្អែកបន្ត។ ដូច្នេះបានន័យថា យើងចំណាយពេលវេលាច្រើនដើម្បីធ្វើដំណើរនៅក្នុងទីក្រុងនេះ។ គឺយើងធ្វើដំណើរប្រហែលជា ២ថ្ងៃកន្លះដើម្បីទៅដល់ព្រំដែន។

[១៤:០៦:៣៤]

**ស៖** នៅពេលដែលលោកបើកចេញពីទីក្រុងភ្នំពេញ តើលោកអាចពិពណ៌នាបានទេថាលោកសង្កេតឃើញយ៉ាងម៉េចដែរនៅក្នុងទីក្រុងភ្នំពេញនោះ? គឺនៅពេលដែលលោកធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញ លោកសង្កេតឃើញអ្វីខ្លះ?

**ផ៖** គឺមានការផ្លាស់ប្តូរខ្លាំងដោយសារគ្មានមនុស្ស មានមនុស្សតិចតួចបំផុត។ នៅពេលដែល

យើងឃើញមនុស្សៗនោះសុទ្ធតែជាពួកខ្មែរក្រហម អត់ឃើញជនស៊ីវិលនោះទេ។ ក្រុមមនុស្សដែលខ្ញុំមើលឃើញហ្នឹង គឺទាហានខ្មែរក្រហមហាក់ដូចជាគេកំពុងហ្វឹកហាត់នៅក្បែរស្ថានីយ៍រថភ្លើង។ ហើយនៅតាមផ្លូវទៅព្រលានយន្តហោះអត់មានអ្វីទាំងអស់ លើកលែងតែម្តងម្កាលយើងឃើញទាហានខ្មែរក្រហមពីរបីនាក់តាមផ្លូវ ឬក៏នៅតាមចំណុចប្រសព្វនានា។

**ស៖** នៅពេលដែលលោកធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជា តើលោកឆ្លងកាត់ទីក្រុង ឬទីរួមខេត្តដទៃទៀតដែរឬទេ? តើលោកសង្កេតឃើញអ្វីខ្លះនៅពេលដែលលោកធ្វើដំណើរឆ្លងកាត់ទីក្រុង ឬក៏ទីរួមខេត្តនៃខេត្តនានាក្នុងប្រទេសកម្ពុជានោះ លោកឃើញអ្វីខ្លះ?

**ឆ៖** យើងស្នាក់នៅ១យប់នៅវត្តមួយនៅបាត់ដំបង ហើយយើងចាកចេញមុនពេលដែលថ្ងៃរះ ដូច្នេះខ្ញុំមិនបានឃើញអ្វីឲ្យច្បាស់នៅក្នុងខេត្តបាត់ដំបងនោះទេ។

[១៤:០៨:២៨]

**លោក ខេល លីសាក់៖**

លោក រ៉ុក្ខហ្វ ខ្ញុំមិនមានសំណួរបន្ថែមទៀតទេ ហើយសហការីខ្ញុំក៏ប្រហែលមិនមានអ្វីសួរដែរ។

លោកប្រធាន យើងព្យាយាមទទួលឯកសារមួយចំនួនពីខាង ឌី.ស៊ី.ខេម ហើយយើងនឹងបញ្ជូនទៅដល់ភាគីនានា។ ហើយខ្ញុំគិតថាលោកសាក្សី គាត់មានហ្វីលរូបថតនៅសហរដ្ឋអាមេរិក ដូច្នេះយើងអាចស្នើសុំដល់គាត់នៅពេលក្រោយ ប៉ុន្តែយើងចាប់អារម្មណ៍ចំពោះការទទួលបានរូបថតជាក្រដាសដែលលោកបានថតនៅក្រសួងព័ត៌មាន ហើយលោកថាមានជាខ្សែវីដេអូទៀតផងនោះ។ ប៉ុន្តែ នេះគឺជាអ្វីដែលយើងអាចស្នើសុំទៅគាត់នៅពេលក្រោយ។ ប៉ុន្តែក្នុងពេលឥឡូវនេះយើងមិនមានអ្វីចោទសួរលោកទៀតទេ ហើយយើងសូមថ្លែងអំណរគុណដល់លោកដែលបានផ្តល់ឱកាសមកទីនេះដើម្បីឆ្លើយនូវសំណួរទាំងអស់នេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិការជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ ជម្រាបសួរលោកសាក្សី។ ខ្ញុំជាសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ខ្ញុំសួរសំណួរ បន្ថែមទៅលើលោកមួយចំនួន។ សំណួរទាំងអស់នេះគ្រាន់តែជាសំណួរសួរបន្តពីសហព្រះរាជអាជ្ញា ដើម្បីខ្ញុំចង់បានព័ត៌មានលម្អិតបន្ថែមពីលោក។ ដូច្នេះវាជាការសួរបន្តពីខាងសហព្រះរាជអាជ្ញា។ លោកជាអ្នកថតរូប ដូច្នេះសូមឲ្យខ្ញុំសួរសំណួរដែលមិនត្រឹមតែពាក់ព័ន្ធទៅនឹងមុខរបររបស់លោកទេ គឺពាក់ព័ន្ធទៅនឹងរឿងហេតុដែលថាលោកនៅពេលនោះ គឺថានៅរយៈពេល២ឆ្នាំនៅកម្ពុជា ហើយប្រហែលជាអាចលោកបានឃើញរឿងហេតុផ្ទាល់ខ្លួនមួយចំនួន ហើយលោកអាចនិយាយលម្អិតជូនយើងខ្ញុំបាន។ សំណួរទី១របស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងរយៈពេលមុនថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ព្រោះថាលោកនៅកម្ពុជាប្រហែលជា២ឆ្នាំមកហើយ នៅពេលនោះ ហើយកាលពីព្រឹកមិញនេះ លោកបានបញ្ជាក់ជូនសហព្រះរាជអាជ្ញាថាលោកពិបាក គឺថាមានការពិបាកចេញពីភ្នំពេញតាំងពីឆ្នាំ៧៣, ៧៤ ហើយនិងដើមឆ្នាំ៧៥។ ក្រៅពីកំពង់ឆ្នាំងដែលលោកបានទៅកាលពីខែតុលា ឆ្នាំ៧៤ ថាតើនៅពេលនោះលោកទៅទីណាដែរលោកសាក្សី?

[១៤:១១:២២]

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** អ្វីដែលខ្ញុំនិយាយថា យើងពិបាកចេញហ្នឹង គឺដោយសារតែផ្លូវជាតិភាគច្រើនត្រូវបានគេផ្ដាច់ដោយពួកខ្មែរក្រហម ហើយទាហានរដ្ឋាភិបាលហាក់ដូចជាព្យាយាមប្រឹងជួសជុល ជាពិសេសគឺផ្លូវជាតិលេខ៤ទៅកំពង់ស្ពឺគឺពិបាក។ ខ្ញុំបានទៅសៀមរាបនៅពេលដែលរដ្ឋាភិបាលទៅប្រាសាទមួយទៀតនៅជិតអង្គរវត្ត ដែលជា -- ហើយចំពោះខេត្តកំពង់ឆ្នាំងគឺមានបញ្ហាមួយសាដែរ គឺរបួសម្ដងពីរដងនៅទីនោះ គឺនៅជិតអង្គស្នួល ក៏ជាកន្លែងមួយមានបញ្ហាផងដែរ គឺមុនពេលដែលខ្មែរក្រហមដណ្ដើមបានអង្គស្នួល ហើយក្រោយមករដ្ឋាភិបាលដណ្ដើមយកវិញ។ ដូច្នេះនេះគឺជាបញ្ហា។ ស្ថានភាពនៅពេលនោះគឺវាមានបញ្ហាបែបនេះ។ ពេលខ្លះយើងអាចទៅ ពេលខ្លះយើងមិនអាចទៅ។ ប្រសិនបើយើងចង់ទៅទីរួមខេត្តវិញ គឺយើងអាចទៅជាមួយពួកកងទ័ពកម្ពុជាបាន។ ប៉ុន្តែកន្លែងភាគច្រើនដែលខ្ញុំធ្លាប់ទៅ គឺកាលខ្ញុំទៅតាមផ្លូវ ឬមួយក៏ទៅតាមវាលស្រែប៉ុណ្ណោះ។ សូមទោសដែលខ្ញុំមិនអាចផ្ដល់នូវព័ត៌មានលម្អិតឲ្យលោកស្រីបាន។

[១៤:១៣:១២]

E1/165.1

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា លោកទៅតែតំបន់ដែលមិនមែនកាន់កាប់ដោយខ្មែរក្រហមទេ គឺកាន់កាប់ដោយកងទ័ព លន់ នល់ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំគិតថាខ្មែរក្រហមមិនឲ្យខ្ញុំទៅជាមួយពួកគេទេ គឺយើងមិនអាចទៅកន្លែងរំដោះបានទេ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកធ្វើដំណើរទៅកន្លែងផ្សេងៗនោះ តើលោកធ្លាប់ឃើញអ្នកដែលភៀសខ្លួនចេញមកពីតំបន់ដែលកាន់កាប់ដោយខ្មែរក្រហមឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ឃើញច្រើនដង។

**ស៖** តើលោកអាចប្រាប់បានទេថា អ្នកទាំងអស់នោះបានរៀបរាប់អ្វីខ្លះ ដូចជាឧទាហរណ៍តើនៅពេលនោះពួកគេមានបានរៀបរាប់អ្វីខ្លះប្រាប់លោកដែរ នៅពេលដែលលោកជួបពួកគេនោះ?

**ឆ៖** ខ្ញុំអាចនិយាយថា ខ្ញុំមានឱកាសសួរពួកគេអំពីស្ថានភាពនានា ហើយការសម្ភាសភាគច្រើនគឺធ្វើឡើងដោយភ្នាក់ងារជនភៀសខ្លួន នៅពេលដែលជនភៀសខ្លួនទាំងអស់នោះត្រូវបានគេបញ្ជូនទៅជំរំជនភៀសខ្លួន។ ខ្ញុំធ្លាប់ឮរឿងដែលជាលក្ខណៈប្រាប់ដោយប្រយោលនោះទេ ប៉ុន្តែខ្ញុំមិនមានឱកាសឲ្យបានគ្រប់គ្រាន់ ដើម្បីជជែកដោយផ្ទាល់ជាមួយនឹងជនភៀសខ្លួនទាំងអស់នោះទេ។ តាមពិតទៅគឺនៅអូតែលកាំបូឌីយ៉ាណា នៅសណ្ឋាគារកាំបូឌយ៉ាណា គឺមានភ្នាក់ងារជនភៀសខ្លួនយ៉ាងច្រើន ដែលមានបោះទីតាំងនៅទីនោះ។

[១៤:១៥:១៣]

**ស៖** ខ្ញុំនិយាយនេះគឺថា សំដៅទៅដល់កន្លែងដែលលោកធ្វើដំណើរទៅ ហើយបន្ទាប់មកខ្ញុំនឹងនិយាយអំពីជនភៀសខ្លួនដែលនៅទីក្រុងភ្នំពេញ។ ឥឡូវនេះខ្ញុំសូមចូលទៅប្រភេទសំណួរផ្សេងទៀត។ ក្នុងចន្លោះឆ្នាំ៧៣ ដល់ឆ្នាំ៧៥ លោកនៅទីនេះជាមួយនឹងអ្នកសារព័ត៌មាន ហើយជាមួយនឹងអ្នកដែលមានទទួលបានការបណ្ដុះបណ្ដាលត្រឹមត្រូវ។ តើពួកគេយល់យ៉ាងណាដែរចំពោះគោលនយោបាយរបស់ខ្មែរក្រហមនៅរយៈពេល២ឆ្នាំមុនពេលរំដោះទីក្រុងភ្នំពេនោះ? ខ្ញុំសំដៅដល់ក្រុមរបស់លោក ឬក៏អ្នកដែលនៅទីក្រុងភ្នំពេញ តើពួកគាត់យល់យ៉ាងម៉េចដែរអំពីគោលនយោបាយរបស់ខ្មែរក្រហមក្នុងរយៈពេល២ឆ្នាំមុនរំដោះនោះ?

[១៤:១៦:០០]

**ឆ៖** ខ្ញុំធ្លាប់ឮច្រើនដង ហើយជាពិសេសប៉ុន្មានខែចុងក្រោយនៃពេលសង្គ្រាមហ្នឹង។ នៅពេលដែលសង្គ្រាមបញ្ចប់ទាំងអស់គ្នានឹងត្រឡប់ទៅកន្លែងដែលគាត់ធ្លាប់រស់នៅ ដោយសារតែមានជនភៀស

ខ្លួនជាង២លាននាក់នៅទីក្រុងភ្នំពេញ។ ដូច្នេះហើយគឺថា ពួកអ្នកភៀសខ្លួនហ្នឹងគាត់គិតជាព័ត៌មានដ៏ល្អ។ ចំពោះប្រជាជនខ្មែរដែលចំណាយលុយរាប់លាន ដើម្បីជួយទៅដល់ប្រទេសកម្ពុជានុ៎ងគឺថា ប្រហែលតាមដែលខ្ញុំស្តាប់ឮតាមវិទ្យុ គឺថាព័ត៌មានត្រូវបានគេផ្ញើទៅវិញទៅមក ហើយខ្ញុំមិនដឹងថាយើងគួរជឿ ឬមិនជឿនោះទេ ចំពោះព័ត៌មានទាំងអស់នេះ។ ប៉ុន្តែអ្វីដែលគេទទួលយកបានទាំងអស់គ្នា គឺការត្រឡប់ទៅផ្ទះវិញ គឺគេត្រឡប់ទៅភូមិកំណើតវិញ ក្រោយពេលចប់សង្គ្រាមនោះ គឺគេយល់ព្រមទាំងអស់គ្នា។

**សៈ** តើមានការនិយាយអំពីរបៀបរស់នៅរបស់ខ្មែរក្រហម ហើយនិងប្រជាជនដែលបានរស់នៅជាមួយខ្មែរក្រហមទេ? គឺខ្ញុំសំដៅទៅដល់នយោបាយ ហើយនិងការអនុវត្តនយោបាយផ្សេងៗរបស់ខ្មែរក្រហមនោះ។

**ឆៈ** ខ្ញុំមិនអាចឆ្លើយប្រាប់លោកស្រីទៅលើសំណួរនេះបានទេ សូមអភ័យទោស។

**សៈ** សូមអរគុណ។ លោកបាននិយាយអំពីជនភៀសខ្លួន ដែលបានមកដល់ទីក្រុងភ្នំពេញ ចេញពីតំបន់រំដោះ ហើយលោកបាននិយាយថា មានមនុស្សជាច្រើនភៀសចេញពីតំបន់រំដោះមក។ តើលោកមានចងចាំទេថាអ្នកភៀសខ្លួនទាំងអស់នោះបានរៀបរាប់អ្វីខ្លះពីតំបន់កាន់កាប់ដោយខ្មែរក្រហមនេះ? សូមលោកអត្ថាធិប្បាយឲ្យបានលម្អិតជាងមុនបន្តិច។

**ឆៈ** ខ្ញុំសង្ឃឹមថា ខ្ញុំអាចឆ្លុះអារម្មណ៍ ប៉ុន្តែខ្ញុំមិនអាចនោះ។ ខ្ញុំមិនមែនជាអ្នកដែលបានសម្ភាសជនភៀសខ្លួន ដូច្នេះខ្ញុំមិនអាចឆ្លើយទៅនឹងសំណួរនេះបានទេ។ សូមអភ័យទោស។

[១៤:១៨:៤០]

**សៈ** ទោះបីជាគេមិនបានឆ្លើយប្រាប់លោកក៏ដោយ ក៏ប៉ុន្តែលោកអាចប្រាប់បានទេថាមានមិត្តភក្តិរបស់លោក ឬក៏មានអ្នកណាផ្សេងនោះប្រាប់លោកអំពីបញ្ហានេះជូនលោកដែរឬទេ?

**ឆៈ** អត់មានអីទាំងអស់ គេអត់មានប្រាប់ខ្ញុំអ្វីទាំងអស់។ ជាទូទៅគេមានតែសួរខ្ញុំវិញទេ គេអត់មានប្រាប់ខ្ញុំទេ គេសួរខ្ញុំទៅវិញ។

**សៈ** សូមអរគុណលោកសាក្សី។ លោកបាននិយាយអំពីកងទ័ព ហើយនិងទាហានដែលមកដល់ទីក្រុងភ្នំពេញ ហើយលោកបានថតរូបពួកទាហានទាំងអស់នោះ។ ហើយលោកនិយាយថា មានក្មេងៗជំទង់ៗជាច្រើន និងមានយុវជនផងដែរ។ តើមនុស្សថ្ងៃទី១៧ មេសា ឆ្នាំ៧៥ លោកធ្លាប់ឮគេនិយាយអំពីកងទ័ពខ្មែរក្រហម ហើយលោកមានធ្លាប់ឮការអត្ថាធិប្បាយអំពីកងទ័ពទាំងអស់នោះ ថាមានសមាសភាពយ៉ាងម៉េច? ថាតើគេរើសយកមនុស្សយកមកចូលធ្វើទាហាននេះយ៉ាងម៉េច? លោកធ្លាប់ឮអំពីមិត្ត

ភក្តិរបស់លោក ឬក៏អ្នកដែលលោកបានជួបនោះ ថាពួកស្ថានភាពពួកគេហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** អត់មានទេ។

[១៤:២០:១៧]

**ស៖** តើមុនថ្ងៃទី១៧ មេសា ៧៥ នៅទីក្រុងភ្នំពេញ លោកធ្លាប់ឮគេនិយាយឈ្មោះមនុស្សដែលស្ថិតនៅក្នុងជួរថ្នាក់ដឹកនាំខ្មែរក្រហមដែរឬទេ មុនថ្ងៃទី១៧ មេសា នោះ? លោកធ្លាប់ឮឈ្មោះអ្នកដែលនៅក្នុងជួរថ្នាក់ដឹកនាំខ្មែរក្រហមទេ?

**ឆ៖** គឺថាមិនមានអ្វីឲ្យច្បាស់លាស់ទេ គឺថាមានមនុស្សម្នាក់នៅក្នុងក្រសួងព័ត៌មានដែលគាត់ធ្លាប់និយាយថា បងប្រុសរបស់គាត់មិនមកទីក្រុងភ្នំពេញក្នុងពេលឆាប់ៗនេះ។ ហើយបុគ្គលនេះឈ្មោះសោម -- សាឡុត ឆាយ បងប្អូនរបស់ សាឡុត ស។ ប៉ុន្តែគាត់មិនដឹងថាបងគាត់ហ្នឹងមានឋានៈខ្ពស់ប៉ុណ្ណានោះទេ។ គឺថាដោយសារតែគាត់មិនបានជួបគ្នាប៉ុណ្ណោះឯង គឺថានេះគឺជាអ្វីដែលខ្ញុំបានដឹង។

**ស៖** ហើយចាប់ពីថ្ងៃទី១៧ មេសា មក លោកបានឮឈ្មោះមេដឹកនាំខ្មែរក្រហមនោះ តើពេលនុ៎ងលោកឮទេពីក្រោយថ្ងៃ១៧ មេសា មកនោះ? ឮមានគេនិយាយឈ្មោះមេដឹកនាំខ្មែរក្រហមដែរឬទេ?

**ឆ៖** ខ្ញុំអត់មានឮគេនិយាយពីឈ្មោះ ឬក៏អត់មាននិយាយពីបុគ្គល ឬក៏មនុស្សណាម្នាក់នោះទេ អត់មានទេ។

**ស៖** នៅថ្ងៃ១៧ មេសា ខ្ញុំជឿថាលោកបានជួបបុគ្គលិកពេទ្យនៅមន្ទីរពេទ្យព្រះកេតុមាលា ហើយគេ -- កាលពីព្រឹកមិញនោះ លោកបានឆ្លើយថា គេបានឆ្លើយប្រាប់លោកថាខ្មែរក្រហមបញ្ជាឲ្យជម្លៀសមន្ទីរពេទ្យនោះ ហើយលោកៗទៅទីនោះ តើនៅពេលដែលលោកទៅដល់នោះ គេជម្លៀសចេញអស់ហើយឬនៅ មានអស់គ្រែ អត់មនុស្សអីចេញពីពេទ្យហើយ ឬក៏មិនទាន់ទេ ពេលដែលលោកទៅដល់?

[១៤:២២:៥៣]

**ឆ៖** នៅពេលនុ៎ងគឺមានគ្រែមួយចំនួន មានសាកសព ខ្ញុំមានរូបថត គឺមានសាកសពមួយចំនួននៅលើគ្រែ ខ្លះនៅលើឥដ្ឋ គឺឃើញតែសាកសព។ ខ្ញុំបានថតរូបជាច្រើនអំពីមន្ទីរពេទ្យនៅថ្ងៃនោះ មុនពេលដែលខ្ញុំដើរចេញមកក្រៅ ហើយត្រូវគេចាប់យកមក។ មន្ទីរពេទ្យព្រះកេតុមាលា ខ្ញុំស្គាល់ពេទ្យនោះដោយសារខ្ញុំធ្លាប់ទៅពីមុនមក ហើយក៏នៅក្បែរនោះក៏មានពេទ្យកុមារមួយផងដែរ គឺថានៅពេលនុ៎ង ខ្ញុំធ្លាប់ត្រូវបានគេដេញចេញនៅពេលដែលខ្ញុំថតរូប។ មន្ទីរពេទ្យព្រះកេតុមាលាហ្នឹង គឺ ដូចដែលខ្ញុំបាន

បញ្ជាក់ពីដើមរួចមកហើយថា នៅតាមបណ្ដោយផ្លូវសីហនុ និងមុនីវង្សក្បែរនុំង។ ហើយគេធ្លាប់ប្រាប់ខ្ញុំថាមន្ទីរពេទនុំងត្រូវបានគេជម្លៀសចេញ។ នេះគឺជាអ្វីដែលខ្ញុំដឹង។

**ស៖** ពាក់ព័ន្ធនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ លោកឆ្លើយជូនសហព្រះរាជអាជ្ញាថា ក្រុមគ្រួសារនានាត្រូវចាកចេញពីទីក្រុងភ្នំពេញ ហើយក្នុងនោះមានមនុស្សចាស់ មានកុមារ ហើយលោកឆ្លើយថាលោកឃើញមានអ្នកជំងឺដែលត្រូវចេញពីពេទ្យកាល់ម៉ែត ហើយដែរដើរកាត់ស្ពានទូតបារាំង។ តើលោកអាចផ្ដល់ព័ត៌មានលម្អិតបន្ថែមទៀតពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានឃើញអំពីការជម្លៀសនេះថាតើមានមនុស្សច្រើនដែរឬទេ? ហើយមានមនុស្សនុំងមានយកអីវ៉ាន់ទៅច្រើនតាមខ្លួនដែរឬទេ? ហើយមាកដឹកជញ្ជូនដោយខ្មែរក្រហមដែរឬទេ? ឬក៏ពួកគេដើរដោយខ្លួនឯង? ឬក៏ជិះកង់ដោយខ្លួនឯង? សូមលោកផ្ដល់ព័ត៌មានលម្អិតបន្ថែមឲ្យបានច្បាស់អំពីអ្វីដែលលោកបានឃើញដោយផ្ទាល់នៅថ្ងៃនោះ ហើយនិងថ្ងៃបន្តបន្ទាប់មកនៅពេលជម្លៀសចេញពីទីក្រុងនោះ?

[១៤:២៥:១៨]

**ឆ៖** ការជម្លៀសមិនអាចធ្វើឡើងក្នុង១ថ្ងៃទេ គឺវាត្រូវការពេលពីរបីថ្ងៃ គឺថាអ្នកជំងឺចាស់ៗឬក៏អ្នកដទៃទៀតត្រូវបានគេបណ្ដេញពីមន្ទីរពេទ្យនោះ គឺនៅថ្ងៃទី២នោះទេ តាមដែលខ្ញុំឃើញ។ ខ្ញុំមិនដឹងថាតើមានអ្វីកើតឡើងនៅមន្ទីរពេទ្យនៅថ្ងៃ១៧នោះទេ ខ្ញុំឃើញនៅពេលដែលគេដើរចេញពីមន្ទីរពេទ្យមកដើរកាត់តាមស្ពានទូតបារាំង ទើបខ្ញុំឃើញ។

**ស៖** ចុះគ្រួសារដែលលោកបានឃើញនោះ លោកអាចបញ្ជាក់ឲ្យបានលម្អិតលើសពីហ្នឹងបន្តិចទៀតបានទេ?

**ឆ៖** ខ្ញុំគិតថា ចំពោះគ្រួសារហ្នឹង គឺថាជាមួយនឹងមនុស្សជរាទាំងស្រី ទាំងប្រុស មានទាំងក្មេងទាំងចាស់ ខ្ញុំគិតថាវាជាគ្រួសារហើយនៅពេលដែលមនុស្សប្រុសមនុស្សស្រីក្មេងចាស់ដើរជាមួយគ្នានោះ។

**ស៖** តើពួកគេមានយកអីវ៉ាន់ទៅតាមខ្លួនទេ ហើយអីវ៉ាន់ហ្នឹងជាអីវ៉ាន់ប្រភេទណាដែរ ពួកគាត់ធ្វើដំណើរហ្នឹងយ៉ាងម៉េចដែរ ដើរដោយថ្មើរជើង ឬក៏មានមធ្យោបាយធ្វើដំណើរ?

**ឆ៖** ភាគច្រើនដើរ ប៉ុន្តែមានអ្នកខ្លះគាត់ជិះឡាន ជិះម៉ូតូដែរ។ ហើយអាចនឹងមានអ្នកខ្លះគាត់រុញឡាន ហើយនៅក្នុងឡានហ្នឹងមានអីវ៉ាន់ ឬក៏មានរបស់របរច្រើន។ ប៉ុន្តែអ្នកខ្លះទៀត គាត់អត់ខ្វល់ពីការរុញឡានទេ គាត់ដើរទៅ។ ប៉ុន្តែនៅពេលដែលគាត់ចាកចេញពីភ្នំពេញគឺគាត់ត្រូវបោះបង់ចោលនូវរបស់របរទាំងអស់នោះហើយ។ ហើយអាចនឹងមានកង់ម៉ូតូមួយចំនួនផងដែរនៅពេលនោះ។ ភាគច្រើន

គឺយើងអាចយកអីវ៉ាន់តិចតួចបានទេ ត្រឹមតែមួយយួរដៃអីប៉ុណ្ណឹង ព្រោះដោយសារតែការដើរ។

[១៤:២៧:២៨]

**ស៖** នៅពេលដែលលោកស្ថិតនៅក្នុងស្ថានទូតបារាំងជាមួយនឹងមនុស្សមួយចំនួនទៀតនោះ តើលោកអាចជម្រាបជូនយើងបានទេថាខ្មែរក្រហមបានផ្សព្វផ្សាយអ្វីខ្លះនៅតាមវិទ្យុ តើពួកគេមានផ្ដល់ព័ត៌មានអំពីការជម្លៀស និយាយអំពីនយោបាយ ឬក៏របបថ្មី ឬក៏របៀបនៃការអនុវត្តរបស់ខ្មែរក្រហមដែរឬទេនៅពេលនោះ?

**ឆ៖** ខ្ញុំមិនដឹងថាគេផ្សាយអ្វីតាមវិទ្យុទេ។ ខ្ញុំមានវិទ្យុ ខ្ញុំអាចស្ដាប់វិទ្យុ ប៊ី.ប៊ី.ស៊ី ឬក៏ជាដើម។ តែចំពោះវិទ្យុខ្មែរក្រហម គឺខ្ញុំអត់បានស្ដាប់ទេ។ ហើយចំពោះស្ថានទូតបារាំង ប្រហែលជាមានការតាមដានហើយ ព្រោះថាមានអ្នកសារព័ត៌មានមួយចំនួនគាត់មានទំនាក់ទំនងជាមួយអ្នកកាទូតបារាំង ឬក៏អ្នកកាទូតនានា ហើយគេផ្ដល់ព័ត៌មានដល់ពួកគាត់។ ហើយពួកទាំងអស់នោះ គេផ្ដល់ព័ត៌មានមកដល់យើង ហើយមានអ្នកកាសែតប្រហែលជាប្រាំ,ប្រាំមួយនាក់ដែលមានទំនាក់ទំនងជាមួយខាងស្ថានទូតបារាំង ដូចជា ស៊ីដនី សាន់ប៊ឺដ, ចន ស្វេន ហើយនិងអ្នកសារព័ត៌មានដទៃទៀតជាដើម។ ដូច្នេះពួកគាត់មានការប្រជុំនៅអគារមួយក្នុងស្ថានទូតបារាំង ចំណែកពួកយើងភាគច្រើន គឺអត់បានចូលរួមក្នុងការប្រជុំនោះទេ។

[១៤:២៨:៥៨]

ហើយខ្មែរក្រហមបានចូលមកក្នុងស្ថានទូតម្ដង ហើយដោយសារតែមានការផ្សាយព័ត៌មានខុសច្បាស់មកក្រៅហ្នឹង ទើបគេចូលមកក្នុងស្ថានទូត ដើម្បីស្វែងរកកន្លែងផ្សព្វផ្សាយព័ត៌មាននោះ ដើម្បីរកមើលតើអ្នកណាជាអ្នកផ្សព្វផ្សាយ។ ដូច្នេះហើយយើងដឹងតិចតួចបំផុតទាក់ទងទៅនឹងអ្វីដែលបានផ្សព្វផ្សាយតាមវិទ្យុនោះ។

**ស៖** សូមអរគុណលោកសាក្សី។ តើគេមានប្រាប់មូលហេតុច្បាស់លាស់ថា ហេតុអ្វីបានជាចាំបាច់ត្រូវជម្លៀសបរទេសចេញពីកម្ពុជាប្រជាធិបតេយ្យអស់នោះ? គេមានប្រាប់មូលហេតុទេ ហើយបើសិនជាប្រាប់នោះថាមូលហេតុអ្វីខ្លះដែរ?

**ឆ៖** គេមិនមានផ្ដល់មូលហេតុអ្វីនោះទេ គេអត់ប្រាប់ទេ។ យ៉ាងណាក៏ដោយមានខ្មែរក្រហមមួយរូបគាត់ប្រាប់យើងថា ពីរបីថ្ងៃក្រោយមក គឺយើងឃើញយន្តហោះប្រតិកម្មមួយបានបើកនៅលើទីក្រុងភ្នំពេញ ហើយបានប្រាប់ថា គឺជាយន្តហោះរបស់ចិន។ នេះគឺជាអ្វីដែលប្រធានាធិបតី និច សុន

ចង់ធ្វើ។ នៅពេលនោះ គឺយើងឃើញយន្តហោះនោះបើកនៅលើមេឃ ហើយយន្តហោះហ្នឹងមានកន្ទុយពណ៌ក្រហម។ យើងឆ្ងល់ថាអាហ្នឹងយន្តហោះអីដែរ។ នៅពេលដែលយើងមើលឲ្យច្បាស់ទៅគឺឃើញមានផ្កាយនៅលើកន្ទុយយន្តហោះពណ៌ក្រហមនោះ។ ហើយយន្តហោះហ្នឹងចុះនៅព្រលានយន្តហោះពោធិ៍ចិនតុង។

[១៤:៣០:០៦]

នៅពេលនោះអ្នកតំណាងខ្មែរក្រហមជាមួយនឹងមន្ត្រីទូតបារាំង បានមកជួបជាមួយយើង ហើយនិយាយជាមួយយើងមួយភ្លែត។ ពួកគេពិភាក្សាអំពីតម្រូវការម្ហូបអាហារ និងតម្រូវការផ្សេងៗ។ ហើយនៅពេលដែលអ្នកសារព័ត៌មានមួយរូបសួរថាតើយន្តហោះហ្នឹងមកដឹកពួកយើងឬមួយក៏ម៉េចដែរ? បុគ្គលនោះគាត់ព្យាយាមបញ្ជាក់ថា យន្តហោះហ្នឹងមិនមែនមកដឹកអស់លោកទេ ប៉ុន្តែអស់លោកនឹងចាកចេញគឺថាលោកនឹងចេញតាមផ្លូវគោកនោះទេ។ ហើយអ្នកសារព័ត៌មាននោះសួរថា ម៉េចក៏មិនឲ្យយើងជិះយន្តហោះ? គេឆ្លើយថា មកពីខ្មែរក្រហមចង់លោកឃើញថាឃើញធ្វើអ្វីបានខ្លះ។ ប៉ុន្តែតាមពិតទៅគេអត់មានបង្ហាញយើងថាគេធ្វើអ្វីបានខ្លះនោះទេ។ ប៉ុន្តែគេប្រាប់យើងថា គេឲ្យយើងទៅតាមផ្លូវគោក ដោយសារឲ្យយើងឃើញអ្វីដែលគេបានធ្វើនោះ។ ដូច្នេះយន្តហោះដែលបានចុះមកពីរដងហ្នឹង ខ្ញុំមិនដឹងថាតើគេមកធ្វើអ្វីនោះទេ ប្រហែលជានាំមន្ត្រីរដ្ឋាភិបាល ឬក៏យ៉ាងម៉េចខ្ញុំក៏មិនដឹងដែរ។ ប៉ុន្តែវាជាយន្តហោះចិនដែលធ្វើនៅអាមេរិក។

[១៤:៣២:២៣]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចូលដល់សំណួរចុងក្រោយ។ លោកបាននិយាយអំពីពេលដែលលោកចេញពីស្ថានទូតដើម្បីទៅប្រទេសថៃ ហើយលោកមានការភ្ញាក់ផ្អើលដែលថា ផ្លូវមានសភាពស្ងាត់ជ្រងំ ហើយលោកថា នៅបាត់ដំបងលោកទៅដល់ពេលយប់ ហើយមិនបានឃើញអ្វីនោះទេ។ ក្នុងអំឡុងពេលធ្វើដំណើរឆ្លងកាត់ផ្ទៃប្រទេសកម្ពុជានោះ តើលោកបានឃើញអ្វីខ្លះ ហើយមានអ្វីខ្លះដែលធ្វើឲ្យលោកភ្ញាក់ផ្អើលប៉ុន្មានថ្ងៃក្រោយពេលដែលវាយកទីក្រុងភ្នំពេញ ហើយនិងក្រោយពេលដែលខ្មែរក្រហមឡើងកាន់អំណាចនោះ?

**ឆ៖** គឺថា៣អាទិត្យក្រោយមកទើបខ្ញុំបានធ្វើដំណើរទៅ គឺថាយើងក្បួនឡានហ្នឹង គឺយើងឃើញធុំក្លិនស្រូវ ហើយក៏ធុំក្លិនសពខ្មោចដែលស្លាប់ដែរ គឺថាខ្មោចដែលត្រូវបានគេសម្លាប់ចោល។ យើងមិនទៅតាមផ្លូវជាតិលេខ៥ទេ ដែលនៅតាមផ្លូវជាតិលេខ៥នោះគឺថាមានភាពសាហាវឃោរឃៅ មានការ

កាប់សម្លាប់អ៊ីចឹងជាដើម។ យើងទៅតាមផ្លូវតូចៗ ខ្មែរក្រហមគ្រប់គ្រងយ៉ាងតឹងរ៉ឹងទៅលើអ្វីដែលយើងមើលឃើញ។ យើងទៅដល់វត្តមួយនៅក្នុងខេត្តបាត់ដំបង។ យើងមិនអាចឃើញអ្វីនោះទេ។ នៅពេលថ្ងៃគឺថាយើងចេញផុតពីទីប្រជុំជនខេត្តបាត់ដំបងរួចទៅហើយ។ ដូច្នេះ ខ្ញុំមិនដឹងថាមានអ្វីកើតឡើងនៅខេត្តបាត់ដំបងនោះឡើយ។

[១៤:៣៤:០៧]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណ។ ហើយខ្ញុំសូមឲ្យលោកឆ្លើយតែអ្វីដែលលោកឃើញប៉ុណ្ណោះ។ សូមអរគុណលោកសាក្សី។ ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១៤:៣៤ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី សូមសួរទៅអស់លោក លោកស្រីចៅក្រម ថាតើមានអស់លោក លោកស្រីចៅក្រមណាមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក រ៉ូកូហ្វ ខ្ញុំជាចៅក្រម ឡាវែន៍ ខ្ញុំមានសំណួរមួយចំនួនសួរបន្ថែមទៅកាន់លោក បន្ថែមទៅលើសំណួរដែលគេបានសួរទៅកាន់លោក។

[១៥:០៣:៣១]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ ជាបឋមខ្ញុំត្រឡប់មកនិយាយអំពីវគ្គមួយដែលលោកបាននិយាយជាច្រើន គឺជាវគ្គដែលនៅក្រសួងព័ត៌មាន។ បាទ ដើម្បីកំណត់កន្លែងនោះឲ្យច្បាស់លាស់នោះ តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើក្រសួងព័ត៌មាននោះមានទីតាំងនៅទីណាដែរ? តើលោកអាចបញ្ជាក់បានទេ ថានៅសព្វថ្ងៃនេះនៃអគារនៃក្រសួងហ្នឹងនៅមានដែរឬទេ? ហើយនៅក្នុងអគារនោះមានអ្វីដែរសព្វថ្ងៃយើងនេះ?

**លោក អាល់ រ៉ូកូហ្វ៖**

**ឆ៖** អគារគឺមានរហូតដល់សព្វថ្ងៃនេះ គឺនៅប្រើជាក្រសួងព័ត៌មាន គឺស្ថិតនៅតាមបណ្ដោយមហាវិថីដែលយើងជិះពីស្ថានីយរថភ្លើងទៅមាត់ទន្លេនុំង គឺនៅតាមផ្លូវនោះឯង។ ខ្ញុំមិនចាំថាប៉ុន្មានរយម៉ែត្រវ៉ារទេះភ្លើងទេ គឺប៉ុន្តែនៅក្បែរនោះដែរ។

[១៥:០៥:៤២]

**ស៖** បាទ ព្រឹត្តិការណ៍ដែលយើងនិយាយ គឺថាលោកនិយាយកាលពីព្រឹកមិញហ្នឹង គឺថាស្ថិតនៅក្នុងបរិវេណតូច ថានៅជុំវិញស្ថានទូតបារាំង គឺថាសណ្ឋាគារឡឺភ្នំ ឬក៏ក្រសួងព័ត៌មាន ហើយនិងសណ្ឋាគារដែលលោកស្នាក់នៅ។ តើលោកធ្លាប់បានទៅផ្នែកផ្សេងនៃទីក្រុងដែរឬទេ? ឧទាហរណ៍ដូចជាទៅខាងជើង តើស្ថានភាពនៅខាងត្បូងនោះដូចនៅខាងជើងទេ? តើមានអ្វីប្លែកគ្នាទេ រវាងផ្នែកមួយនឹងផ្នែកមួយនៅក្នុងទីក្រុងភ្នំពេញនេះ?

**ឆ៖** តំបន់នៅម្តុំវិមានឯករាជ្យនោះ ហើយនិងប្រហែលជាពី៣០០ម៉ែត្រខាងត្បូងហ្នឹង គឺមិនច្បាស់ទេនៅថ្ងៃ១៧ មេសា។ ខ្ញុំមិនបានទៅឆ្ងាយហួសពីហ្នឹងទៀតទេ ដោយសារតែប្រហែលជាពេលនុំងគឺមានជម្លៀសប្រជាជនប្រហែលជារាប់សែន។ ហើយគេធ្វើដំណើរទៅផ្នែកកណ្ដាលនៃទីក្រុងភ្នំពេញដោយសារតែមានការទម្លាក់គ្រាប់នៅខាងមុំទន្លេ មាត់ទន្លេ។ នៅថ្ងៃ១៧ មេសា នៅក្នុងសក្ខីកម្មពីមុន

របស់ខ្ញុំ ខ្ញុំទៅខាងត្បូងវិមានឯករាជ្យ ខ្ញុំទាហានខ្មែរក្រហមធ្វើដំណើរមកខាងជើង ហើយមានស្លៀកសម្លៀកបំពាក់គគ្រិច ហើយមានអាប្បកិរិយាមិនល្អល្ហើយ ហើយខ្ញុំគិតថាដូចជាមិនមានសុវត្ថិភាពប្រសិនបើខ្ញុំធ្វើដំណើរទៅខាងត្បូងតទៅមុខទៀត ដូច្នេះហើយខ្ញុំក៏មកខាងជើងវិញ។

[១៥:០៧:២៥]

**ស៖** បាទ លោកបានលើកឡើងថ្ងៃនេះថា មានការប្រែប្រួលបរិយាកាសនៅក្នុងទីក្រុងភ្នំពេញ។ កាលពីព្រឹកគឺថាមានសេចក្ដីរីករាយ ប្រជាជនគាត់សប្បាយរីករាយដោយឃើញថាសង្គ្រាមចប់ហើយ បន្ទាប់មកបរិយាកាសនេះប្រែប្រួល។ តើការប្រែប្រួលនេះចំពោះលោកនោះ ប្រែប្រួលភ្លាមៗតែម្ដង ឬក៏មានអ្វីមួយដែលបង្ហាញឲ្យយើងឃើញថា មិនមែនជាការងាយស្រួលទេ ក្នុងការមើលឃើញការប្រែប្រួលនេះ?

**ឆ៖** ខ្ញុំមិនអាចឆ្លើយបាន ថាតើវាភ្លាមៗ ឬមួយក៏យ៉ាងម៉េចនោះទេ ប៉ុន្តែនៅពេលថ្ងៃត្រង់គឺប្រជាជនត្រូវបានគេបណ្ដេញចេញទីក្រុង។ ចំពោះខ្ញុំវាហាក់ដូចជាពិបាកដែរ នៅពេលដែលយើងនៅម្ដុំស្ពានជប៉ុន គឺស្ពានជ្រោយចង្វានោះឯង គឺខ្ញុំឃើញប្រជាជនធ្វើដំណើរទៅខាងជើងតាមផ្លូវជាតិ។ ប៉ុន្តែមើលទៅប្រជាជនហាក់ដូចជាកម្សត់ ដូចជាពិបាកចិត្ត មិនមានអ្នកញញឹមច្រើនទេ មានអ្នកញញឹមតិចតួចមែនទែន។ គឺថាអារម្មណ៍របស់ប្រជាជនគឺពិតជាផ្លាស់ប្ដូរមែន ប៉ុន្តែខ្ញុំមិនប្រាកដថាគ្រប់កន្លែងនោះទេ ប៉ុន្តែខ្ញុំឃើញថាមានការផ្លាស់ប្ដូរប្រហែលជា២-៣ម៉ោងក្រោយនោះឯង។

[១៥:០៨:៤៩]

**ស៖** លោក រ៉ុក្ហូ ធ្លាប់ឮគេនិយាយអំពីមនុស្សម្នាក់ឈ្មោះហែម កេតដារ៉ា គឺថាជាចលនាជាតិនិយម។ លោកធ្លាប់ឮនិយាយអំពីចលនាជាតិនិយមនេះដែរឬទេ? ឬក៏រឿងដែលប្រហាក់ប្រហែលនេះ?

**ឆ៖** ខ្ញុំធ្លាប់ឮពីចលនានេះដែរ នៅពេលក្រោយមក គឺបន្ទាប់ពេលចាកចេញពីទីក្រុងភ្នំពេញ នៅពេលដែលខ្ញុំជួបជាមួយអ្នកសារព័ត៌មាននានា។ គឺថានិយាយអំពីអ្នកដែលបន្លំធ្វើជាខ្មែរក្រហម ខ្ញុំគិតថារឿងនេះកើតឡើងនៅក្រសួងនៅពេលព្រឹក ប៉ុន្តែមិនមានអ្វីឲ្យច្បាស់លាស់នោះទេ។ ប៉ុន្តែវាងាយស្រួលក្នុងការកំណត់ ដោយសារពួកគាត់ហ្នឹងពាក់ស្បែកជើងស្អាត ហើយមានសម្លៀកបំពាក់សមរម្យ មើលទៅគឺស្អាតជ្រុល ឬក៏យើងអាចនិយាយថា សុខភាពល្អខ្លាំងពេកមិនសមជាខ្មែរក្រហមនោះទេ។ ដូច្នេះនៅពេលរសៀលខ្ញុំ សាន់ប៊ឺជ ហើយនិង ចន ស្វេន បានចូលទៅក្នុងក្រសួងហើយបានឃើញមនុស្សនោះដែរ។

[១៥:១០:00]

**ស៖** លោកសាក្សី តើលោកធ្លាប់ទៅក្រសួងព័ត៌មានតែមួយដង ឬក៏ពីរដងនៅថ្ងៃទី១៧ មេសា? តើលោកទៅពេលព្រឹក ទាំងពេលព្រឹក ទាំងពេលល្ងាច ឬក៏ទៅតែពេលរសៀសនោះទេ?

**ឆ៖** ខ្ញុំទៅទាំងពីរ ទាំងពេលព្រឹក ទៅជួបក្រុមខ្មែរក្រហមដែលមកដល់មាត់ច្រកចូល ហើយប្រសិនបើតាមរូបថត គឺថាយើងឃើញថាស្រមោលហ្នឹងគឺបញ្ជាក់ថាស្រមោលនៅពេលព្រឹក ព្រោះថាស្រមោលពីខាងកើតទៅខាងលិច។ ហើយពេលរសៀលគឺខ្ញុំទៅប្រហែលជាម៉ោងបួន ឬជិតប្រាំនុំង គឺស្រមោលហ្នឹងគឺឃើញផ្ទុយមកវិញ។ គឺថាខ្ញុំទៅក្នុងក្រសួងហ្នឹងគឺទៅទាំងពីរដង ទៅគោលដៅខុសៗគ្នា។ ព្រោះថាគេប្រាប់ខ្ញុំឲ្យទាំងពីរដងនោះឯង។

**ស៖** បើដូច្នេះ ដោយជាក់លាក់តែម្តង តើគេមានប្រាប់លោកអំពីមូលហេតុច្បាស់លាស់ដែរឬទេ មូលហេតុដែលលោកទៅក្រសួងព័ត៌មាននោះ?

[១៥:១១:១៨]

**ឆ៖** យើងទៅក្រសួងគឺថាដើម្បីទៅជួប ខិត ប្រន ដើម្បីប្រាប់ ស៊ីដនី សាន់ប៊ឺជ នៅក្រសួងនោះ។ ហើយដំបូងគឺយើងត្រូវធ្វើដំណើរការដោយថ្មើរជើង ហើយបន្ទាប់មកគេដេញមកខាងក្រៅ ហើយគេឲ្យយើងចូលទៅក្នុង។ ខ្ញុំគិតថាវាជាមូលហេតុដែលយើងទៅទីនោះ។

**ស៖** លោកនិយាយអម្បាញ់មិញថា លោកមានអារម្មណ៍ហាក់ដូចជាមួយខ្មែរក្រហមដែលចាប់លោកនោះក្នុងចំណោមពួកគេ អ្នកខ្លះគេមានទំនាក់ទំនងជាមួយថ្នាក់លើរបស់គេ ដោយសារហេតុនេះហើយបានជាលោកត្រូវបានគេដោះលែងវិញ។ តាមលោកនោះ តើថ្នាក់លើរបស់ខ្មែរក្រហមនេះហើយឬដែលបញ្ជាឲ្យលោកទៅក្រសួងព័ត៌មាននោះ ឬក៏ខ្មែរក្រហមតូចតាចនោះដែលចាប់លោកដោយខ្លួនឯងតែម្តង មិនមានបញ្ជាចេញពីមកពីថ្នាក់លើនោះទេ?

**ឆ៖** ខ្ញុំគិតថា មិនមែនពួកខ្មែរក្រហមដែលចាប់យើងពេលដំបូងនៅពេទ្យព្រះកេតុមាលានោះទេ។ គិតថាប្រហែលជាមានពួកថ្នាក់លើដែលបញ្ជាឲ្យនាំយើងទៅទីនោះ។ គឺពួកអ្នកដែលគ្រប់គ្រងនៅតំបន់មុំស្ពានជ្រោយចង្វានោះជាអ្នកបញ្ជា។

[១៥:១២:៥៧]

**ស៖** ខ្ញុំសូមឲ្យផ្នែកសោតទស្សន៍នោះបង្ហាញរូបភាពមួយដែលយើងបានឃើញពីព្រឹកមិញនៅក្នុងសម្រង់វីដេអូដែលខាងសហព្រះរាជអាជ្ញាបានស្នើសុំឲ្យចាក់កាលពីព្រឹកមិញ គឺលេខកូដ គឺថា “ប៉ុល

ពត *ឌឹ ឃើលលីង អេមប្រេស"* ដែលមាន D108/32.2R។ បាទ នេះគឺជារូបភាពមាននៅនាទី២៥:៤១ សឹហ្គុង -- វិនាទី។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ដូច្នេះសូមអនុញ្ញាតបញ្ចាំងរូបនេះនៅលើអេក្រង់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអនុញ្ញាត! អ្នកជំនាញខាងសោតទស្សន៍ចាក់វីដេអូឃ្លីបផ្សាយតាម -- លើអេក្រង់កុំព្យូទ័រតាមការស្នើសុំរបស់លោកចៅក្រម!

[១៥:១៣:៥៥]

*(ការបង្ហាញឯកសារជាវីដេអូ)*

[១៥:១៤:០៤]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ លោកសាក្សី តើលោកស្គាល់រូបនេះទេ? តើលោកពិតជាម្ចាស់រូបថតនេះមែនទេ?

**លោក អាល់ រ៉ុក្វហ្វ៖**

**ឆ៖** បាទ គឺខ្ញុំជាអ្នកថត គឺខ្ញុំថតនៅពេលព្រឹក គឺនៅច្រកចូលទៅក្រសួង គឺនៅពេលព្រឹក។

**ស៖** បើដូច្នេះ លោកបានប្រាប់យើងថារូបថតនេះថតនៅពេលព្រឹក ក៏ប៉ុន្តែមិនមែនថតនៅពេលរសៀលនោះទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើលោកអាចពិពណ៌នាអំពីអ្វីដែលកើតឡើងនៅពេលនោះដែរឬទេ? គឺថានេះយើងមើលឃើញមានយោធាដែលមានអាវុធ តើនៅលើរូបថតនោះ ជនស៊ីវិលនេះជាអ្នកណាដែរ?

[១៥:១៥:០៩]

**ឆ៖** បុគ្គលដែលពាក់អាវសនៅជិតមាត់ទ្វារនោះប្រហែលជាបុគ្គលិករបស់ក្រសួង គឺគាត់នៅក្នុងក្រសួងនោះនៅពេលដែលពួកទាហានមកដល់។ ហើយចំណុចមួយទៀតដែលខ្ញុំចង់បញ្ជាក់ គឺថានៅពេលដែលយើងឃើញមនុស្សរត់ឡើងជណ្តើរនោះ គឺជាខ្មែរក្រហម។ គឺជាក្រុមពួកខ្មែរក្រហមដែលយើងបានបញ្ជាក់ពីមុននោះ គឺពួកខ្មែរក្រហមដែលមានស្បែកជើងស្អាតនោះ គឺមិនមែននោះទេ។ គឺថាពួកនោះមានសម្លៀកពាក់ស្អាត ហើយមើលទៅវាមានសុខភាពល្អ ស្បែកជើងអីស្អាតត្រឹមត្រូវគឺពួកនេះ។

[១៥:១៥:៥០]

**ស៖** បាទ ដូច្នេះខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានផ្ដល់រូបថតមួយចំនួនទៅភាគី គឺថាជារូបថតដែលមានចំណាត់ថ្នាក់សាធារណៈ ហើយរូបថតទាំងអស់នេះមានរូបថតមួយដែលយើងមើលឃើញទីកន្លែងច្បាស់លាស់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បើអ៊ីចឹងខ្ញុំសូមអនុញ្ញាតផ្ដល់រូបថតនេះទៅឲ្យសាក្សី គឺរូបថតលេខ៤ ហើយក៏សូមអនុញ្ញាតបញ្ចាំងលើអេក្រង់ផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំមិនដឹងថាអាចបញ្ចាំងរូបនេះនៅលើអេក្រង់បានដែរឬទេ? បាទ ខ្ញុំសូមឲ្យពង្រីករូបនេះទាំងស្រុងតែម្ដងដើម្បីមើលឃើញទាំងអស់។ បាទ រូបថតនេះវាមិនសូវច្បាស់ទេ។ បាទ ខ្ញុំមើលទៅឃើញដូចមានការលំបាកក្នុងការបង្ហាញឲ្យឃើញទាំងមូល។ បាទ ដូច្នេះ គឺថាភាគីទាំងអស់អាចទទួលឯកសារនេះបានហើយ។ ខ្ញុំសូមជម្រាបជូនថា រូបថតទាំងស្រុងនេះ គឺថាបើយើងមើលរូបថតនេះពេញតែម្ដងនោះ យើងឃើញមានអក្សរសរសេរថា ក្រសួងព័ត៌មាននៅច្រកចូល។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** តើលោកអាចបញ្ជាក់ថា រូបថតនេះពិតជារូបថតដែលលោកថតដោយផ្ទាល់ដៃលោកមែនទេ?

[១៥:១៨:១៥]

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** ខ្ញុំដឹងថានេះជារូបថតដែលខ្ញុំថត ទោះបីថារូបហ្នឹងត្រូវបានគេយកមកកាត់ចេញមួយចំនួនក៏ដោយ ហើយម្យ៉ាងទៀតយកមកទៅគុណភាពវាមិនច្បាស់ក៏ដោយ ប៉ុន្តែខ្ញុំនៅតែស្គាល់ថានេះជារូបថតដែលខ្ញុំបានថតពិតមែន។

**ស៖** បាទ អម្បាញ់មិញនេះ លោកបាននិយាយថា លោកធ្លាប់ជួបមនុស្សម្នាក់នៅក្រសួង

ឃោសនាការដែលមានឈ្មោះថា សាឡុត ឆាយ ដែលបាននិយាយអំពីបងរបស់គាត់ទៅកាន់លោក ហើយបើសិនជាខ្ញុំយល់មិនច្រឡំទេ គឺថាបងគាត់នោះឈ្មោះ សាឡុត ស។ ខ្ញុំសួរលោកថា តើលោកស្គាល់លោក សាឡុត ឆាយ នេះច្បាស់លាស់ដែរឬទេ?

**ឆ៖** តាមពិតទៅ យើងមិនដែលជួបគាត់ទេ ហើយខ្ញុំក៏មិនដែលនិយាយជាមួយបងរបស់គាត់ដែរ។ ប៉ុន្តែគាត់ហ្នឹងនៅក្រសួងព័ត៌មាន ហើយដោយសារនៅក្នុងសង្គ្រាមហ្នឹង គឺមានប្រជាជនបាត់បង់បងប្អូនគ្នាជាច្រើន ហើយ សាឡុត ឆាយ បានប្រាប់ថាបងគាត់នឹងត្រឡប់មកទីក្រុងភ្នំពេញវិញ។ ហើយគាត់ដដែលៗទៅលើចំណុចនេះ។ ហើយគាត់បានបញ្ជាក់ថានៅពេលនោះ គាត់មិនដឹងថាតើបងគាត់ហ្នឹងមានតួនាទីធំប៉ុន្មាននោះទេ។ គាត់គឺជាបងប្អូនដែលបានបាត់បង់នោះ គឺចំពោះគាត់ គាត់គិតថាបងប្រុសរបស់គាត់ សាឡុត ស ហ្នឹងគ្រាន់ជាមេទ័ពមួយប៉ុណ្ណោះ។ គាត់មិនដឹងថាតើបងគាត់មានតួនាទីធំប៉ុនណានោះទេ។

[១៥:១៩:៥៧]

**ស៖** តើ សាឡុត ឆាយ ហ្នឹងគាត់មានឋានៈ ឬក៏មុខងារជាផ្លូវការអីនៅក្រសួងឃោសនាការហ្នឹងដែរឬទេ? តើគាត់មានទំនួលខុសត្រូវណាមួយជាក់លាក់ទេ នៅក្នុងក្រសួងហ្នឹង? តើលោកដឹងមុខងារគាត់ជាក់លាក់ទេ?

**ឆ៖** ខ្ញុំមិនអាចឆ្លើយបានទេ ខ្ញុំមិនដឹងថាតើគាត់មានតួនាទីអ្វីឲ្យជាក់លាក់នោះទេ។ ហើយខ្ញុំក៏មិនដែលទំនាក់ទំនងជាមួយគាត់នោះដែរ។ គាត់គ្រាន់តែប្រាប់ថា បងគាត់នៅភាគីម្ខាងទៀតប៉ុណ្ណោះ។

**ស៖** បាទ ឥឡូវនេះខ្ញុំសូមនិយាយនឹងវគ្គមួយនៅស្ថានទូតបារាំង បើលោកបាននិយាយយ៉ាងយូរអំពីអ្វីដែលកើតឡើង បាទឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយលម្អិតអំពីការព្រាត់គ្នា ឬក៏ការចាកចេញនៃជនអៀសខ្លួនខ្មែរ ឬក៏ការបំបែកពួកគាត់ចេញពីគ្នានៅស្ថានទូតបារាំង។ តើលោកអាចជម្រាបជូនតុលាការបានទេថា ការធ្វើបែបនេះប្រព្រឹត្តទៅរបៀបណាដែរ? ឧទាហរណ៍ដូចជាចំពោះគ្រួសារដែលជាគ្រួសារ ដែលជាប្រពន្ធជនជាតិផ្សេង ប្តីជនជាតិផ្សេង ដែលប្តីប្រពន្ធជនជាតិខុសគ្នានោះ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើការប្រព្រឹត្តចំពោះពួកគាត់ហ្នឹងមានលក្ខណៈយ៉ាងម៉េចដែរ ការដូចថា មានការបញ្ជាអ្វីជាក់លាក់ទេ?

[១៥:២១:៥៤]

**ឆ៖** ខ្ញុំអត់ដឹងថាមានអ្វីកើតឡើងបន្ទាប់ពីមនុស្សទាំងនោះបានចាកចេញពីទូតនោះទេ។ ខ្ញុំចាំតែ

អ្វីដែលកើតឡើងនៅទូត ប៉ុន្តែនៅពេលដែលចេញពីទូតខ្ញុំអត់ដឹងទេ។ ខ្ញុំមានហេតុការណ៍សោកនាដកម្មមួយគឺថា ស្ត្រីជនជាតិបារាំងម្នាក់គាត់មានប្តីជាជនជាតិខ្មែរនៅពេលនោះគឺទោះបីថាមានឯកសារគ្រប់គ្រាន់ក៏ដោយពួកខ្មែរក្រហមថាប្តីជនជាតិខ្មែរនេះ មិនអាចទៅតាមប្រពន្ធជនជាតិបារាំងបាននោះទេ។ នៅពេលនោះប្រហែលជា នៅពេលដែលគេប្រាប់ប្រហែលជា ១០-១៥នាទីក្រោយមកគេក៏បណ្តេញប្តីជនជាតិខ្មែរឲ្យចេញពីស្ថានទូត នៅពេលនោះអាចនឹងមានការប្រែប្រួលប៉ុន្តែប្តីជនជាតិខ្មែរនោះបានចេញពីស្ថានទូតបាត់ទៅហើយ។ នេះគឺជាហេតុការណ៍មួយដែលខ្ញុំបានឃើញ ហើយមានអ្នកសារព័ត៌មានជាច្រើនគាត់កត់ត្រានូវហេតុការណ៍នេះ។ ហើយមានអ្នកខ្លះមួយចំនួនទៀតត្រូវបានគេបណ្តេញចេញដែរដោយសារតែមិនមានឯកសារគ្រប់គ្រាន់។ ហើយអ្នកខ្លះអាចនៅរស់រាន អាចនៅបានដោយសារតែមានឯកសារក្លែងក្លាយ ឬក៏ឯកសារដែលមិនពិតគេអាចផ្ទុកនៅទីនោះបាន។ ចំពោះហេតុការណ៍ សោកនាដកម្មដែលថាប្តីខ្មែរប្រពន្ធបារាំងនៅពេលដែលប្តីគាត់ដើរចេញប្រហែល១៥នាទីមក ទើបគេប្រាប់ថា ប្តីអាចនៅជាមួយប្រពន្ធបាន ប៉ុន្តែប្តីបានចេញផុតពីស្ថានទូតរួចទៅហើយ។

**ស៖** បាទ ទោះបីជាមានការបញ្ជាយ៉ាងដូច្នេះតើមានអ្នកខ្លះដែលអាចរួចផុតពីការឃ្លាំមើលរបស់ខ្មែរក្រហមហើយនិងអាចចេញទៅតាមខ្សែឡាននោះទៅប្រទេសថៃដែរឬទេ? តើមានអ្នកណា អាចគេចខ្លួនរួចដែរឬទេ? គេចខ្លួនរួចអំពីអាជ្ញាធរខ្មែរក្រហម?

[១៥:២៤:00]

**ធ៖** ខ្ញុំឃើញមានករណីពីរបីដែរ ដែលកើតឡើងគឺទាក់ទងទៅនឹងការជម្លៀសតាមក្បួនរថយន្តហ្នឹង នៅពេលនុ៎ងខ្មែរក្រហមត្រូវរាប់ចំនួនប្រជាជនដែលមាន២៤នាក់ក្នុងមួយឡាន ប៉ុន្តែនៅពេលដែលខ្មែរក្រហមរាប់គឺរាប់ឡើងដល់ទៅ២៥។ ហើយនៅពេលនោះគឺមានជនជាតិបារាំងម្នាក់នៅជាមួយប្រពន្ធ ឬក៏សង្សារខ្ញុំមិនច្បាស់ទេ។ គឺថាធ្វើដំណើរជាមួយគ្នា គាត់ដឹងថាមានអ្វីកើតឡើង គាត់លោតចេញពីឡានដើរទៅកៀន ហើយពេលនោះទាហានខ្មែរក្រហមមិនបានរាប់ គឺរាប់ឃើញតែ២៤។ គាត់ដើរទៅឡានមួយទៀតគឺនៅពេលដែលគាត់ទៅរាប់ឡានថ្មីមួយទៀត គឺជនជាតិបារាំងនោះត្រឡប់មកជិះឡានហ្នឹងឡើងវិញ។ ដូច្នេះឡើងចំនួនហ្នឹងដល់២៥ នៅក្នុងឡានហ្នឹង គឺខ្មែរក្រហមរាប់ច្រឡំ។

**ស៖** បើតាមលោកដឹង ថាតើមានជនជាតិបរទេសដែលអាចរួចផុតពីការជម្លៀសចេញហ្នឹងដែរទេ ឬក៏ថាការជម្លៀសហ្នឹងគឺថាជម្លៀសជនជាតិបរទេសទាំងអស់តែម្តង? តើលោកមានឃើញអ្នកការទូតដែរឬទេ ហើយនិងប្លុកកុម្មុយនីស្តជាដើម?

**ឆ៖** ខ្ញុំឃើញពួកខាងអាល្លឺម៉ង់ខាងកើតដើរចេញពីស្ថានទូត ហើយចូលមកស្ថានទូតវិញ។ ហើយគាត់បានដាក់នូវលក្ខខណ្ឌមួយចំនួន ហើយក៏មានករណីនៃការស្នើសុំចំណីអាហារ។ នេះគឺជាអ្វីដែលបានកើតឡើងនៅទីនោះ គឺក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ។ ប៉ុន្តែយ៉ាងណាក៏ដោយជនជាតិអាល្លឺម៉ង់ខាងកើតហ្នឹងត្រូវទុកម្ហូបអាហារនៅក្នុងកន្លែងរួមគ្នាហ្នឹង គឺថាមិនអាចយកទៅតាមខ្លួនបាននោះទេ។ ប្រសិនបើមានអ្នកការទូតដទៃទៀតចូលមក គឺត្រូវចូលមកស្ថានទូតនេះឯង គឺប្រហែលជាមិនមានអ្វីផ្សេងនោះទេ គឺមានតែចូលមកក្នុងស្ថានទូតនេះ។ ព្រោះថា នៅពេលនោះគឺថាខ្មែរក្រហមហាក់ដូចជារំភើបជាមួយជោគជ័យ ដូច្នេះគេមិនបានគិតឲ្យបានច្បាស់លាស់នោះទេ។

[១៥:២៦:៤៥]

**ស៖** នៅពេលដែលជនភៀសខ្លួនខ្មែរនៅក្នុងស្ថានទូតបារាំង ដែលបង្ខំចិត្តចាកចេញពីស្ថានទូតនោះ តើអាជ្ញាធរបារាំងនៅពេលនោះ ឬក៏បុគ្គលិកស្ថានទូតបារាំង ឧទាហរណ៍ដូចជាប៉ូលិសនៅស្ថានទូតហ្នឹងជាដើម ពួកគេនោះមានធ្វើសកម្មភាពជាក់លាក់ណាមួយ ដើម្បីរក្សាពួកគេនៅស្ថានទូត ដេញចេញពួកគេចេញពីស្ថានទូតបារាំង ដេញជនភៀសខ្លួនទាំងអស់នោះចេញពីស្ថានទូតបារាំង ឬក៏មានការគំរាមកំហែងអំពីសំណាក់ខ្មែរក្រហមទៅលើស្ថានទូត?

**ឆ៖** បុគ្គលដែលមិនមានសិទ្ធិត្រូវបានគេបណ្តេញចេញ ហើយខ្មែរក្រហមចូលមកមើលស្ថានទូតច្រើនដង។ ដូច្នេះហើយគឺគេត្រូវបណ្តេញចេញពីស្ថានទូត ហើយនៅពេលដែលខ្មែរក្រហមចូលមកស្ថានទូត គឺត្រូវមានមន្ត្រីទូតអមដំណើរមកជាមួយ។ ហើយនៅពេលដែលពួកទាហានខ្មែរក្រហមចូលមកម្តងៗ គឺមានការដើរអមដោយស្ថានទូត។ ប៉ុន្តែនៅចំពោះបរិវេណខាងក្រៅស្ថានទូត គឺពួកខ្មែរក្រហមបានដើររុករកមើលនៅតាមជុំវិញស្ថានទូតផងដែរ។ ខ្ញុំមិនអាចជម្រាបថាតើដោយសារមូលហេតុអ្វីទេ ប៉ុន្តែបរិយាកាសវាមើលទៅមានការគំរាមកំហែង និងកៀបសង្កត់ខ្លាំងនៅខាងក្រៅ។

**ស៖** នៅក្នុងចំណោមឥស្សរជននៃរបបសាធារណរដ្ឋ លន់ នល់ ដែលចូលមកក្នុងស្ថានទូតបារាំងនោះ តើលោកមានឃើញថាអ្នកខ្លះហ្នឹង ក្នុងចំណោមឥស្សរជនទាំងអស់ហ្នឹង មានអ្នកណាដែលស្ថានទូតបារាំងបណ្តេញចេញពីស្ថានទូតដែរឬទេ?

[១៥:២៨:៤៦]

**ឆ៖** ខ្ញុំមិនមានវត្តមាននៅទីនោះទេ នៅពេលដែល ស៊ីសុវត្ថិ សិរិមតៈ ត្រូវបានគេបណ្តេញចេញពីស្ថានទូតនោះ។ ខ្ញុំមិនអាចឆ្លើយបានទេ សូមអភ័យទោស។

**ស៖** អម្បាញ់មិញនេះ គឺលោកបាននិយាយអំពីការចាកចេញនៃប្រជាជន ហើយលោកក៏បាននិយាយដែរថា ឮសូរស្នូរកាំភ្លើងនៅពេលណាមួយនោះ ហើយបន្ទាប់មកទៀត គឺថាមានការនិយាយថា ជនភៀសខ្លួនទាំងអស់នោះប្រហែលជាទៅអគារម្ភុំអគារកីឡា គឺថាទៅបុរីកីឡា។ តើបុរីកីឡាហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** កន្លែងនុ៎ងគឺនៅខាងជើងស្ពានទូតបារាំង គឺនៅភាគខាងជើងស្ពានទូតបារាំង។ ខ្ញុំមិនដឹងឈ្មោះអ្វីទេ។ សូមអភ័យទោស។

**ស៖** ខ្ញុំប្រហែលជា បើសិនជាខ្ញុំមិនច្រឡំទេ ឥឡូវរាល់ថ្ងៃនេះគេហៅថា ស្តាតចាស់ បើមិនអ៊ីចឹងទេគេហៅឈ្មោះថា ស្តាតឡាំពៃ។ នៅពេលដែលលោកបាននិយាយថា លោកបានឮស្នូរកាំភ្លើងនោះ តើពេលលោកឮស្នូរកាំភ្លើងនោះ ក្រោយពេលដែលជនភៀសខ្លួននោះចេញយូរហើយ ហើយលោកឮស្នូរកាំភ្លើងនោះច្រើនគ្រាប់ ឬក៏យ៉ាងម៉េច បើតាមលោកចាំនោះយ៉ាងម៉េចដែរ?

[១៥:៣០:៣១]

**ឆ៖** ការបាញ់កាំភ្លើងនេះមិនច្រើនទេ ពីរបីគ្រាប់តែប៉ុណ្ណោះ មនុស្សពីរបីនាក់ត្រូវបានគេបាញ់។ ហើយប៉ុន្តែវាមិនជាអ្វីចម្លែកទេ នៅក្នុងពេលដែលអាកាសធាតុដែលវាមិនស្រួល ដូចជាមានពពកខ្មៅភ្លៀងអ៊ីចឹង គឺថាជាទូទៅយើងឃើញបាញ់កាំភ្លើងឡើងទៅលើ ដើម្បីបំបែកខ្យល់ ឬពពកអ៊ីចឹង។ ដូច្នេះគឺខ្ញុំគិតថា មិនមែនបាញ់ឡើងទៅលើ បាញ់ឡើងទៅលើនោះទេ គឺថាខ្ញុំដឹងថាគេបាញ់យ៉ាងម៉េចទៅលើនៅពេលនោះ ខ្ញុំដឹងថាគឺមានការបាញ់។ ខ្ញុំបានឮសំឡេងបាញ់កាំភ្លើងនៅក្រៅទីក្រុងភ្នំពេញ ១អាទិត្យក្រោយពេលទីក្រុងភ្នំពេញដួលរលំ។ ដូច្នេះហើយវាគ្មានអ្វីដែលថាចម្លែកនោះទេ។

**ស៖** បាទ លោកសាក្សី យើងដូចជាមិនយល់គ្នាប៉ុន្មានទេ។ ខ្ញុំគួរតែសូមឲ្យលោកមកជាមួយនឹងរូបថតមួយចំនួនដែលលោកបានថត ក៏ប៉ុន្តែយើងមិនបានធ្វើការងារនេះឲ្យទាន់ពេលវេលា។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ គឺថាមានរូបថតលោកមួយចំនួនដែលគេស្គាល់ ហើយដែលយើងអាចរកឃើញនៅក្នុងអ៊ីនធឺណេតផងដែរ។ ហើយអ៊ីចឹងខ្ញុំសូមអនុញ្ញាតបញ្ចាំងរូបថតលោកមួយចំនួន ហើយនិងសូមផ្តល់រូបថតនេះជូនទៅលោក ហើយដើម្បីចង់ដឹងថាតើលោកពិតជាម្ចាស់រូបថតនេះមែនឬទេ ហើយនិងឲ្យលោកធ្វើការកត់សម្គាល់។ ដូច្នេះខ្ញុំសូមបង្ហាញរូបថតទាំងអស់នេះ។ ខ្ញុំគិតថាមានរូបថតចំនួនបួន គឺថាក្នុងនោះមានមួយដែលយើងបានបង្ហាញហើយហើយកាលពីព្រឹកមិញ គឺជារូបថតដែលយើងថត -- ដែលលោកថតនៅមុខក្រសួងឃោសនាការ។

[១៥:៣២:៤០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារ -- ផ្តល់រូបថតនេះទៅលោកសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមអនុញ្ញាតបញ្ចាំងរូបថតទី១ លើអេក្រង់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មានអត្តសញ្ញាណសម្គាល់ទេ? មានលេខសម្គាល់ទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ គឺជាឯកសារថ្មី ដោយសារឯកសារនេះមិនមាននៅក្នុងសំណុំរឿងទេ រូបថតដែលនៅក្នុងសំណុំរឿងនោះត្រូវបានបង្ហាញកាលពីព្រឹកមិញទៅសាក្សីហើយ។ ហើយរូប -- បាទសូមឲ្យយក ក៏ប៉ុន្តែបានផ្តល់រូបថតទាំងអស់នេះទៅមន្ត្រីតុលាការដើម្បីបង្ហាញនៅល្ងាចនេះ -- រសៀលនេះ។ រូបថតទី១ គឺថាទាហានក្មេងម្នាក់ដែលស្លាយ -- ដែលលីកាំភ្លើង។ បាទ ឥឡូវឃើញរូបចេញមកហើយ។

[១៥:៣៤:១៨]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បាទ តើលោកអាចជម្រាបជូនតុលាការបានទេ តើរូបនេះជារូបរបស់លោក? ហើយរូបនេះតំណាងឲ្យអ្វីដែរ?

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** ខ្ញុំថតរូបថតនេះ ខ្ញុំជឿគឺថានៅចុងឆ្នាំ៧៣ ប្រហែលចុងឆ្នាំ៧៣ ឬដើមឆ្នាំ៧៤ នៅតាមផ្លូវជាតិលេខ៥ ជិតភ្នំប្រសិទ្ធ ហើយគឺទាហាននេះលីកាំភ្លើងអឹមសី ហើយគាត់បានពាក់មួកមានផ្កានៅពីលើហ្នឹង។ បាទ គឺថាផ្កាហ្នឹងមិនមែនដាក់នៅពីលើក្បាលតែម្តងទេ គឺថាដាក់ភ្ជាប់នឹងមួក។

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមបង្ហាញរូបថតទី២ ដែលនៅលើរូបថតនោះមានទាហានក្មេងមួយរូបដែលមួយនាក់ដែលកំពុងតែកាន់កាំភ្លើងរបស់ខ្លួន។ អ៊ីចឹងសូមបង្ហាញរូបថតនេះ។

បាទ សំណួរដដែលនេះ តើលោកអាចចាំទេ ថារូបថតនេះថតនៅកន្លែងណា ហើយនៅពេល

ណា? ហើយរូបថតនេះលោកចង់បង្ហាញអ្វីដែរនៅក្នុងរូបថតនេះ?

**ឆ៖** គឺជាទាហានរបស់រដ្ឋាភិបាល លន់ នល់។ ខ្ញុំមិនចាំច្បាស់ទេ ខ្ញុំថតនៅកន្លែងណា ប៉ុន្តែខ្ញុំដឹងថាថតនៅក្នុងឆ្នាំ១៩៧៥។

**ស៖** ព្រឹកមិញលោកបាននិយាយថា នៅក្នុងចំណោមជនរងគ្រោះនៃសង្គ្រាមនេះ គឺថាមានលោកបានកត់សម្គាល់ថាទាហាននោះក្មេងមែនទែន តើនៅលើរូបថតនេះ លោកអាចធ្វើការប៉ាន់ស្មានទាហាននេះអាយុប្រហែលប៉ុន្មានដែរ?

[១៥:៣៦:៤៥]

**ឆ៖** បាទ ប្រហែលជាអាយុ១៦ ឬ១៧ គឺមិនលើស១៨ទេ។

**ស៖** បាទ សូមអរគុណ។ បាទឥឡូវយើង ខ្ញុំសូមបង្ហាញរូបថតទី៣ ដែលថតនៅលើផ្លូវ ហើយអ៊ីចឹងសូមបញ្ចាំងរូបថតនេះនៅលើអេក្រង់។ សំណួរគឺថាតើលោកជាអ្នកថតរូបនេះ ឬក៏យ៉ាងម៉េច? ហើយលោកអាចជម្រាបជូនបានទេ តើរូបថតនេះតំណាងឲ្យអ្វីដែរ? ហើយដូចជាអ្នកដែលយើងមើលឃើញនៅខាងឆ្វេងដៃនេះនៅលើចិញ្ចើមផ្លូវនេះណ៎ា តើអ្នកនុ៎ងជាអ្នកណាដែរ?

**ឆ៖** ខ្ញុំថតរូបថតនេះនៅថ្ងៃទី១៧ មេសា ពេលព្រឹកព្រលឹម ពេលព្រឹកជិតពេលថ្ងៃត្រង់ ហើយខ្ញុំដឹងថានៅទីនេះគឺថាមានទាហាននៅខាងស្តាំកន្លែងដើរ។ ហើយយើងឃើញថាកន្លែងនេះគឺថាពីរប្លុកតែប៉ុណ្ណោះ ពីផ្លូវបំបែកមហាវិថីព្រះសីហនុ និងមហាវិថីព្រះមុនីវង្ស។ នេះគឺយើងឃើញថារូបថតហ្នឹងមើលទៅឃើញរូបថតដែលបង្ហាញនូវរោងភាពយន្ត។ ខ្ញុំអាចសន្មតថានៅវ៉ស្បានេះ ជិតវ៉ស្បាគឺថាទាហានរបស់ លន់ នល់ ហើយគឺជាទូទៅគឺថាទាហាន លន់ នល់ គឺមិនអាចដើរតាមផ្លូវផ្ដេសផ្ដាសបានទេ បើសិនជាមិនដូច្នោះទេ គេបាញ់សម្លាប់ចោល។ គឺនៅផ្លូវបំបែកផ្សេងទៀតគឺថាយើងមានឮសំឡេងយើងឃើញមានការប្រមូលផ្តុំកាំភ្លើង ហើយក៏ឃើញគេបណ្តើរទាហានចាកចេញទៅផងដែរ។ ទាហាននេះគឺថាក៏មានទាហានខ្មែរក្រហមនៅក្នុងហ្នឹងដែរ ហើយខ្ញុំដើរជាមួយទាហាននោះប្រហែលជា១២, ១៣នាក់ ហើយខ្ញុំដើរពីក្រោយបុគ្គលហ្នឹងពេលខ្លះទៅ ហើយពេលខ្លះទៀតខ្ញុំដើរជាមួយនឹងហ្វូងទាហាន។ សូមអធ្យាស្រ័យគឺថារូបថតនេះផ្ដិតទៅមិនច្បាស់ទេ ហើយបើសិនជាផ្ដិតច្បាស់នោះ គឺផ្ដិតនៅក្រសួងឃោសនានោះគឺអាចច្បាស់ជាងនេះ។ ហើយខ្ញុំដឹងថារូបថតនេះបើសិនយករូបថតច្បាប់ដើមមក គឺវាច្បាស់ជាងនេះទៀត បាទមើលឃើញ តែខ្ញុំអធ្យាស្រ័យមិនមានច្បាប់ដើម។

[១៥:៣៩:៥២]

**ស៖** នៅពេលដែលយើងមើលរូបថតនេះ គឺថាយើងមានអារម្មណ៍ថា ទាហានដែលយើងឃើញនៅខាងស្តាំដៃនេះ គឺមើលទៅដូចជាទាហានហ្នឹងតែម្នាក់ឯងទេ។ តើទាហានហ្នឹងម្នាក់ឯង ឬមានជាក្រុម គាត់ជាមនុស្សម្នាក់នៅក្នុងក្រុមទាហានមួយ?

**ឆ៖** គឺយើងមានទាហានហ្នឹងច្រើននាក់ ប៉ុន្តែខ្ញុំដើរពីក្រោយក្រុមទាហានហ្នឹង។ បើសិនយើងមើលទៅលើរូបថតផ្សេងទៀតនោះ គឺថានឹងឃើញមានទាហានច្រើនទៀត ហើយមានការឃើញការបាញ់សម្លាប់ផងដែរ។ រូបថតនេះគឺថាខ្ញុំគ្រាន់តែថត ដើម្បីឲ្យខ្ញុំហ្នឹងអាចចងចាំ និងមើលឃើញតែប៉ុណ្ណោះ។ គឺខ្ញុំវាសំណាងណាស់ ដែលថាខ្ញុំដើរជាមួយនឹងហ្វូងក្រុមទាហាន ហើយមិនមានបញ្ហាអ្វីកើតឡើង ហើយគ្មាននរណាម្នាក់មករំខានខ្ញុំ។ ខ្ញុំដើរជាមួយនឹងទាហាន ៗផ្សេងទៀត គឺថាយល់ថាខ្ញុំនៅក្នុងក្រុម ហើយប្រសិនបើខ្ញុំនេះសុំគេជិះឡាន ឬជិះយានយន្តណាទៅជាមួយគេនោះ គឺថាប្រហែលគេនឹងរំខាន ហើយធ្វើឲ្យខ្ញុំមានបញ្ហា។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំដើរតាមហ្វូងអ៊ីចេះ ដូចថាគេមិនធ្វើអ្វីខ្ញុំនោះទេ។ ហើយខ្ញុំដើររហូតទៅដល់មន្ទីរពេទ្យព្រះកេតុមាលា។ ហើយបន្ទាប់មកគឺដល់កន្លែងឈប់។ ដល់កន្លែងមួយហ្នឹង គឺថាខ្ញុំឃើញប្រជាជន។ ឃើញប្រជាជន ក៏ប៉ុន្តែនៅកន្លែងពីរផ្សេងទៀតនោះ គឺថាមិនមានប្រជាជនដើរទេ ក្រៅតែពីអ្នកកាសែតដើរហើរកន្លែងខ្លះតែប៉ុណ្ណោះ។

[១៥:៤១:៤០]

**ស៖** បាទ ឥឡូវខ្ញុំសូមបង្ហាញរូបថតចុងក្រោយមួយចំនួន ខ្ញុំមិនដឹងថា រូបថតនេះបានផ្តល់ជូនទៅសាក្សីហើយឬនៅទេ? ហើយខ្ញុំក៏មិនដឹងថាខាងសោតទស្សន៍នោះមានរូបថតនេះហើយឬនៅដែរ? តែរូបថតទាំងអស់នេះ ខាងសហព្រះរាជអាជ្ញាបានទទួលពីមជ្ឈមណ្ឌលកម្ពុជា ហើយអ៊ីចឹងខ្ញុំសូមឲ្យលោកធ្វើការសង្កេតលើរូបថតទាំងអស់នេះ ហើយលើចំណារជាដើមនោះ។ ហើយអ៊ីចឹងខ្ញុំសូមសួរលោកថា តើរូបថតទាំងអស់នេះពិតជារូបថតរបស់លោកដែរឬក៏អត់? តើអាចយករូបថតនេះទៅឲ្យសាក្សីបានដែរឬទេ? ហើយនឹងសូមឲ្យខាងសោតទស្សន៍បញ្ចាំងរូបថតទាំងអស់នេះលើអេក្រង់ផងដែរ។

បាទ អ្វីដែលយើងចាប់អារម្មណ៍នោះ គឺថាយើងចាប់អារម្មណ៍ទៅលើរូបថតដែលយើងបង្ហាញទៅលើបង្ហាញទៅឲ្យលោកសាក្សី។ បាទ អ៊ីចឹងសូមលោកមើលតែរូបបានហើយ កុំបាច់មើលចំណារនៅលើហ្នឹង ការអត្ថាធិប្បាយនៅលើហ្នឹង។ នេះរូបថតទី១ តើលោកអាចជម្រាបតុលាការបានទេថារូបថតនេះជារូបថតអ្វី? ហើយតើលោកជាអ្នកថតរូបថតនេះមែនទេ?

[១៥:៤៣:៣២]

**ឆ៖** នេះគឺជារូបថតរបស់ខ្ញុំ។ ខ្ញុំថតនៅថ្ងៃ១២ មេសា ឆ្នាំ៧៥។ នេះគឺជាទីតាំងដែលគេជម្លៀស ទីតាំងទូតសហរដ្ឋអាមេរិកដែលជាកន្លែងគេជម្លៀស។ នេះជាកងទ័ពជើងទឹក ហើយជាអ្នកការពារសន្តិសុខនៅក្នុងតំបន់ហ្នឹងផងដែរ។ យើងឃើញមានឧទ្ធម្ភាគចក្រហោះមកដល់ទីតាំងនេះ ហើយនេះគឺជាឧទ្ធម្ភាគចក្រចុងក្រោយហើយ ដែលក្រុមកងទ័ពជើងទឹកនេះឡើងជិះ ដើម្បីចាកចេញទៅ។ ខ្ញុំមានរូបថតបែបនេះច្រើនទៀតពាក់ព័ន្ធ ដែលបង្ហាញអំពីការជម្លៀស ហើយរូបថតនេះ គឺជារូបថតដែលខ្ញុំពេញចិត្តមួយផងដែរ។ យើងឃើញថានៅក្នុងរូបថតមួយចំនួនផ្សេងទៀតនោះ គឺថាមានឧទ្ធម្ភាគចក្រដែលប្រជាជនឡើងជិះទៅ -- ឡើងជិះដើម្បីចាកចេញទៅ។

**សៈ** ទាក់ទងនឹងការជម្លៀសនេះ ជាលក្ខណៈទូទៅ តើលោកមានចាំថាមានការចេញបញ្ជាទាក់ទងទៅនឹងអាណិកជនអាមេរិកាំង និងបរទេស ដែលឲ្យចេញពីប្រទេសកម្ពុជា តើលោកដឹងថាមានបញ្ជាចេញពីរណសិរ្សរួបរួមជាតិ ហើយនិងរាជរដ្ឋាភិបាលរួបរួមជាតិដែរឬទេ គឺនិយាយឲ្យចំទៅ គឺថាចេញពីខាងអាជ្ញាធរខ្មែរក្រហម?

[១៥:៤៥:០៨]

**ឆ៖** ខ្ញុំអត់ដឹង ខ្ញុំមិនអាចឆ្លើយបានទេ យើងឮអំពីការជម្លៀសជនជាតិអាមេរិកដែលវាអាច កើតឡើងនាពេលឆាប់ៗនៅពេលនោះ។ ខ្ញុំដឹងថាអាមេរិកភាគច្រើននោះដឹងថានឹងមានអ្វីកើតឡើង ហើយជនជាតិខ្មែរនោះគឺគាត់មិនដឹងនោះទេ។ ហើយបុគ្គលមួយចំនួនដែលមិនទទួលបានសារទាន់ពេលវេលានោះ មិនត្រូវបានគេជម្លៀសនោះទេ។ ឧទ្ធម្ភាគចក្រចុងក្រោយនោះគឺមានប្រាំទៅប្រាំមួយតែប៉ុណ្ណោះដែលមកជម្លៀស។ ហើយមានប្រជាជនតិចណាស់ដែលអាចឡើងជិះឧទ្ធម្ភាគចក្រនោះចាកចេញបាន។ ហើយប្រជាជនតិចតួចបំផុតគឺឡើងជិះ ហើយគឺមានក្រុមទាហានជើងទឹកនោះក៏បានឡើងជិះយន្តហោះឧទ្ធម្ភាគចក្រប្រាំ,ប្រាំមួយចុងក្រោយនោះផងដែរ។ មានប្រជាជនមកពីគេហៅថាសណ្ឋាគារ ឡឺភ្នំ ផងដែរ ក៏ប៉ុន្តែប្រជាជនមួយចំនួននោះមិនបានដឹងអំពីការជម្លៀសនោះទេ។

**សៈ** បាទឥឡូវនេះយើងនិយាយទៅមុខទៀត។ សូមបង្ហាញរូបថតមួយទៀតដែលជារូបថតទី ៥ បើសិនជាខ្ញុំមិនច្រឡំទេ។ នៅក្នុងឯកសារនេះរូបថតនេះមានលេខរៀងលេខ៥។ បើអ៊ីចឹងសូមបញ្ចាំងរូបនេះទៅលើអេក្រង់។

[១៥:៤៦:៤៦]

បាទ មិនមែនរូបថតនេះទេ តាមពិតរូបថតបន្ទាប់ហ្នឹងទៀត។ បាទរូបថតនេះហើយ។ តើលោក

ជាអ្នកថតរូបថតហ្នឹងមែនទេ? តើលោកអាចផ្តល់ព័ត៌មានមួយចំនួនទាក់ទងទៅនឹងរូបថតហ្នឹង បានដែរឬទេ?

**ឆ៖** នេះជារូបថតដែលខ្ញុំថត។ ខ្ញុំថតរូបថតនេះនៅផ្លូវបំបែកព្រះមហាវិថីព្រះមុនីវង្ស និងកាត់មហាវិថីព្រះសីហនុ។ យើងឃើញថាមាន នៅក្នុងនេះមានក្មេងៗដែលជួយខ្មែរក្រហមប្រមូលផ្តុំអាវុធ។

**សៈ** ហើយក្មេងៗទាំងអស់នោះជាអ្នកណាដែរ? ជាក្មេងអនាថានៅភ្នំពេញឬក៏ជាកូនខ្មែរក្រហម?

**ឆ៖** ខ្ញុំគិតថាប្រជាជនសាមញ្ញតាមផ្លូវឃើញប្រជាជន កូនក្មេងសាមញ្ញៗតាមផ្លូវនេះគ្មានផ្ទះសម្បែងនៅច្រើនណាស់ ពួកគេគ្រាន់តែត្រូវបានគេបង្ខំឱ្យជួយទៅលើការងារនេះតែប៉ុណ្ណោះ។ ខ្ញុំស្ទាក់ស្ទើរក្នុងការប្រើថា កុមារទាំងអស់នេះជាសិស្សសាលាណាស់ដោយសារតែគ្មានសាលាណាឱ្យពួកគេទៅរៀននោះទេ ដោយសារតែខ្មែរក្រហមបង្ខំឱ្យពួកគេជួយធ្វើការងារប្រមូលអាវុធនៅពេលនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ឥឡូវយើងបន្តទៅរូបថតបន្ទាប់ពីរូបថតចុងក្រោយនៃឯកសារនេះ អ៊ីចឹងខ្ញុំសូមអនុញ្ញាតបញ្ចាំងរូបថតនេះនៅលើអេក្រង់។

[១៥:៤៩:២០]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**សៈ** បាទលោកសាក្សីតើលោកជាអ្នកថតរូបថតនេះមែនទេ? តើលោកអាចពិពណ៌នារូបថតនេះបន្តិចបានទេ?

**លោក អាល់ រ៉ុក្កូហ្វ៖**

**ឆ៖** នេះគឺជារូបថតដែលខ្ញុំថតនៅពីមុខស្ថានទូតបារាំង។ នេះជញ្ជាំងនេះគឺថាវាធ្លាប់ជាជញ្ជាំងស្ថានទូតដែលមនុស្សគេវារឡើង ហើយឡាននេះគឺថាមានដឹកស្បៀងអាហារ ប៉ុន្តែអស់សាំង។ យើងឃើញហើយថាមានស្បៀងនៅក្នុងឡាន។ ឡាននេះគេរុញមកពីសណ្ឋាគារឡឺរ៉ូយ៉ាល់មកដល់ស្ថានទូតបារាំង។ គឺក្រុមកាកបាទ ឡានរបស់ក្រុមកាកបាទក្រហម។ រឿងងងឹតបន្តិចហើយនៅក្នុងពេលនោះបើសិនយើងមើលរូបថតនេះ។ យើងឃើញផ្សែងនៅខាងក្រោយ គឺជាផ្សែងឆេះហ្គារាសសាំងមួយនៅឆ្ងាយដែរ។

**សៈ** ដូច្នេះ យើងមើលឃើញកម្ពស់ជញ្ជាំងរបងហ្នឹង នៃស្ថានទូតបារាំងហ្នឹង។ អ៊ីចឹងយើងមើលឃើញថា របងស្ថានទូតបារាំងហ្នឹងទាបជាងរបងសព្វថ្ងៃនេះ។ តើពេលលោកមើលឃើញជន

ភៀសខ្លួននៅស្ថានទូតនោះ អ្នកដែលនៅមុខនោះ ថាយើងមើលទៅឃើញថាពួកគាត់ហ្នឹង ដូចជាឡេះឡុះ លែងដឹង ធ្វើអីលែងកើតហើយ ឬក៏ថាមានការចុះខសន្យា កិច្ចព្រមព្រៀងអីមួយរវាងខ្មែរក្រហម ហើយ និងស្ថានទូត?

**ឆ៖** ខ្ញុំមិនដឹងថាមានកិច្ចព្រមព្រៀងណាមួយគេចុះហត្ថលេខានោះទេ។ ហើយខាងស្ថានទូតបារាំងមិនបានហាមឃាត់ -- អ៎! មិនរុញច្រានប្រជាជនចេញមកទេ គឺគ្រាន់តែទុកកុំឲ្យប្រជាជនវារចូល ឬក៏ឡើងជញ្ជាំងចូលទូតតែប៉ុណ្ណោះ។ យើងដឹងហើយថា យើងឃើញថានៅខាងក្រោយស្ថានទូតនោះ ឃើញជញ្ជាំងហ្នឹង ប្រជាជនគាត់តោងឡើង។ យើងដឹងហើយថា នៅពេលបច្ចុប្បន្ននេះ ជញ្ជាំងរបងស្ថានទូតបារាំងពេលបច្ចុប្បន្ននេះ ប្រហែលជាខ្ពស់ជាងមុនបីដងឯណោះ។ ហើយកាលពីមុនមិនខ្ពស់ដូចឥឡូវនេះទេ។ ឥឡូវនេះទើបតែសាងសង់របងថ្មីតែប៉ុណ្ណោះ។

[១៥:៥២:០៥]

**ស៖** បាទ ខ្ញុំសូមបង្ហាញរូបចុងក្រោយ។ សូមអនុញ្ញាតបញ្ចាំងរូបនេះនៅលើអេក្រង់។ តើលោកជាអ្នកថតរូបថតនេះមែនទេ? លោកបាននិយាយពីរូបថតនេះអម្បាញ់មិញ តើរូបថតនេះមានខ្លឹមសារយ៉ាងដូចម្ដេចដែរ?

**ឆ៖** នេះមិនស្ថិតនៅក្នុងស្ថានទូតបារាំងនោះទេ។ រូបថតថតមុនពេលបែកទីក្រុងភ្នំពេញ។ ទាហាន លន់ នល់ ដែលត្រូវបានបាញ់ត្រង់ក្បាល ត្រូវបានបាញ់នៅស្តាតអូឡាំពិក ដែលយើងឃើញថានៅកន្លែងតារាងបាល់បាស្កេត បាល់បោះនោះគឺថាមានទ័ពជាច្រើននៅទីនោះផងដែរ។ ហើយយើងឃើញថាមាន ប្រជាជន ទាហានមួយចំនួនត្រូវបានគេបាញ់ត្រង់ក្បាល ហើយវេជ្ជបណ្ឌិតនោះគឺបានព្យាបាល។ នៅក្នុងរូបថតនេះ គឺថាជាទាហានដែលបាញ់ ត្រូវបាញ់ចំក្បាលហើយស្លាប់។ រូបថតនេះថតហ្នឹងគឺ បង្ហាញថាទាហាននេះបានស្លាប់២០នាទីនេះ ហើយទើបខ្ញុំបានថតរូបថតនេះ។

**ស៖** ដូច្នេះ រូបថតនេះមិនបានថតនៅថ្ងៃទី១៧ មេសា ទេ ក៏ប៉ុន្តែថតមុនថ្ងៃ១៧ មេសា បន្តិច។ តើខ្ញុំយល់នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ប្រហែលជា១ខែ ទៅ ២ខែឯណោះ មុន១៧ មេសា។ មិនមែនថាជិតបែកទីក្រុងភ្នំពេញនោះទេ ប្រហែលជាថតនៅក្នុងខែមករា។ យើងឃើញថាមានទីតាំងមួយចំនួនដែលគេធ្វើការសាងសង់ឡើង ហើយនៅតាមទីកន្លែងមួយចំនួននៅក្នុងទីក្រុងភ្នំពេញ ហើយគេបានមកយកទីតាំងនេះដើម្បីស្នាក់នៅ។ តែយើងមិនត្រូវច្រឡំ មិនត្រូវច្រឡំជាមួយនឹងទាហានរដ្ឋាភិបាលដែលរបួស ហើយដាក់នៅ ស្ថិត

នៅក្នុងស្ថានទូតបារាំងនោះទេ។ រូបថតនេះ ហើយនិងរូបថតទាហានរបួសក្នុងស្ថានទូតបារាំងនោះ គឺខុសគ្នា។

[១៥:៥៤:៣៦]

**ស៖** បាទជាទូទៅជនភៀសខ្លួន ដែលមកទីក្រុងភ្នំពេញ ចូលមកទីក្រុងភ្នំពេញ តើអាជ្ញាធរខ្មែរ ឬក៏រដ្ឋាភិបាលរបស់សាធារណរដ្ឋខ្មែរនោះ ប្រព្រឹត្តទៅលើពួកគាត់យ៉ាងម៉េចដែរ តើមានវិធានការជួយ ដូចជា ផ្តល់ជាលំនៅដ្ឋាន ឬក៏ចំណីអាហារ ស្បៀងអាហារជាដើម ដើម្បីឲ្យគាត់អាចមានលទ្ធភាពហូប ចុក។ តើមានការរៀបចំយ៉ាងម៉េចដែរ ហើយប្រព្រឹត្តយ៉ាងម៉េចដែរទៅលើជនភៀសខ្លួនទាំងអស់នោះ?

**ឆ៖** យើងឃើញមានអ្នកជនភៀសខ្លួនរាប់សែននាក់ដែលគ្មានទីលំនៅ ហើយគេមិនបានទៅជំរំ ភៀសខ្លួន ដែលរៀបចំឡើងដោយសេវាកម្មរៀបចំសម្រាប់អ្នកជនភៀសខ្លួននោះទេ។ យើងឃើញថាជំរំ ភាគច្រើននៅក្រៅទីក្រុងភ្នំពេញ។ យើងដឹងថាមានជំរំជនភៀសខ្លួនមួយនៅក្នុងសណ្ឋាគារកាំបូឌីយ៉ាណា ហើយយើងឃើញថាមានបន្ទប់មួយចំនួន ដែលថាគេរៀបចំឡើងនៅក្នុងសណ្ឋាគារកាំបូឌីយ៉ាណា។ យើងដឹងថានៅពេលនោះមានជនភៀសខ្លួនពី ២១.០០០នាក់ ទៅដល់២៣.០០០នាក់ ដែលជាជនភៀស ខ្លួននៅក្នុងសណ្ឋាគារកាំបូឌីយ៉ាណា។ យើងខ្ញុំ -- ខ្ញុំបានទៅតាមផ្លូវមើលស្ថានភាព ហើយយើងឃើញ មានការយកស្បៀងអីផងដែរមកផ្តល់ឲ្យប្រជាជនរាប់ពាន់នាក់ ចូលប្រហែលជាពី២១.០០០ ទៅ២៣.០០០ នាក់ ដែលគេបានយកស្បៀងអាហារមកឲ្យប្រជាជនទាំងអស់នោះ គឺណែនណាន់តាន់តាប់ណាស់។ ជនភៀសខ្លួនមួយចំនួនទៀតមិនបានទៅតាមទីតាំងជំរំជនភៀសខ្លួនដែលគេរៀបចំឡើងនោះទេ គេទៅ តាមកន្លែងដែលពួកគេចង់ទៅ។ ហើយជារឿយៗនោះគឺថា យើងឃើញរដ្ឋាភិបាល និងខ្មែរក្រហមមិន មានការយកចិត្តទុកដាក់នោះទេ។ ប៉ុន្តែសណ្ឋាគារកាំបូឌីយ៉ាណានេះ នៅពេលនោះគឺជាទីតាំងដែលគេ រៀបចំសម្រាប់ជនភៀសខ្លួននាពេលនោះ។

[១៥:៥៦:៥៦]

**ស៖** លោកបានជម្រាបជូនថា នៅពេលដែលលោកចាកចេញតាមក្បួនឡានខ្មែរក្រហមហ្នឹង ជា ដំបូងថាឆ្លងកាត់តាមព្រលានយន្តហោះពោធិ៍ចិនតុង ហើយបន្ទាប់មកទៀតលោក ដែលឈ្មោះជាភាសា បារាំងហ្នឹង គេហៅថា ផ្លូវលំ ឬផ្លូវតូច។ តើផ្លូវដែលលោកជិះទៅនោះ តើគេជិះតាមផ្លូវហ្នឹងដោយ ចេតនាតែម្តង ក្នុងការជ្រើសរើសយកផ្លូវលំនេះ អ៊ីចឹងឬក៏យ៉ាងម៉េច?

**ឆ៖** នៅពេលនោះខ្ញុំមិនបានគិតពីបញ្ហាហ្នឹងច្រើននោះទេ ដោយសារតែបញ្ហាមនុស្សធម៌មួយ

ចំនួននោះ គឺយើងឃើញថា គេបានបោះទៅតាមជួរផ្លូវជាតិលេខ៥ គឺណែនណាន់តាន់តាប់ណាស់។ ផ្លូវដែលយើងទៅតាមនោះគឺទៅតាមខាងកើតភ្នំប្រសិទ្ធិ៍ ហើយគឺជាកន្លែងដែលយើងធ្លាប់ធ្វើការ។ ជាទូទៅ ខ្មែរក្រហមគេមិនមើលផែនទីទេ គេជិះទៅតែម្តង។ អ្វីដែលខ្ញុំអាចចំណាំបាននោះ គឺថាភ្នំខដុង្គ និងភ្នំប្រសិទ្ធិ៍ដែលខ្ញុំស្គាល់។ ខ្មែរក្រហមប្រើប្រាស់ផ្លូវនេះមួយរយៈពេល ហើយវាជាផ្លូវវាសម្រាប់តែឡានចិនទេដែលជិះបាន។ ហើយខ្មែរក្រហមគឺថាពេលខ្លះទៅ យើងឃើញមានកូនក្មេងឡើងលើដើមឈើ ហើយធ្វើការទាញឈើដើម្បីធ្វើឲ្យផ្លូវនេះពិបាក ហើយផ្លូវនោះពេលខ្លះទៅជង្ហុកជ្រៅណាស់នៅក្នុងរដូវវស្សា។ ដូច្នេះឡានគឺពេលខ្លះទៅមិនអាចជិះចូលបាននោះទេ ដូច្នេះហើយគឺយើងពេលខ្លះចុះលុយទឹកផងដែរ។

[១៥:៥៩:០៧]

ខ្ញុំគិតថា នៅក្នុងរដូវវស្សានោះ ទោះបីជ្រៅយ៉ាងណាក៏ដោយ ពេលខ្លះគឺថាយើងអាចលុយទឹកជ្រៅចុះបាន។ យើងឃើញថាភាគច្រើននោះគឺខ្មែរក្រហមពេលនោះប្រើផ្លូវនេះមួយរយៈពេលផងដែរ។ ខ្ញុំមិនឃើញប្រជាជនទេនៅពេលដែលជិះតាមផ្លូវនុ៎ង ហើយមិនឃើញប្រជាជនទាំងហ្វូងៗទេ ខ្ញុំឆ្លើយពីមុនរួចមកហើយ។ ខ្ញុំមិនបានឃើញគេកាប់សម្លាប់ប្រជាជន ឬឃើញសញ្ញាណាមួយដែលបង្ហាញអំពីការកាប់សម្លាប់នោះទេ ហើយខ្ញុំក៏មិនអាច -- ពេលខ្លះមិនអាចធុំក្លិនដែរ ក្រៅតែពីថាធុំក្លិនសាកសព ក្រៅតែពីក្លិនស្រូវ។ ហើយខ្មែរក្រហមនោះពេលនោះក៏មិនមានការខឹងសម្បា ហើយអ្វីដែលគេចង់បានគឺថាមកតែសុំបារីជក់តែប៉ុននុ៎ង។

[១៦:០០:០៧]

មានខ្មែរក្រហមមួយចំនួនតូចនោះ គឺថាគឺគាត់បានរុញច្រាន -- កម្មាភិបាលខ្មែរក្រហមនោះ គឺកម្មាភិបាលខ្មែរក្រហមរុញច្រានកូនទាហានខ្មែរក្រហមដែលថាចេះតែមករកជនបរទេស។ ខ្ញុំឈរនៅតាមផ្លូវខ្លះដែរ ហើយខ្ញុំបានមើលឃើញថាមានប្រជាជន២៣នាក់នៅលើឡាន ហើយពេលខ្លះទៅខ្មែរក្រហមនោះ គេហៅ រ៉ុក្វហ្វៗ ហើយចង្អុលមកខ្ញុំ ហើយហៅដូចជាក្រុកៗ ឈ្មោះខ្ញុំហៅស្រដៀងអ៊ីចឹង។ ហើយគឺមានបុគ្គលម្នាក់នោះគឺថាធ្លាប់ធ្វើការនៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ហើយគាត់ស្គាល់ខ្ញុំ ហើយនៅពេលដែលខ្ញុំមើលគាត់ទៅ គាត់ថាគឺគាត់ស្គាល់ខ្ញុំ ប៉ុន្តែគាត់យ៉ាងណាក៏ដោយគឺគាត់មិនមកជិតខ្ញុំនោះទេ។ បាទអធ្យាស្រ័យអំមិញខ្ញុំប៉ះ តើលោក លោកស្រីចៅក្រមឮខ្ញុំនិយាយទេ អំមិញខ្ញុំគិតថាខ្ញុំប៉ះស្ពីបែក។ ហើយមានបុរសម្នាក់នោះមកជិតខ្ញុំនោះ ហើយពួកគាត់ បុរសម្នាក់ហ្នឹងគឺថាប្រយ័ត្នណាស់គាត់ធ្វើយ៉ាងណាកុំឲ្យគេដឹងថាគាត់ហ្នឹងស្គាល់ខ្ញុំ។ គឺនេះជាបទពិសោធន៍មួយដែរ ដែលខ្ញុំបានឃើញ

ហើយបុរសម្នាក់ដែលថាស្គាល់ខ្ញុំហ្នឹង គឺខ្ញុំមិនដែលឃើញគាត់ទៀតទេ។

**ស៖** តើលោកចេញទៅតាមក្បួនឡានហ្នឹងជាខ្សែទី១ ឬក៏ខ្សែទី២?

**ឆ៖** ខ្ញុំស្តាប់អត់ឮទេ មានបញ្ហាអ្វីដែរ?

[១៦:០២:០២]

**ប្រធានអង្គជំនុំ៖**

បាទ *បាធីរី* ប្តូៗ!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ហើយឥឡូវ តើលោកឮខ្ញុំហើយនៅ? បាទ អម្បាញ់នេះខ្ញុំសួរលោកថាតើលោកចេញទៅតាមក្បួនឡានទី១ ឬក៏ក្បួនឡានទី២ ដែលចេញពីស្ថានទូតបារាំងទៅប្រទេសថៃនោះ?

**លោក អាល់ រ៉ូកូហ្វ៖**

**ឆ៖** គឺខ្ញុំជិះឡានទី១ នៅក្នុងក្បួនរថយន្តទី២។

**ស៖** តើអ្នកកាសែតបានទទួលបញ្ជាជាក់លាក់ណាមួយថា កុំនិយាយអំពីអ្វីដែលកើតមានឡើងនៅទីក្រុងភ្នំពេញ ឧទាហរណ៍ដូចជាការលំបាកនៅក្នុងប្រទេសកម្ពុជាជាដើមនោះ?

**ប្រធានអង្គជំនុំ៖**

ម្តងទៀត ដូចអត់ឮ មានបញ្ហា*បាធីរី*ដដែល។ យកថ្មីផ្សេងទៀត!

[១៦:០៣:៤៤]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ ឥឡូវលោកឮខ្ញុំហើយឬនៅ? អំម្បាញ់មិញនេះ ខ្ញុំសួរលោកថាតើលោកមានដឹងថាមានការចេញបញ្ជាទៅអ្នកកាសែតថាកុំឲ្យនិយាយអំពី និយាយ ឬក៏សរសេរអត្ថបទសារព័ត៌មានដើម្បីជៀសវាងឲ្យផុតពីការលំបាកចំពោះអ្នកដែលរស់នៅទីក្រុងភ្នំពេញ?

**លោក អាល់ រ៉ូកុហ្វ៖**

**ឆ៖** តាមដែលខ្ញុំដឹង គឺមានការដាក់បង្គាប់ទាក់ទងទៅនឹងរឿងរ៉ាវនៃស្ថានភាពនោះផងដែរ គឺជាការដាក់ដោយខ្លួនឯង ដាក់ទៅលើក្រុមរថយន្តក្បួនទី១ ដែលនិយាយអំពីរឿងដែលថាមិនឲ្យទាក់ទងដល់ក្រុមក្បួនរថយន្តទី២។ ខ្ញុំមិនដឹងអំពីបញ្ហានយោបាយ ថាតើវាជាការរំលោភបំពាន ឬអ្វីនោះឡើយ។ គឺថាគឺមានការប្រាប់ដល់ក្បួនទី១ មុននឹងគេអនុញ្ញាតឲ្យក្បួនទី២ ចេញ។ នៅពេលដែលក្រុមក្បួនទី១ទៅ

ដល់ព្រំដែនប្រទេសថៃ គឺនៅពេលនោះ គឺគេចាប់ផ្ដើមផ្សព្វផ្សាយរឿងជាច្រើននៅក្នុងប្រទេសថៃនោះ គឺរឿងអំពីប្រទេសកម្ពុជា។ អ្វីដែលយើងដឹងគឺថាមានការជម្រាបតិចតួចទៅដល់បុគ្គលិករបស់បុគ្គលិក ប៊ី.ប៊ី.ស៊ី គឺថាយើង គឺគេប្រាប់ព័ត៌មានមួយចំនួនដល់ពួកគាត់មុនពេលដែលចាកចេញ។ នេះគឺជាអ្វីកើតឡើងប្រហែលជា២-៣ថ្ងៃនោះ។ ហើយមានព័ត៌មាននៅតាមព័ត៌មាន ប៊ី.ប៊ី.ស៊ី ដែលថានៅពេលដែលក្រុមទី១ គឺមានគេប្រាប់ គឺហែក្បួនហ្នឹង គឺក្បួនជនបរទេសចុងក្រោយដែលបានចាកចេញ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ លោកសាក្សី ខ្ញុំសូមអរគុណលោកជាច្រើនដែលបានផ្ដល់ការបំភ្លឺនៅរសៀលនេះ។ ហើយខ្ញុំអស់សំណួរចោទសួរលោកទៀតហើយ។ សូមអរគុណលោកប្រធាន។

[១៦:០៥:៥៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម អរគុណសាក្សី។

[១៦:០៦:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៧:៣០]

**ប្រធានអង្គជំនុំ៖**

បាទ មុននឹងសម្រាក អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្ដី ពីព្រោះដល់ពេលស្អែកនេះ គឺដល់ពេលវេលាដែលអង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដើម្បីសួរសាក្សីរូបនេះហើយ។ ហើយចង់ដឹងថាទំនងជាការប្រើប្រាស់ពេលប៉ុន្មានដែរក្នុងការសួរសាក្សីរូបនេះ។ ដោយចាប់ផ្ដើមពីក្រុមមេធាវីការពារក្ដីលោក នួន ជា មុន។

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន ខ្ញុំគិតថាប្រហែលជាខ្ញុំត្រូវការពេលវេលាកន្លះម៉ោងតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះក្រុមមេធាវីការពារក្ដីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរអស់លោក លោកស្រី។ ផ្អែកទៅលើការសាកសួរ ខ្ញុំអាចមាន ឬក៏អាចមិន

មានសំណួរ។ ចំពោះខ្ញុំ មកដល់ពេលនេះ ខ្ញុំគិតថាប្រហែលជាខ្ញុំមិនមានអ្វីត្រូវសួរនោះទេ ប៉ុន្តែផ្អែកទៅលើក្រុមមេធាវីការពារក្តីដទៃទៀតអាចថាមាន ប៉ុន្តែក្នុងពេលឥឡូវនេះ គឺខ្ញុំអត់មានអ្វីដែលគ្រោងនឹងសួរនោះទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ចំពោះខ្ញុំថា ខ្ញុំត្រូវការពីម្ភៃទៅសាមសិបនាទី។ នេះតាមការប៉ាន់ស្មាន ហើយក៏វាអាស្រ័យទៅតាមសំណួរដែលគេនឹងសួរនៅថ្ងៃស្អែកនេះផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការបញ្ជាក់អំពីព័ត៌មាននេះ។

អរគុណលោកសាក្សី ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៩ ខែមករា ឆ្នាំ២០០៣ (ស៊ីក) ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មរបស់លោកបញ្ចប់ ដែលនឹងអាចសួរ -- ដែលនឹងសួរដោយមេធាវីការពារក្តី។ សូមភាគី និងសាធារណជនជ្រាប។

លោក អាល់ រ៉ុក្កូហ្វ ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត ដែលទំនងគឺប្រហែលជាមួយព្រឹក។ ដូច្នេះអង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

[១៦:១០:០០]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក អៀង សារី និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក អៀង សារី ឲ្យនាំខ្លួនគាត់មកត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលបានរៀបចំនូវឧបករណ៍សោត

ទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដាននូវកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១០ នាទី)*